ទស្សនាវដ្តីនៃមជ្ឈមណ្ឌលឯកសារកម្ពុជា

# ស្វែងរកការពិត




- ការកសាងសន្តិភាពទាមទារឱ្យមានកិច្ចប្រឹងប្រែងទាំងថ្នាក់ដឹកនាំ
- សហព្រះរាជអាជ្ញា  បញ្ចប់ការធ្វើសេចក្តីសន្និដ្ឋានផ្ទាល់មាត់

ចែកជូនដោយឥតគិតថ្លៃដល់មន្ទីរស្រុកនិងឃុំទូទាំងព្រះរាជាណាចក្រកម្ពុជា

លេខ២១៤ ខែតុលា ឆ្នាំ២០១៧

# ស្វែងរកការពិត

## ទស្សនាវដ្ដីនៃមជ្ឈមណ្ឌលឯកសារកម្ពុជា

លេខ២១៤ ខែតុលា ឆ្នាំ២០១៧

## មាតិកា

◆ ការកសាងសន្តិភាពទាមទារឲ្យមានកិច្ចប្រឹងប្រែង................................១

**ផ្នែកឯកសារ**

◆ សឹម ស៊ីលេណា សេ.អ៊ី.អា មកពីអាមេរិក....................................៦

◆ ចម្លើយសារភាពរបស់ សាយ អាត សមាជិកកងតូច.....................២៨

**ផ្នែកប្រវត្តិសាស្ត្រនិងការស្រាវជ្រាវ**

◆ អតីតកម្មាភិបាលវ័យក្មេង ដែលត្រូវបញ្ជូនឲ្យទៅដឹកនាំនៅតំបន់៥ .........៣៤

◆ ឲ្យតែមានបាយហូបគឺគ្រប់គ្រាន់..................................................៣៦

◆ យុទ្ធនារីពេទ្យបដិវត្តន៍ ..............................................................៣៨

◆ កងចល័តនៅទំនប់ត្រពាំងថ្ម .......................................................៤០

◆ ទោះបីហូបមិនឆ្អែតក៏មិនហ៊ានត្អូញត្អែរ .........................................៤១

**ផ្នែកច្បាប់**

◆ សហព្រះរាជអាជ្ញា បញ្ចប់ការធ្វើសេចក្ដីសន្និដ្ឋានផ្ទាល់មាត់................៤៣

**វេទិកាពិភាក្សាសាធារណៈ**

◆ ជនសង្ស័យនៅក្នុងសំណុំរឿង០០៤ ............................................៥១

**ទំព័រស្រាវជ្រាវរកគ្រួសារ**

◆ មាត់អភ័ព្វអាហារ.......................................................................៥៩



**រក្សាសិទ្ធិ**

មជ្ឈមណ្ឌលឯកសារកម្ពុជា

អនុញ្ញាតឲ្យបោះពុម្ពផ្សាយដោយ
ក្រសួងព័ត៌មាននៃព្រះរាជាណាចក្រកម្ពុជា
ប្រកាសទេសរដ្ឋមន្ត្រីនិងរដ្ឋមន្ត្រីក្រសួងព័ត៌មាន
លេខ០២៩១ពម.៩៩
ចុះថ្ងៃទី២ ខែសីហា ឆ្នាំ១៩៩៩

រូបថតឯកសារៈ មជ្ឈមណ្ឌលឯកសារកម្ពុជា
និងសារមន្ទីរឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ទួលស្លែង

***ស្នេរលេខនេះ*** ៖ *ផេង ពង្ស, សោម លាភ, ហាក់ ដឹលីណា, រ៉ូនិត អារី, អាន ហាញដល, យាង សេងហៀន* ***អ្នកនិពន្ធនិងស្រាវជ្រាវ*** ៖ *ទាវ សារៈមុនិន្ទ និង ហូ ចុនា* ***អ្នកបកប្រែ*** ៖ *អ៊ួច គន្ធា* ***និពន្ធនាយកទូទៅ*** ៖ *ឆាំង យុ* ***ជំនួយការនិពន្ធនាយក*** ៖ *សោម ប៊ុនថន* ***ក្រាហ្វិកកុំព្យូទ័រ*** ៖ *សោម ប៊ុនថន* ***គ្រប់គ្រងការចែកផ្សាយ*** ៖ *សន ល័ក្ខ* **Email: dccam@online.com.kh, Homepage: www.dccam.org, www.cambodiatribunal.org, www.cambodiasri.org, www.truthcambodia.com**

# ការកសាងសន្តិភាពតាមការឱ្យមាន កិច្ចប្រឹងប្រែងទាំងថ្នាក់ដឹកនាំ និងថ្នាក់មូលដ្ឋាន

ពាក្យ "សន្តិភាព" ត្រូវបានកំណត់និយមន័យខុសៗគ្នានៅក្នុងបរិបទកម្ពុជា ។ នៅក្នុងកម្រិតថ្នាក់ដឹកនាំ ព្រឹត្តិការណ៍ដ៏គួរជាទីកត់សម្គាល់ចំនួនពីរបានផ្តល់នូវពន្លឺនៃក្តីសង្ឃឹមថាសន្តិភាពអាចកើតមានឡើងនៅក្នុងប្រទេសកម្ពុជា ។ ព្រឹត្តិការណ៍ទាំងពីរនេះ រួមមានកិច្ចព្រមព្រៀងសន្តិភាពទីក្រុងប៉ារីសក្នុងខែតុលា ឆ្នាំ១៩៩១ និងការធ្វើសមាហរណកម្មឆ្នាំ១៩៩៨ នៃតំបន់អន្លង់វែងដែលជាតំបន់តស៊ូចុងក្រោយនៃចលនាខ្មែរក្រហម ។

ជាការគាប់ជួន ការបន្តឡើងវិញនៃ "ទស្សនកិច្ចសិក្សាស្តីពីសន្តិភាព និងសិទ្ធិមនុស្សនៅតំបន់អន្លង់វែង" ដែលជាគម្រោងមួយដែលទទួលមូលនិធិពីប្រទេសកាណាដា នៅថ្នាក់មូលដ្ឋានក្នុងតំបន់អន្លង់វែង បានកើតឡើងស្របគ្នាក្នុងអំឡុងខួបប្រចាំឆ្នាំនៃកិច្ចព្រមព្រៀងសន្តិភាពទីក្រុងប៉ារីស ។ បច្ចុប្បន្នសុពលភាពនៃកិច្ចព្រមព្រៀងនេះត្រូវបានលើកយកមកពិភាក្សាដោយភាពចម្រូងចម្រាស់នៅឡើយ ។ គោលបំណងនៃកិច្ចព្រមព្រៀងនេះ បានស្តែងឲ្យឃើញពីការបញ្ចប់ជាផ្លូវការនៃជម្លោះដ៏រ៉ុាំរ៉ៃនៅកម្ពុជា ។ ទោះជាយ៉ាងណាក្តី គោលបំណងនេះមិនត្រូវបានសម្រេចភ្លាមៗជាស្ថាពរនៅឆ្នាំ១៩៩១ ដែលនៅពេលនោះ កិច្ចព្រមព្រៀងសន្តិភាពត្រូវបានប្រកាសឡើយ ប៉ុន្តែសន្តិភាពត្រូវបានសម្រេចជោគជ័យទាល់តែប្រាំពីរឆ្នាំក្រោយមកឯណោះ ។

ដោយមានការធ្វើសមាហរណកម្មចុងក្រោយនៃតំបន់អន្លង់វែងចូលក្នុងប្រទេសកម្ពុជានៅឆ្នាំ១៩៩៨ មកដល់ឆ្នាំនេះមានរយៈពេល១៩ឆ្នាំមកហើយ (១៩៩៨-២០១៧) ចាប់តាំងពីពេល



រូបខាងឆ្វេង ៖ បណ្ឌិត លី សុខឃាង នាយកមជ្ឈមណ្ឌលសន្តិភាពអន្លង់វែងបានធ្វើបទបង្ហាញពីប្លង់គោលសម្រាប់អភិវឌ្ឍតំបន់អន្លង់វែងប្រាប់ទៅគណៈប្រតិភូមកពីប្រទេសស៊ុយ ក្នុងអំឡុងពេលទស្សនកិច្ចនៅស្រុកអន្លង់វែង ខេត្តឧត្តរមានជ័យ ។



និស្សិតស្ម័គ្រចិត្តរបស់គម្រោងមជ្ឈមណ្ឌលសន្តិភាពអន្លង់វែងកំពុងស្តាប់វាគ្មិនរៀបរាប់ពីបទពិសោធន៍ផ្ទាល់ខ្លួនក្នុងរបបខ្មែរក្រហម ក្នុងអំឡុងពេលទស្សនកិច្ចសិក្សារយៈពេល៨ថ្ងៃ នៅស្រុកអន្លង់វែង ខេត្តឧត្តរមានជ័យ ។

ដែលប្រជាជនកម្ពុជាអាចស្គាល់នូវសុខសន្តិភាពក្នុងប្រទេសខ្លួន ។ នៅក្នុងបរិបទនេះ សន្តិភាពគឺសំដៅលើអវត្តមាននៃជម្លោះហិង្សា ហើយមិនមែនសំដៅលើសន្តិភាពបែបវិជ្ជមាននោះឡើយ ។

ម្យ៉ាងទៀត វាជាការពិតណាស់ដែលការថែរក្សាសន្តិភាព នៅតែជាកិច្ចការដែលត្រូវការពេលច្រើន ។ សន្តិភាពទាមទារឲ្យមានវិធានការបង្ការទុកជាមុន និងជាក់ស្តែងដែលវិធានការទាំងនេះពាក់ព័ន្ធនឹងមនុស្សគ្រប់ស្រទាប់វណ្ណៈនៃសង្គម ។ សូមក្រឡេកមើលមជ្ឈមណ្ឌលសន្តិភាពអន្លង់វែងដែលជាគំរូមួយជាក់ស្តែងស្រាប់ ។ មជ្ឈមណ្ឌលនេះផ្តួចផ្តើមចេញពីគម្រោងមួយក្នុងចំណោមគម្រោងសន្តិភាពតាមមូលដ្ឋានសហគមន៍មួយចំនួនដែលត្រូវបានបង្កើតឡើងដោយមជ្ឈមណ្ឌលឯកសារកម្ពុជា រួមសហការជាមួយក្រសួងទេសចរណ៍ ។ គម្រោងនេះក៏បានដាក់ឲ្យដំណើរការនូវគម្រោងផ្សេងៗទៀតដែលទាក់ទងទៅនឹងការស្រាវជ្រាវ ការអប់រំ និងការតាំងពិព័រណ៍ជាដើម ។ ក្នុងចំណោមគម្រោងទាំងនេះ គម្រោងដែលគួរឲ្យកត់សម្គាល់ គឺដំណើរទស្សនកិច្ចសិក្សាស្តីពីសន្តិភាព និងសិទ្ធិមនុស្សនៅតំបន់អន្លង់វែង ដែលត្រូវបានលើកមកបង្ហាញមុននេះ ។ វាជាកម្មវិធីមួយដែលត្រូវបានរៀបចំឡើងដើម្បីធ្វើការលើកកម្ពស់ការសន្ទនាបែបអន្តរបុគ្គល និងបែបអន្តរសហគមន៍ដែលជាផ្នែកមួយនៃគោលបំណងដ៏វិសាលរបស់មជ្ឈមណ្ឌលឯកសារកម្ពុជាក្នុងការលើកកម្ពស់សន្តិភាព ការបង្រួបបង្រួម និងការផ្សះផ្សា ។ ចាប់តាំងពីឆ្នាំ២០១៦ ក្នុងមួយខែម្តង មាននិស្សិតប្រមាណជាងមួយរយនាក់ដែលសិក្សាមុខវិជ្ជា និងប្រវត្តិសាវតារប្លែកៗគ្នាបានចូលរួមយ៉ាងសកម្មក្នុងគម្រោងសហគមន៍នេះ ដោយមិនរើសអើងថា តើនិស្សិតទាំងនោះមានសាច់ញាតិធ្លាប់ជាជនរងគ្រោះ ឬក៏អ្នកធ្លាប់បម្រើការក្នុងជំនាន់ខ្មែរក្រហមឡើយ ។

នៅខែតុលានេះខ្ញុំបាទមានឱកាសរៀបចំដំណើរទស្សនកិច្ចនិស្សិតចំនួន១៥នាក់ ទៅកាន់ស្រុកអន្លង់វែង ។ គោលបំណងនៃទស្សនកិច្ចនេះ គឺដើម្បីសិក្សាពីបរិបទសន្តិភាពតាមរយៈការពិភាក្សាពីវិធីណាដែលអាចធ្វើបានសម្រាប់ការលើកស្ទួយសន្តិភាព ។ លទ្ធផលផ្អែកលើការពិភាក្សានេះមានប្រធានបទរួមពីរគឺ ៖ មានតែតាមរយៈ “ប្រជាជន” និង “ការអប់រំ” ប៉ុណ្ណោះដែលអាចធានាបាននូវសន្តិភាព និងសម្រេចបាននូវស្ថិរភាពនៅប្រទេសកម្ពុជាបច្ចុប្បន្ន ។

លើសពីនេះ និស្សិតទាំងឡាយក៏បានលើកឡើងពីកត្តាសំខាន់ៗដទៃទៀត ។ ក្នុងនោះ មាននិស្សិតមួយចំនួនជឿថាថ្នាក់ដឹកនាំក៏ដើរតួជាកត្តាចប្បងមួយដែរ ។ បើពិចារណាលើចំណុចនេះសន្តិភាពរឹងមាំ ឬក៏ទន់ខ្សោយគឺអាស្រ័យលើឆន្ទៈ ការប្តេជ្ញាប្រព្រឹត្ត និងប្រយោជន៍ ។ ស្រដៀងគ្នានេះ និស្សិតដទៃទៀតជឿជាក់ថា នីតិរដ្ឋគឺជាចំណុចគោលសំខាន់នៃសន្តិភាព ដោយបាននិយាយសង្កត់ធ្ងន់ថាបុគ្គលម្នាក់ៗសមនឹងទទួលបានការគោរពសិទ្ធិស្មើៗគ្នាក្រោមការគាំពារពីច្បាប់ ព្រមទាំងលើកឡើងថាប្រព័ន្ធយុត្តិធម៌ដែលអាចជឿទុកចិត្តបានអាចនឹងជួយកាត់បន្ថយភាពចលាចលក្នុងសង្គម ។ ជាទីបញ្ចប់ ក្រុមនិស្សិតបានឲ្យតម្លៃទៅលើព័ត៌មានដែលដើរតួយ៉ាងធំធេងក្នុងការការពារសន្តិភាព ប៉ុន្តែមិនបានលើកឡើងពីចំណុចអវិជ្ជមានមួយចំនួននៃព័ត៌មាននោះទេ ។

និស្សិតទាំងអស់បានផ្តល់អនុសាសន៍រួមមួយចំនួនដែលក្នុងនោះមានរាប់ចាប់តាំងពីការកសាងទំនុកចិត្ត និងការយោគយល់គ្នាទៅវិញទៅមក រហូតដល់ការលើកកម្ពស់ភាពអធ្យាស្រ័យគ្នា ការគាំទ្រឲ្យមានបរិយាកាសមួយដែលគ្មានភាពជ្រុលនិយម និងការលើកស្ទួយស្មារតីសាមគ្គីភាព ។ បន្ថែមពីនេះ ក្រុមនិស្សិតក៏បានគូសបញ្ជាក់ពីសារសំខាន់នៃការបំផុសឲ្យមានការដោះស្រាយដោយសន្តិវិធីក្នុងករណីតានតឹងនៃជម្លោះ ឬការខ្វែងគំនិតគ្នា ក៏ដូចជាការលើកកម្ពស់សិទ្ធិមនុស្ស និងបទដ្ឋានសេដ្ឋកិច្ចសង្គម និងការអភិវឌ្ឍសម្រាប់ប្រជាជនទាំងមូល ។

ទោះបីជាការលើកកម្ពស់ និងការបន្តស្វែងរកសន្តិភាពនៅថ្នាក់ដឹកនាំពិតជាមានសារសំខាន់ខ្លាំងសម្រាប់សន្តិភាពទូលំទូលាយរបស់កម្ពុជាក៏ដោយ ការបំផុសយុវជនឲ្យចូលរួមនៅថ្នាក់មូលដ្ឋានគឺមានសារសំខាន់ជាយុទ្ធសាស្ត្រ ។ ទស្សនកិច្ចសិក្សាស្តីពីសន្តិភាព និងសិទ្ធិមនុស្សនៅតំបន់អន្លង់វែងមានសក្តានុពលក្នុងការផ្តល់ឱកាសដល់យុវជនកម្ពុជាក្នុងការធានាថាសន្តិភាពនៅកម្ពុជានឹងត្រូវបានប្រជាជនទាំងអស់ខ្មែរចូលរួមការពារនាពេលបច្ចុប្បន្ន និងអនាគតដ៏យូរអង្វែងតទៅ ។

**លី សុខឃាង**



ទិដ្ឋភាពស្រុកអន្លង់វែងមើលពីលើភ្នំដងរែក

# ទស្សនកិច្ចសិក្សារបស់សិស្សនិស្សិត នៅមជ្ឈមណ្ឌលស









# ន្តិភាពអន្លង់វែង ពីថ្ងៃទី១៨-២១ ខែតុលា ឆ្នាំ២០១៧











# ស៊ឹម ស៊ីលេណា សេ.អ៊ី.អា មកពីអាមេរិក ជាប់ឃុំឃាំងនៅមន្ទីរស-២១

*ដកស្រង់ចេញពីឯកសារលេខ D៤១២៨៥*

ស៊ឹម ស៊ីលេណា គឺជាអ្នកទោសជាប់ឃុំឃាំងនៅមន្ទីរស-២១ ដែលខ្មែរក្រហមបានចោទប្រកាន់ថា ជាភ្នាក់ងារ សេ.អ៊ី.អា មកពីប្រទេសអាមេរិក ។ ស៊ីលេណា បានមកដល់ប្រទេសកម្ពុជា នៅថ្ងៃទី២៨ ខែឧសភា ឆ្នាំ១៩៧៦ ។ ស៊ីលេណា និងមិត្តភ័ក្តិម្នាក់ទៀត ត្រូវបានប្រជាជននៅភូមិដីឥដ្ឋចាប់ខ្លួនបាន នៅថ្ងៃទី១៨ ខែកញ្ញា ឆ្នាំ១៩៧៦ នៅពេលកំពុងគេចខ្លួនបម្រុងរត់ទៅប្រទេសវៀតណាម ។ អ្នកភូមិបាននាំខ្លួនអ្នកទាំងពីរទៅប្រគល់ឲ្យអង្គការ វេលាម៉ោង៦ល្ងាច ។ អង្គការបានឃុំខ្លួនអ្នកទាំងពីរនៅស្រុកកៀនស្វាយមួយយប់ បន្ទាប់មកទើបបញ្ជូនអ្នកទាំងពីរបន្តទៅភ្នំពេញ (មន្ទីរស-២១) នៅថ្ងៃទី២០ ខែកញ្ញា ឆ្នាំ១៩៧៦ ។ ចម្លើយសារភាពរបស់ ស៊ីលេណា ចែកចេញជាច្រើនផ្នែក ។ សន្លឹកឯកសារខ្លះសរសេរដោយដៃ និងខ្លះទៀតបានវាយជាអក្សរអង្គុលីលេខ សរុបទាំងអស់មានចំនួន១៦១ទំព័រ ។ យើងមិនដឹងថា ចម្លើយដែល ស៊ីលេណា បានឆ្លើយទាំងនេះពិតប្រាកដណានោះទេ ។ ខាងក្រោមនេះ ជាការដកស្រង់សេចក្តីចេញពីចម្លើយសារភាពរបស់ ស៊ឹម ស៊ីលេណា ៖



កងចល័តនៅស្រុកកៀនស្វាយ កំពុងជញ្ជូនស្នោ រៀបចំដីសម្រាប់ស្ទូងស្រូវប្រាំង ឲ្យបានស្អាត និងកំពុងវាយសម្រុកស្ទូងស្រូវប្រាំង នៅការដ្ឋានស្រែអំពិល ។

## សេ.អុី.អា ក្លែងភេទធ្វើសកម្មភាពក្នុងបដិវត្តន៍កម្ពុជា

មុនពេលដែលខ្ញុំបានទទួលបេសកកម្មឲ្យមកធ្វើសកម្មភាពបំបះបំបោរនៅក្នុងប្រទេសកម្ពុជាដើម្បីវាយប្រហារដណ្តើមរដ្ឋអំណាចពីបដិវត្តន៍កម្ពុជាវិញនៅថ្ងៃទី២០ ខែមេសា ឆ្នាំ១៩៧៥ គឺខ្ញុំបានចាប់ផ្តើមធ្វើសកម្មភាព ដើម្បីបន្លំខ្លួនតាំងពីនៅសហរដ្ឋអាមេរិកមកម្ល៉េះ ។ នៅក្នុងសាលា ខ្ញុំបានប្រាប់កម្មសិក្សាការីដែលសុំត្រឡប់មកស្រុកជាមួយគ្នាថា ខ្ញុំសុំត្រឡប់មកនេះគឺដោយសារស្នេហាជាតិ ចង់មករួមចំណែកក្នុងការកសាង និងការពារប្រទេស រហូតដល់កម្មសិក្សាការីទាំងនោះជ្រើសខ្ញុំឲ្យធ្វើប្រធានក្រុម ដើម្បីរកមធ្យោបាយចូលស្រុក ។ លុះចេញពីសាលាទៅនៅជំរំ ការបន្លំបន្លប់ខ្លួនរបស់ខ្ញុំរឹតតែប្រសើរឡើងថែមទៀត ដោយខ្ញុំបានលើកមកនិយាយ ទោះនៅក្នុងក្រុមតូចក្តី ក្រុមធំក្តី តែពីស្នេហាជាតិ កសាងជាតិ ការពារជាតិ និងខិតខំកសាងខ្លួនឲ្យបានស្អាតដើម្បីនឹងទទួលយកគោលជំហរបដិវត្តន៍ថ្មី ហើយបានធ្វើការប្រឆាំងនឹងការឃោសនាសម្លុយពីប្រទេសកម្ពុជា ពីសំណាក់ជនក្បែសខ្លួន និងពីអាមេរិក ។ លុះពេលខ្ញុំត្រឡប់មកស្នាក់នៅប្រទេសបារាំងវិញ ខ្ញុំក៏បានចូលជាសមាជិកនៃរណសិរ្សរួបរួមជាតិកម្ពុជាប្រចាំនៅប្រទេសបារាំងក្នុងគោលបំណងក្លែងខ្លួនជាអ្នកបដិវត្តន៍ដោយបម្រើនយោបាយក្រៅប្រទេសរបស់អង្គការបដិវត្តន៍កម្ពុជាធ្វើយ៉ាងណាឲ្យអង្គការមានជំនឿមកលើខ្ញុំថា ខ្ញុំស្មោះត្រង់ចំពោះអង្គការដើម្បីឲ្យអង្គការចាត់តាំងខ្ញុំឲ្យត្រឡប់មកស្រុកវិញក្នុងពេលឆាប់ៗ ។ គោលបំណងរបស់ខ្ញុំក៏បានសម្រេចមែន ដោយអង្គការបានចាត់តាំងខ្ញុំឲ្យត្រឡប់ចូលមកប្រទេសនៅថ្ងៃទី២៥ ខែឧសភា ឆ្នាំ១៩៧៦ ។ មកដល់ភ្នំពេញ អង្គការបានចាត់តាំងខ្ញុំឲ្យធ្វើការងារពលកម្មជាមួយអ្នកដែលត្រឡប់មកពីបរទេសទាំងអស់ និងបានចូលរៀនចប់សព្វគ្រប់នៅវគ្គសិក្សាទី១ទៀតផង ។ រយៈពេលដែលខ្ញុំនៅមន្ទីរភ្នំពេញ ខ្ញុំបានសម្របខ្លួនតាមសមូហភាពជានិច្ចគ្រប់បញ្ហាទាំងអស់ តាំងពីបញ្ហាហូប សម្រាក ធ្វើការងារពលកម្មបញ្ហាសីលធម៌ ការរៀនសូត្រពីឯកសារបដិវត្តន៍ ទោះនៅក្នុងអង្គប្រជុំក្តី ក្នុងពេលធ្វើការងារក្តី ពេលសម្រាកក្តី និងពេលខ្ញុំមិនសូវមានសុខភាពល្អក្តី ខ្ញុំក៏នៅតែខិតខំជានិច្ច មិនឲ្យសមូហភាពចាប់អារម្មណ៍ឡើយ ។ ប៉ុន្តែជាមួយគ្នានេះ ខ្ញុំបានលបលួចជួបគ្នាជាស្ងាត់កំបាំងជាមួយ ដួង ដាញ់ និង ហ៊ុល តាប មិនឲ្យសមូហភាពចាប់អារម្មណ៍ឡើយ ។ លុះដល់ថ្ងៃទី១៧ ខែកក្កដា ឆ្នាំ១៩៧៦ អង្គការបានចាត់តាំងឲ្យខ្ញុំមកនៅភូមិតាលៃ ។ ទៅដល់ភូមិតាលៃ ខ្ញុំបានខិតខំធ្វើការងារបានមួយកម្រិតទៀត ដើម្បីកុំឲ្យសមូហភាពចាប់អារម្មណ៍មកលើខ្ញុំ ប៉ុន្តែការណ៍ដែលខ្ញុំជួបជាមួយ សូភត្រា មិនកំបាំងនឹងភ្នែករបស់សមូហភាពឡើយ ។ ការបន្លំខ្លួនរបៀបនេះនៅក្នុងសមូហភាព មិនអាចឲ្យខ្ញុំធ្វើសកម្មភាពបានតាមចិត្ត និងតាមគម្រោងផែនការទេ ទោះជានៅយូរតទៅទៀតក៏ដោយ ។ ដូច្នេះ ដួង ដាញ់ ក៏បានរៀបចំចាត់ឲ្យខ្ញុំត្រៀមខ្លួនចេញទៅស្រុកយួនជាបន្ទាន់ ។ ថ្ងៃទី១០ ខែតុលា ឆ្នាំ១៩៧៦ អង្គការបានចាត់តាំងឲ្យខ្ញុំទៅធ្វើការនៅព្រែកប្រា ។ ពេលនោះ ខ្ញុំធ្វើការជាធម្មតា ហើយឆ្លៀតសង្កេតរកច្រក និងរកឱកាសចាកចេញចាប់តាំងពីខ្ញុំបានទៅដល់ព្រែកប្រា ។ ខ្ញុំបានសម្រេចចេញដំណើរឆ្ពោះទៅស្រុកយួននៅម៉ោងមួយភ្លឺថ្ងៃទី១៨ ខែសីហា ឆ្នាំ១៩៧៦ ដើម្បីទៅរាយការណ៍ឲ្យ ហ្សាក់ មីលីគុន និងទីបញ្ជាការ សេ.អុី.អា នៅក្រុងវ៉ាស៊ីនតោន តាមរយៈភ្នាក់ងារ សេ.អុី.អា អាមេរិកបន្លំខ្លួនធ្វើការនៅអង្គការមនុស្សធម៌ និងកាកបាទក្រហមអន្តរជាតិដែលធ្វើការនៅស្រុកយួន ។

ហ្សាក់មីលីគុន ដែល ស៊ីលេណា ទាក់ទង គឺជាជនជាតិអាមេរិក មានអាយុប្រហែលជាង៣៥ឆ្នាំ ជាភ្នាក់ងារតំណាងក្រសួងការបរទេសអាមេរិក ទទួលបន្ទុកមើលការខុសត្រូវបញ្ហាប្រទេសកម្ពុជា ។ ហ្សាក់ មីលីគុន ជាតំណាងក្រសួងការបរទេសអាមេរិក ក្នុងការរៀបចំផែនការជាមួយទីបញ្ជាការ សេ.អុី.អា និងទទួលខុសត្រូវក្នុងការចាត់វិធានការ ដើម្បីអនុវត្តផែនការ និងទទួលសេចក្តីរាយការណ៍ទៅពិនិត្យជាមួយទីបញ្ជាការ សេ.អុី.អា ដើម្បីសម្រេច ឬរៀបចំផ្លាស់ប្តូរផែនការ ។

មីលីគុន ធ្លាប់បានមកធ្វើការនៅក្នុងប្រទេសកម្ពុជាពីឆ្នាំ១៩៧២ ដល់ឆ្នាំ១៩៧៥ នៅស្ថានទូតអាមេរិកនៅក្រុងភ្នំពេញ ។ មីលីគុន ក៏ធ្លាប់បានធ្វើការនៅក្នុងស្រុកយួន និងស្រុកសៀមដែរ និងជាអ្នកជំនាញការនៅក្នុងភូមិភាគឥណ្ឌូចិន ។ ខាងក្រោមគឺជាការរៀបរាប់អំពីឈ្មោះ និងប្រវត្តិសកម្មភាពខ្សែ សេ.អុី.អា មួយចំនួនរបស់ មីលីគុន ដែល មីលីគុន បានឲ្យទៅ ស៊ីលេណា ដើម្បីធ្វើ

ការទាក់ទងជាមួយ ៖

**១) កុយ ធុច**

កុយ ធុច ជាជនជាតិខ្មែរ មានអាយុជាង៣៧ឆ្នាំ មានដើមកំណើតនៅក្រុងភ្នំពេញ បានចូលធ្វើជា សេ.អ៊ី.អា នៅឆ្នាំ១៩៥៤ ដើម្បីធ្វើវិទ្ធង្សនានៅក្នុងប្រទេសកម្ពុជា បម្រើនយោបាយឲ្យលោកសេរី ។ កុយ ធុច បានធ្វើជាអ្នកបើកបររថយន្តឲ្យស្ថានទូតអាមេរិក រហូតដល់ពេលរាជរដ្ឋាភិបាលសម្តេច សីហនុ បិទស្ថានទូតអាមេរិកចោល ។ បន្ទាប់មក កុយ ធុច ក៏ដើរស៊ីឈ្នួលបើកបររថយន្តតូច-ធំ រហូតក្រោយរដ្ឋប្រហារឆ្នាំ១៩៧០ ទើបស្ថានទូតអាមេរិកបើកសាជាថ្មី នៅក្រុងភ្នំពេញ ។ ពេលនោះ កុយ ធុច ក៏បានត្រឡប់ចូលទៅធ្វើជាអ្នកបើកបររថយន្តក្នុងស្ថានទូតអាមេរិកវិញម្តងទៀត ។ លុះដល់ឆ្នាំ១៩៧៣ អាមេរិក បានបញ្ជូន កុយ ធុច ឲ្យទៅបង្កប់ខ្លួនក្នុងកងទ័ពបដិវត្តន៍ មានបេសកកម្មពិសេស គឺត្រៀមខ្លួនធ្វើសកម្មភាពតាមផែនការថ្មីរបស់អាមេរិកមកលើកម្ពុជា ដើម្បីដណ្តើមអំណាចពីអង្គការបដិវត្តន៍កម្ពុជា ក្រោយពីខ្លួនបានចាញ់សង្គ្រាមហើយ ។ កុយ ធុច នេះ ជាយុទ្ធជននៅភ្នំពេញ ហើយក៏ជាមេ សេ.អ៊ី.អា នៃក្រុមដែលអាមរិកតាំងបង្កប់ត្រៀមទុក ។

**២) កែវ អុន**

កែវ អុន ជាជនជាតិខ្មែរ មានអាយុជាង៣៧ឆ្នាំ កើតនៅភ្នំពេញ បានចូល សេ.អ៊ី.អា នៅឆ្នាំ១៩៥៥ ។ រយៈពេលមុនរដ្ឋប្រហារ អុន មានបេសកកម្មជាអ្នកធ្វើវិទ្ធង្សនាប្រឆាំងរបបកម្ពុជាឯករាជ្យ បម្រើនយោបាយលោកសេរី ។ អុន បានចូលធ្វើជាកម្មករក្នុងការិយាល័យនៃស្ថានទូតអាមេរិក រហូតដល់ស្ថានទូតនេះត្រូវបិទទ្វារ ។ ពេលនោះ អុន ក៏បានធ្វើជាកម្មករក្នុងការិយាល័យរបស់ក្រុមហ៊ុនឯកជនផ្សេងៗក្នុងក្រុងភ្នំពេញ រហូតដល់ក្រោយរដ្ឋប្រហារឆ្នាំ១៩៧០ ក៏បានចូលធ្វើការជាកម្មករនៅស្ថានទូតអាមេរិកនៅទីក្រុងភ្នំពេញវិញ ។ លុះដល់ឆ្នាំ១៩៧៣ មេ សេ.អ៊ី.អា អាមេរិកនៅក្រុងភ្នំពេញបានចាត់ឲ្យចូលទៅបង្កប់ខ្លួនក្នុងកងទ័ពបដិវត្តន៍ ដោយបំពេញបេសកកម្មតាមផែនការថ្មីរបស់អាមេរិក ត្រៀមវាយដណ្តើមរដ្ឋអំណាចពីអង្គការបដិវត្តន៍វិញ បន្ទាប់ពីចាញ់សង្គ្រាម ។ អុន ជាមេ សេ.អ៊ី.អា ទីពីរបន្ទាប់ពី កុយ ធុច នៃក្រុមដែលអាមេរិកបានបង្កប់ សម្រាប់វាយប្រហារអង្គការបដិវត្តន៍កម្ពុជា ។ សព្វថ្ងៃនេះ អុន ជាយុទ្ធជននៅក្នុងក្រុងភ្នំពេញ ។

**៣) ថាច**

ថាច គឺជាជនជាតិខ្មែរ មានអាយុប្រហែល៣០ឆ្នាំ មានដើមកំណើតនៅកម្ពុជាក្រោម បានចូលមកនៅក្រុងភ្នំពេញតាំងពីក្មេង និងបានចូលធ្វើជា សេ.អ៊ី.អា នៅឆ្នាំ១៩៦៥ មានបេសកកម្មធ្វើវិទ្ធង្សនាប្រឆាំងនឹងនយោបាយឯករាជ្យ មិនចូលបក្សសម្ព័ន្ធរបស់កម្ពុជា ដើម្បីបម្រើនយោបាយលោកសេរី រហូតដល់ថ្ងៃរដ្ឋប្រហារឆ្នាំ១៩៧០ ។ ពីឆ្នាំ១៩៧០-១៩៧២ ថាច ធ្វើជាអ្នកស៊ើបរកសកម្មភាពខ្មាំងនៅក្នុងក្រុងភ្នំពេញ ឬជនដែលក្បត់របបសាធារណរដ្ឋរបស់ លន់ នល់ ។ នាឆ្នាំ១៩៧២ មេ សេ.អ៊ី.អា អាមេរិកនៅក្រុងភ្នំពេញ បានបញ្ជាឲ្យ ថាច បន្លំខ្លួនចូលទៅបង្កប់នៅក្នុងកងទ័ពបដិវត្តន៍ ត្រៀមខ្លួនដើម្បីបំពេញបេសកកម្ម និងផែនការថ្មីរបស់អាមេរិក ដើម្បីវាយកងទ័ពបដិវត្តន៍កម្ពុជាជាថ្មី បន្ទាប់ពីខ្លួនចាញ់សង្គ្រាម ។ ថាច មានឋានៈជាមេកងរយ នៅក្នុងខេត្តបាត់ដំបង ។

**៤) ដាវ**

ដាវ ជាជាជាតិខ្មែរ មានអាយុប្រហែល៣០ឆ្នាំ និងមានដើមកំណើតនៅកម្ពុជាក្រោម បានចូលធ្វើជា សេ.អ៊ី.អា នៅក្រុងភ្នំពេញនៅឆ្នាំ១៩៦៥ ដោយប្រកបរបរជាអ្នកជួសជុលរថយន្តនៅក្រុងភ្នំពេញ ។ ដាវ មានភារកិច្ចជាអ្នកធ្វើវិទ្ធង្សនាប្រឆាំងរបបឯករាជ្យ មិនចូលបក្សសម្ព័ន្ធរបស់កម្ពុជា ឲ្យមហាជនមាននិន្នាការរបបលោកសេរី ។ បេសកកម្មនេះ ត្រូវបានបញ្ចប់នៅនៅថ្ងៃរដ្ឋប្រហារឆ្នាំ១៩៧០ ។ ចាប់ពីឆ្នាំ១៩៧០-១៩៧២ ដាវ មានភារកិច្ចស៊ើបអង្កេតសកម្មភាពខ្មាំងនៅក្រុងភ្នំពេញ និងពួកក្បត់សាធារណរដ្ឋរបស់ លន់ នល់ ។ លុះដល់ឆ្នាំ១៩៧២ មេ សេ.អ៊ី.អា អាមេរិកប្រចាំប្រទេសកម្ពុជា បានដាក់បេសកកម្មឲ្យ ដាវ បង្កប់ខ្លួននៅក្នុងកងទ័ពបដិវត្តន៍ និងត្រៀមបំពេញផែនការថ្មីរបស់អាមេរិក ដើម្បីវាយប្រហារអង្គការបដិវត្តន៍កម្ពុជា ដណ្តើមរដ្ឋអំណាចមកវិញក្រោយពីខ្លួនបានចាញ់សង្គ្រាម ។ សព្វថ្ងៃនេះ ដាវ នៅខេត្តពោធិ៍សាត់ មានមុខងារជាមេកងរយ ។

**៥) ពូន**

ពូន ជាជនជាតិខ្មែរ មានអាយុប្រហែលជា៣០ឆ្នាំ មានដើមកំណើតនៅកម្ពុជាក្រោម បានចូលធ្វើជា សេ.អ៊ី.អា នៅឆ្នាំ

១៩៦៥ នៅក្រុងភ្នំពេញ តាមរយៈក្រុមខ្មែរសេរី ។ ពូន មានមុខរបរជាកម្មករធាក់ស៊ីក្លូ ជាអ្នកបម្រើនៅក្នុងភោជនីយដ្ឋាន និងលក់ការ៉េមតាមផ្លូវ ។ ពូន មានបេសកកម្ម ស៊ើបការណ៍អំពីសកម្មភាពរបស់រាជរដ្ឋាភិបាលកម្ពុជាជំនាន់នោះដែលប្រឆាំងនឹងខ្មែរសេរីបង្កប់នៅក្រុងភ្នំពេញ និងធ្វើវិទ្ធង្សនាផ្នែកនយោបាយនៅក្នុងសង្គមឲ្យលម្អៀងទៅខាងលោកសេរី ។ ពូន ធ្វើកិច្ចការនេះរហូតដល់ថ្ងៃរដ្ឋប្រហារឆ្នាំ១៩៧០ ។ ក្រោយមក មេ សេ.អ៊ី.អា អាមេរិកបានចាត់ឲ្យ ពូន ធ្វើជាអ្នកស៊ើបតាមសកម្មភាពខ្មាំងនៅទីក្រុងភ្នំពេញ ឬសកម្មភាពអ្វីដែលប្រឆាំងនឹងនយោបាយអាមេរិកដល់ឆ្នាំ១៩៧២ ។ នៅឆ្នាំ១៩៧២ មេ សេ.អ៊ី.អា នៅក្រុងភ្នំពេញបានឲ្យ ពូន ទៅបង្កប់ខ្លួនធ្វើការនៅក្នុងកងទ័ពបដិវត្តន៍កម្ពុជា ដើម្បីត្រៀមចាំធ្វើសកម្មភាពទៅតាមផែនការថ្មីរបស់អាមេរិកបន្ទាប់ពីវាចាញ់សង្គ្រាម វានឹងវាយប្រហារដណ្តើមរដ្ឋអំណាចពីអង្គការបដិវត្តន៍ម្តងទៀត ។ ពូន សព្វថ្ងៃជាមេកងរយនៅខេត្តកំពង់ឆ្នាំង ។

## ៦) ច័ន្ទ

ច័ន្ទ ជាជនជាតិខ្មែរ មានអាយុជាង៣០ឆ្នាំ មានដើមកំណើតនៅខេត្តកំពង់ស្ពឺ ។ ច័ន្ទ ធ្លាប់ធ្វើជាកម្មករនៅក្នុងស្ថានទូតអាមេរិកនៅក្រុងភ្នំពេញនៅឆ្នាំ១៩៦២ រហូតដល់ស្ថានទូតនេះបិទទ្វារ ។ ច័ន្ទ បានចូលធ្វើជា សេ.អ៊ី.អា នៅឆ្នាំ១៩៦៥ ធ្វើការឲ្យក្រុមខ្មែរសេរី ។ ច័ន្ទ បានបង្កប់ខ្លួននៅក្នុងក្រុងភ្នំពេញរហូតដល់រដ្ឋប្រហារឆ្នាំ១៩៧០ ដោយមានភារកិច្ចស៊ើប តាមដានសកម្មភាពណាដែលប្រឆាំងនឹងក្រុមខ្មែរសេរី និងធ្វើវិទ្ធង្សនានយោបាយក្នុងសង្គមឲ្យងាកទៅខាងរបបលោកសេរីវិញ ។ ក្នុងរយៈពេលនេះ ច័ន្ទ មានមុខរបរមិនជាប់លាប់ទេ គឺផ្លាស់ប្តូរពីកន្លែងមួយទៅកន្លែងមួយទៀតក្នុងក្រុងភ្នំពេញ ។ ក្រោយថ្ងៃរដ្ឋប្រហារ មុខរបររបស់ ច័ន្ទ នៅដដែល ប៉ុន្តែអាមេរិកបានឲ្យ ច័ន្ទ ធ្វើសកម្មភាពថ្មី គឺធ្វើជាអ្នកយកការណ៍ និងតាមដានសកម្មភាពខ្មាំងនៅក្នុងក្រុងភ្នំពេញ និងអំពីសកម្មភាពនៅក្នុងរដ្ឋាភិបាល លន់ នល់ ឲ្យតែប្រឆាំងនឹងអាមេរិក ។ លុះដល់ឆ្នាំ១៩៧២ អាមេរិកបានឲ្យ ច័ន្ទ គឺចូលបន្ទំខ្លួនក្នុងកងទ័ពបដិវត្តន៍ ដើម្បីត្រៀមធ្វើសកម្មភាពទៅតាមផែនការអាមេរិកចូលមកវាយអង្គការបដិវត្តន៍កម្ពុជាម្តងទៀតក្រោយពេលចាញ់សង្គ្រាម ។ សព្វថ្ងៃ ច័ន្ទ មានមុខងាររជាមេកងរយនៅក្នុងខេត្តកំពង់ស្ពឺ ។

## ៧) ម៉ី

ម៉ី មានអាយុ៣០ឆ្នាំ ជនជាតិខ្មែរ មានដើមកំណើតនៅខេត្តកំពត ។ ម៉ី ធ្លាប់ធ្វើជាកម្មករនៅស្ថានទូតអាមេរិកនៅក្រុងភ្នំពេញរហូតដល់ស្ថានទូតនេះ ត្រូវបានរាជរដ្ឋាភិបាលរបស់សម្តេច សីហនុ បិទទ្វារ ។ ម៉ី បានចូលធ្វើជា សេ.អ៊ី.អា នៅក្រុងភ្នំពេញក្នុងឆ្នាំ១៩៦៥ និងមានបេសកកម្មតាមដានសកម្មភាពរបស់រាជរដ្ឋាភិបាលសម្តេច សីហនុ ដែលប្រឆាំងនឹងក្រុមខ្មែរសេរីដែលបង្កប់ក្នុងក្រុងភ្នំពេញ និងធ្វើសកម្មភាពនយោបាយប្រឆាំងនយោបាយឯករាជ្យមិនចូលបក្សសម្ព័ន្ធរបស់កម្ពុជា ។ ក្នុងរយៈពេលពីឆ្នាំ១៩៦៥-១៩៧០ ម៉ី មានមុខរបរជាកម្មករធាក់ស៊ីក្លូ កម្មករសង់ផ្ទះ លក់ដូរបន្តិចបន្តួចតាមផ្សារ និងតាមចំណតរថយន្តឈ្នួល ។ បន្ទាប់ពីរដ្ឋប្រហារឆ្នាំ១៩៧០ ម៉ី នៅតែមានមុខរបរមិនទៀងទាត់ដដែល គឺ ម៉ី បានចូលធ្វើទាហាន និងមានបេសកកម្មស៊ើបរកខ្មាំងដែលបង្កប់នៅក្រុងភ្នំពេញ និងសកម្មភាពដែលប្រឆាំងនឹងនយោបាយរបស់អាមេរិក ហើយក្រោយមក ម៉ី ក៏ឈប់ធ្វើទាហាន ។ ឆ្នាំ១៩៧២ មេ សេ.អ៊ី.អា អាមេរិកនៅភ្នំពេញ បានបញ្ជា ម៉ី ឲ្យទៅបង្កប់ខ្លួននៅក្នុងកងទ័ពបដិវត្តន៍ ត្រៀមចាំអនុវត្តផែនការថ្មីរបស់អាមេរិក ដើម្បីវាយប្រហារអង្គការបិដវត្តន៍កម្ពុជាក្រោយពីខ្លួនចាញ់សង្គ្រាម ។ សព្វថ្ងៃ ម៉ី មាននាទីជាមេកងរយនៅក្នុងខេត្តកំពត ។

## ៨) ហ៊ុល តាប

ហ៊ុល តាប ជាជនជាតិខ្មែរ មានអាយុប្រហែល៣៧ឆ្នាំ និងមានដើមកំណើតនៅភ្នំពេញ ។ តាប ធ្វើជាកម្មកររថភ្លើងនៅភ្នំពេញតាំងពីមុនរដ្ឋប្រហារឆ្នាំ១៩៧០ ។ ក្រោយរដ្ឋប្រហារ តាប នៅធ្វើជាកម្មកររថភ្លើងដដែល ។ តាប ចូលធ្វើ សេ.អ៊ី.អា នៅភ្នំពេញក្នុងឆ្នាំ១៩៧០ ដោយមានភារកិច្ចស៊ើបយកការណ៍អំពីសកម្មភាពខ្មាំង និងស៊ើបរកអ្នកប្រឆាំងនឹងនយោបាយរបស់អាមេរិក ។ លុះដល់ថ្ងៃ១៧ ខែមេសា ឆ្នាំ១៩៧៥ ក្រោយពីរំដោះបានទីក្រុងភ្នំពេញ អង្គការបានជម្លៀសប្រជាជនចេញពីភ្នំពេញទាំងអស់ ហើយ តាប ក៏ត្រូវចេញទៅជនបទដែរ ។ រយៈពេលប៉ុន្មានខែក្រោយមក អង្គការបានប្រមូលកម្មកររថភ្លើងចាស់ឲ្យមកធ្វើការ

នៅក្រុមរថភ្លើងវិញ ហើយ តាប ក៏ត្រូវបានចាត់តាំងឲ្យធ្វើការក្នុងក្រុមដឹកជញ្ជូន រៀបចំអីវ៉ាន់ឡើងចុះតាមផ្លូវរថភ្លើងភ្នំពេញ-កំពង់សោម-បាត់ដំបង ។ ក្រោយពេលមកដល់ភ្នំពេញបានមួយអាទិត្យ ខ្ញុំ (ស៊ីលេណា) បានទាក់ទងជាមួយ ភួង ដាញ់ ហើយបានទទួលការណែនាំឲ្យមកទាក់ទងជាមួយ ហ៊ុល តាប ដែលជាខ្មែរ សេ.អ៊ី.អា ចាស់របស់ ហ្សាក់ មីលីគុន ដើម្បីស៊ើបសួរអំពីស្ថានការនៅតាមជនបទ និងជាពិសេស ដើម្បីឲ្យជួយស៊ើបរកទាក់ទងឈ្មោះដែលខ្ញុំត្រូវប្រគល់បេសកកម្ម និងផែនការថ្មីរបស់អាមេរិកឲ្យដើម្បីវាយបដិវត្តន៍កម្ពុជាជាថ្មី ដែលមានឈ្មោះ កុយ ធុច និង កែវ អុន ជាមេក្រុម សេ.អ៊ី.អា ដែលអាមេរិកឲ្យបង្កប់ខ្លួនក្នុងកងទ័ពបដិវត្តន៍ និងឈ្មោះ ថាច, ដាវ, ពូន, ច័ន្ទ និង ម៉ី ដែលអាមេរិកបានឲ្យមកត្រៀមវាយបដិវត្តន៍កម្ពុជា ។ ហ្សាក់ មីលីគុន ក៏បានឲ្យខ្ញុំធ្វើសកម្មភាពជាមួយអ្នកទាំងនេះ ។ ប្រហែលមួយសប្ដាហ៍ក្រោយមក ខ្ញុំបានជួប តាប នៅតាមផ្លូវរថភ្លើង ខាងក្រោយមន្ទីរអប់រំភ្នំពេញ វេលាម៉ោងមួយរសៀល ។ ពេលជួបគ្នាដំបូង តាប មិនស្គាល់ខ្ញុំទេ គឺខ្ញុំបានចាប់ផ្ដើមមុនដោយបាននិយាយថា "អាមេរិកជាមិត្តនឹងខ្មែរ ប៉ុន្តែការពិតវាជាសត្រូវ" និងនិយាយបន្ថែមខ្លះពីដំណើរដែលខ្ញុំទើបមកពីអាមេរិក ដើម្បីបញ្ជាក់ឲ្យគាត់ទុកចិត្ត រួចខ្ញុំបានស្នើឲ្យគាត់រាយការណ៍អំពីព្រឹត្តិការណ៍សំខាន់ក្រោយថ្ងៃ ១៧ មេសា ១៩៧៥ ដែលគាត់បានដឹង ព្រោះទាក់ទងនឹងបេសកកម្មរបស់ខ្ញុំ ហើយគាត់បាននិយាយថា ៖

◆ ចាប់តាំងពីអង្គការបដិវត្តន៍រំដោះភ្នំពេញ និងប្រទេសទាំងមូលភ្លាមៗ មានការកាប់សម្លាប់ច្រើន ពិសេសចំពោះអតីតទាហាន និងអតីតអ្នករដ្ឋការផេតរើសមុខឡើយ ឲ្យតែអង្គការមានការសង្ស័យ និងខ្លះទៀតស្លាប់ដោយសារការអត់ឃ្លាន និងដោយជំងឺផ្សេងៗ ។ល ។

◆ មានទ័ព ស៊ីង ឌឹកថាញ់ នៅកោះត្រល់

◆ មានទ័ពព្រៃបះបោរខ្មែរសេរីប្រឆាំងនឹងអង្គការបដិវត្តន៍កម្ពុជា នៅភូមិភាគឈូងសមុទ្រថៃ ចាប់តាំងពីកំពតរហូតទៅដល់ទល់ដែនខ្មែរ-ថៃ មានចំនួនទ័ពប្រហែលបីម៉ឺននាក់ ដឹកនាំដោយអតីតមេទាហាន លន់ នល់ ។

◆ មានទ័ពព្រៃរបស់ អ៊ិន តាំ នៅតាមជួរភ្នំដងរែក ព្រំដែនខ្មែរ-ថៃ ។

◆ មានការបះបោរនៅក្នុងសហករណ៍កំពង់ត្រាំ ខេត្តកំពង់ស្ពឺ

◆ កម្មកររថភ្លើងមួយចំនួន ក៏មានការមិនពេញចិត្តចំពោះរបបថ្មីរបស់អង្គការបដិវត្តន៍ដែរ ។ គាត់និយាយបានត្រឹមនេះ ក៏ឈប់ព្រោះមានមិត្តនៅក្នុងមន្ទីរដើរទៅធ្វើការកាត់តាមទីនោះ និងដើម្បីកុំឲ្យមានការសង្ស័យ ។ គាត់បានសន្យាថា នឹងលបមកជួបគ្នាទៀតនៅម៉ោងដដែល និងកន្លែងដដែល គឺតាមផ្លូវរថភ្លើង ដោយឲ្យខ្ញុំនៅចាំមើលពីមន្ទីរ ហើយបើឃើញគាត់ដើរមកសឹមចុះមកជួប ។

ចាប់តាំងពីថ្ងៃនោះមក ខ្ញុំបានរង់ចាំជួបគាត់ដើម្បីឲ្យគាត់ជួយធ្វើការ ប៉ុន្តែរយៈពេលជិតមួយខែក្រោយមក ខ្ញុំបានស្កាត់ទៅសួរកម្មកររថភ្លើងម្នាក់ដែលដើរតាមផ្លូវនោះ កម្មករនោះ បានប្រាប់ខ្ញុំថា អង្គការឈប់ឲ្យ តាប ធ្វើការហើយ ។

## ៩) សូ ភត្រា

សូភត្រា ជាជនជាតិខ្មែរ មានអាយុប្រហែលជាង៣៥ឆ្នាំ ទីកន្លែងកំណើតក្ដាប់មិនបាន ។ ភត្រា ចូលធ្វើទាហានខាងបើកយន្តហោះជំនាន់ទី៦ ប៉ុន្តែមិនចាំឆ្នាំ ។ ភត្រា ធ្វើការនៅវាលយន្តហោះពោធិ៍ចិនតុង រហូតដល់ក្រោយរដ្ឋប្រហារឆ្នាំ១៩៧០ គាត់ត្រូវបាននាយសេនាធិការទ័ពអាកាសបញ្ឈប់លែងឲ្យបើកយន្តហោះ ដោយមូលហេតុគាត់មិនគោរពវិន័យហោះហើរ ម៉្យាងទៀតគាត់ជាប់ខ្សែ ស្ដេច នរោត្តម និងមានប្រពន្ធជាកូនស្ដេច សីហនុ ។ នៅចុងឆ្នាំ១៩៧១ គាត់ត្រូវផ្លាស់ទៅធ្វើការនៅវាលយន្តហោះកេងកងក្រុងកំពង់សោម ក្នុងផ្នែកប្រតិបត្តការសឹក តែគាត់មិនបានបើកយន្តហោះទេ ។ នៅពាក់កណ្ដាលឆ្នាំ១៩៧២ គាត់បានផ្លាស់មកភ្នំពេញវិញ ហើយបានចេញពីទ័ពអាកាសទៅចូលក្នុងកងកម្លាំងពិសេស និងបានទៅសិក្សាយុទ្ធសាស្ត្រនៅស្រុកយួនអស់រយៈពេលជាច្រើនខែ ទើបត្រឡប់មកភ្នំពេញវិញ ។ ភត្រា បានចេញចូលមូលដ្ឋានពោធិ៍ចិនតុងញឹកញាប់ ដូចកាលគាត់នៅបម្រើក្នុងកងទ័ពអាកាសដូចពេលមុនដែរ ។ លុះដល់ដើមឆ្នាំ១៩៧៣ គាត់បានលួចយន្តហោះ តេ២៨ មួយគ្រឿងពីពោធិ៍ចិនតុងទៅទម្លាក់គ្រាប់បែកលើចម្ការមន រួចបើកយន្តហោះសំដៅទៅតំបន់រំដោះតែម្ដង ។ ក្រោយមកឮថា គាត់មានមុខងារជានាយសេនាធិ

ការទ័ពអាកាសរបស់កងទ័ពបដិវត្តន៍នៃរាជរដ្ឋាភិបាលរួបរួមជាតិកម្ពុជា ដែលមានតាំងទីបញ្ជាការនៅក្រុងប៉េកាំង ។ ពេលដែលគាត់ទម្លាក់គ្រាប់បែកលើចម្ការមន ហើយភៀសខ្លួនទៅតំបន់រំដោះ គាត់បានពាក់ស័ក្តិ៣ ។

គាត់បានត្រឡប់មកដល់ភ្នំពេញវិញនៅខែធ្នូ ឆ្នាំ១៩៧៥ អង្គការបានចាត់តាំងឲ្យគាត់ធ្វើការងារពលកម្មបន្តរបង្កើនផលនៅមន្ទីរនៅភ្នំពេញ និងនៅភូមិតាលៃរហូតដល់ (ឆ្នាំ១៩៧៦) ។ ខ្ញុំបានទៅដល់ភូមិតាលៃ នៅថ្ងៃទី១៧ ខែកក្កដា ឆ្នាំ១៩៧៦ ។ ខ្ញុំបានទាក់ទង ភួង ដាញ់ ជាថ្មី ហើយបានទទួលការណែនាំឲ្យទៅទាក់ទងជាមួយ សូ ភត្រា ដើម្បីស្ទាបស្ទង់ និងទាក់ទាញឲ្យចូលរួមបំពេញផែនការរបស់អាមេរិក ដើម្បីវាយបដិវត្តន៍កម្ពុជាក្នុងពេលដ៏ខ្លីខាងមុខនេះ ។ មូលហេតុដែលត្រូវទៅទាក់ទង សូ ភត្រា នេះ ភួង ដាញ់ បានណែនាំប្រាប់ខ្ញុំថា ៖

◆ សូ ភត្រា មិនមែនជាអ្នកបដិវត្តន៍ទេ គាត់ចូលក្នុងបដិវត្តន៍ដោយបញ្ហាផ្ទាល់ខ្លួន ។

◆ គាត់មានអត្តចរិតជាអ្នកសេរីរើ មិនសូវចូលចិត្តវិន័យសង្កត់លើគាត់ទេ ។

◆ គាត់ជាប់ខ្សែស្រឡាយគ្រួសារស្តេច ហើយស្តេចនេះជាទំនាស់ធំណាស់ជាមួយបដិវត្តន៍ ហើយស្តេច ក៏ត្រូវបានអង្គការបដិវត្តន៍ដកអំណាចដែរ ។

◆ គាត់ពិតជាអាក់អន់ចិត្តខ្លះចំពោះអង្គការបដិវត្តន៍ ដែលដកគាត់ចេញពីតំណែងយកមកអប់រំ លំបាកវេទនាក្នុងការងារពលកម្ម ដែលគាត់មិនធ្លាប់ធ្វើទាល់តែសោះតាំងពីដើមមក ។

ខ្ញុំបានជួប សូ ភត្រា នៅថ្ងៃទី១៩ ខែកក្កដា ឆ្នាំ១៩៧៦ នៅម៉ោងជាង៤រសៀល នៅក្នុងថ្នាលដកសំណាប ។ ខ្ញុំបានជួបគាត់ក្នុងពេលដែលមិត្តឯទៀតកំពុងធ្វើការ ។ ខ្ញុំ និងគាត់នៅឃ្លាតពីគេឯងល្មមតែនិយាយគ្នាគេស្តាប់មិនឮ ។ ខ្ញុំចាប់ផ្តើមសួរគាត់ពីការងារដែលគាត់បានធ្វើនៅទីនោះ ហើយបន្ទាប់ពីការអប់រំ និងការងារពលកម្ម គាត់ត្រូវទៅធ្វើការនៅកន្លែងណាទៀត ។ ខ្ញុំបានសួរគាត់ពីវាសនារបស់អតីតទាហាន ដែលសុំចូលមកក្នុងប្រទេសកម្ពុជានៅតាមព្រំដែនខ្មែរ-ថៃ និងសួរពីការងាររបស់ខ្ញុំទៅថ្ងៃមុខ បន្ទាប់ទទួលការអប់រំ និងធ្វើការងារពលកម្មនេះ ហើយអាចបានចូលទៅធ្វើការក្នុងកងទ័ពអាកាសបានដែរឬទេ ។ គាត់បាននិយាយប្រាប់ខ្ញុំដូចតទៅ ៖

នៅភូមិតាលៃនេះ កិច្ចការរបស់គាត់មិនច្បាស់លាស់ទេ គឺធ្វើគ្រប់មុខឲ្យតែមាន ។ ពីមុនគាត់ជានាយសេនាធិការកងទ័ពអាកាសបដិវត្តន៍ ហើយបន្ទាប់បានទទួលការអប់រំ និងធ្វើការងារពលកម្មរួច អង្គការឈប់ឲ្យគាត់បើកយន្តហោះ ដោយទុកឲ្យក្មេងៗបើកវិញ ។ ម្យ៉ាងទៀត គាត់មានជំងឺសួត ប្រហែលជាអង្គការមិនចាត់តាំងឲ្យទៅធ្វើការនៅក្នុងការិយាល័យដូចមុនទៀតទេ ។ ចំណែក អតីតទាហាន ដែលសុំចូលមកក្នុងប្រទេសកម្ពុជា តាមព្រំដែនខ្មែរ-ថៃ ទាំងពីរសានោះ ប្រហែលជាគ្មានវាសនានៅដល់សព្វថ្ងៃនេះទេ ។ កាលនោះសង្គ្រាមនៅក្តៅនៅឡើយ ដូចដំបៅទើបតែជា មិនទាន់បាត់ឈឺផង ដូច្នេះប្រជាជនមិនទុកអតីតទាហានដែលភាគច្រើនជាទ័ពអាកាសទាំងនេះទេ ហើយម្យ៉ាងអង្គការមិនបានត្រួតពិនិត្យឲ្យបានដិតដល់ទេគ្រានោះ ព្រោះនៅឆ្ងាយពីភ្នំពេញ មិនដូចគាត់ដែលបានមកចុះនៅពោធិ៍ចិនតុងទេ ។ កាលណាចូលកាន់ការវិញ គាត់នឹងសើរើប្រមូលរៀបចំទ័ពអាកាសជាថ្មីឡើងវិញ ។ ការជជែកគ្នាក៏ត្រូវដាច់ត្រឹមនេះ ដោយដល់ម៉ោងឈប់ធ្វើការ ហើយមិត្តឯទៀតក៏ដើរមកជួបជុំគ្នាហូរហែ ហើយខ្ញុំ និងគាត់ក៏បែកគ្នា ។ ចាប់តាំងពីថ្ងៃនោះមក ខ្ញុំមិនដែលបានជួបគាត់ទេ ដោយមិនបានធ្វើការជាមួយគ្នាព្រោះក្រុមផ្សេងគ្នា និងវិន័យតឹងតែងមិនឲ្យចេញចូលរវាងសមូហភាពខាងលិច និងខាងកើតទេ រហូតដល់ខ្ញុំត្រូវអង្គការចាត់តាំងឲ្យទៅធ្វើការនៅព្រែកប្រា ។ ប៉ុន្តែនៅពេលដែលខ្ញុំទៅព្រែកប្រា គាត់នៅធ្វើការនៅភូមិតាលៃដដែល ។

### ១០) ចេង សាយ៉ុមប៊ុន

ឈ្មោះដើម ចេង សាយ៉ុមប៊ុន ជាអតីតនាយទាហានពាក់ស័ក្តិ៥ មាននិន្នាការរាជានិយម ។ នៅពេលរដ្ឋប្រហារឆ្នាំ១៩៧០ គាត់ធ្វើជាចៅហ្វាយខេត្តក្រចេះ និងជាមេបញ្ជាការនៅតំបន់សឹកខេត្តក្រចេះ ។ ក្រោយរដ្ឋប្រហារផ្ទុះឡើង កងទ័ពបដិវត្តន៍កម្ពុជាបានធ្វើការវាយប្រហារដណ្តើមកាន់កាប់ខេត្តក្រចេះភ្លាម សាយ៉ុមប៊ុន ឥតមានចាត់វិធានការទប់ទល់ឲ្យបានមុតមាំទេ គឺបញ្ជាទ័ពឲ្យដកថយ ហើយរត់ដោះខ្លួនមកភ្នំពេញតែម្តង ។ គាត់ត្រូវរដ្ឋាភិបាល

របស់ លន់ នល់ ចោទថាក្បត់ជាតិ ចាប់គាត់ឃុំឃាំង និងឲ្យតុលាការសឹកកាត់ទោស ។ ប៉ុន្តែក្រោយមក គាត់ត្រូវបានបក្សពួកជួយរំដោះឲ្យរួចផុតពីគុក ហើយបានចូលរួមជាមួយអង្គការបដិវត្តន៍ ដើម្បីត្រឡប់មកវាយប្រហាររដ្ឋាភិបាល លន់ នល់ វិញ ។ គាត់ជាមេទ័ពមួយដ៏សំខាន់ក្នុងចំណោមមេទ័ពធំៗ នៃកងទ័ពបដិវត្តន៍ក្នុងការវាយរំដោះទីក្រុងភ្នំពេញ ។

ហ្វ្រាក់ មីលីគុន បានដាក់ឈ្មោះ ចេង សាយ៉ុមប៊ិន បញ្ចូលក្នុងចំណោមមនុស្សរបស់វា ដែលតម្រូវឲ្យខ្ញុំ (ស៊ីលេណា) ធ្វើការទាក់ទងដើម្បីបង្កើនកម្លាំងផ្ទៃក្នុងបដិវត្តន៍កម្ពុជាឲ្យបានច្រើន ដើម្បីវាយប្រហារលើកងទ័ពបដិវត្តន៍កម្ពុជាតាមផែនការថ្មីរបស់ខ្លួន ។ ដើម្បីធ្វើការទាក់ទាញ ចេង សាយ៉ុមប៊ិន ឲ្យរួមបំពេញផែនការរបស់អាមេរិកនេះ គឺឈ្មោះ ធុច និង អុន ដែលអាមេរិកបានបង្កប់ទុកដើម្បីតាមដានអ្នកបដិវត្តន៍ដែលត្រូវទាក់ទង ឬត្រូវត្រៀមទុកទាក់ទងជាអ្នករៀបចំ ។

## ១១) ឌុប យ៉ុន

ឌុប យ៉ុន មានអាយុ៣៧ឆ្នាំ ជាជនជាតិខ្មែរ មានស្រុកកំណើតនៅខេត្តព្រៃវែង ។ កាលពីមុនរដ្ឋប្រហារឆ្នាំ១៩៧០ ឪពុករបស់ យ៉ុន ធ្លាប់បានធ្វើជាគិញឲ្យមេឃុំ និងមានភារកិច្ចជាអ្នកស៊ើបរកខ្មែរក្រហមនៅក្នុងឃុំ ។ លុះដល់ក្រោយរដ្ឋប្រហារគាត់បានធ្វើការរួមជាមួយ យ៉ុន ដោយធ្វើជាអ្នកយកការណ៍ឲ្យ យ៉ុន អំពីសកម្មភាពទាំងឡាយក្នុងតំបន់រំដោះនៃខេត្តព្រៃវែង រហូតដល់ចុងឆ្នាំ១៩៧៤ ទើបឈប់ធ្វើកិច្ចការនេះដោយមិនដឹងមូលហេតុ ។

យ៉ុន មានប្អូនស្រីម្នាក់ និងប្អូនប្រុសម្នាក់ ។ ប្អូនស្រីមានប្តីរស់នៅក្នុងតំបន់រំដោះក្នុងខេត្តព្រៃវែង ។ ចំណែកប្អូនប្រុសនៅលីវរស់នៅជាមួយឪពុកម្តាយក្នុងតំបន់រំដោះដែរ ។ ប្អូនថ្លៃរបស់ យ៉ុន ក៏ធ្វើការងារជាមួយឪពុករបស់ យ៉ុន ដែរ ។ យ៉ុន បានទាក់ទងផ្នែកនយោបាយចាប់តាំងពីឆ្នាំ១៩៦៥ នៅពេលដែលគាត់ចេញពីសាលានាយទាហានរងបច្ចេកទេស ចូលទៅធ្វើការនៅវាលយន្តហោះពោធិ៍ចិនតុង ។ ដំបូង គាត់បានចូលរួមជាមួយនាយទាហានម្នាក់ឈ្មោះ ឡាំ សាមុត ។ យ៉ុន បានចូលជាភ្នាក់ងារ សេ.អ៊ី.អា នៅចុងឆ្នាំ១៩៦៥ ហើយបានបង្កប់ខ្លួននៅវាលយន្តហោះពោធិ៍ចិនតុង ។ បេសកកម្មពិសេសរបស់គាត់គឺធ្វើឲ្យមានការរំជើបរំជួលក្នុងកងទ័ពអាកាសអំពីការផ្តាច់ជំនួយរបស់អាមេរិក ទៅឲ្យរដ្ឋាភិបាលខ្មែរសម័យនោះ ។ ចាប់តាំងពីឆ្នាំ១៩៦៥ រហូតមកដល់ថ្ងៃរដ្ឋប្រហារឆ្នាំ១៩៧០ យ៉ុន មានមុខងារជាអ្នកដើរញុះញង់ឲ្យមានការមិនសប្បាយចិត្តចំពោះការខ្វះខាតនៅក្នុងកងទ័ពដែលបណ្តាលមកពីការកាត់ជំនួយរបស់អាមេរិក ក្នុងគោលបំណងឲ្យកងទ័ពមាននិន្នាការលម្អៀងចង់ទៅរកជំនួយអាមេរិកវិញ ។ លុះមកដល់ក្រោយពេលរដ្ឋប្រហារ យ៉ុន មានបេសកកម្មថ្មី គឺស៊ើបអង្កេត និងរាយការណ៍ឲ្យភ្នាក់ងារអាមេរិកដែលធ្វើការនៅក្នុងមូលដ្ឋានពោធិ៍ចិនតុងជាមួយគ្នាអំពីការលួចបន្លំយកគ្រឿងសម្ភាររបស់អាមេរិកទៅលក់ដូរ ។ យ៉ុន ធ្វើការស៊ើបអង្កេត និងរាយការណ៍រហូតដល់ឆ្នាំ១៩៧៤ ។

មកដល់ឆ្នាំ១៩៧៥ យ៉ុន ត្រូវបានបញ្ជូនឲ្យទៅសិក្សានៅសហរដ្ឋអាមេរិក ផ្នែកខ្ទម្ពាកចក្រ ។ ថ្ងៃ២០ មេសា ឆ្នាំ១៩៧៥ ស័ក្តិ៥អាមេរិក ដែលជាចាងហ្វាងសាលាឈ្មោះ កេ អាបុត បានទាក់ទង យ៉ុន និងបានប្រគល់បេសកកម្ម និងផែនការដើម្បីវាយប្រហារអង្គការបដិវត្តន៍នៅប្រទេសកម្ពុជា ។ អាបុត បានប្រាប់ យ៉ុន ឲ្យចូលរួមធ្វើការងារជាមួយខ្ញុំចាប់តាំងពីពេលនោះមក ។ នៅក្នុងសាលាភាសាអង់គ្លេសនារដ្ឋតិចសាស់ គាត់បានឃោសនាប្រមែប្រមូលអ្នកសុំវិលត្រឡប់មកស្រុកខ្មែរវិញឲ្យបានច្រើនដើម្បីងាយបន្លំលាក់ខ្លួន ។ លុះដល់ថ្ងៃទី២១ ខែមិថុនា ឆ្នាំ១៩៧៥ គាត់ត្រូវបាន អាបុត បញ្ជូនទៅជំរំហ្គតឆាហ្វីជាមួយខ្ញុំ និងសិស្សចំនួន៣០នាក់ទៀត ដើម្បីទៅទាក់ទងអង្គការសហប្រជាជាតិ ។ កាលនៅក្នុងជំរំ នៅចុងខែទី៦ ឆ្នាំ១៩៧៥ គាត់ក៏បានជួប និងទទួលការណែនាំបន្ថែមទាក់ទងបេសកកម្ម និងផែនការដែលត្រូវយកមកបំពេញនៅប្រទេសកម្ពុជា ពីស្ត្រីអាមេរិកម្នាក់ដែលដំណាងឲ្យក្រសួងការបរទេសអាមេរិក ។ លុះដល់ថ្ងៃទី១៨ ខែកក្កដា ឆ្នាំ១៩៧៥ អាបុត បានបញ្ជូន យ៉ុន រួមជាមួយខ្ញុំ និងអ្នកផ្សេងទៀតទៅជំរំជិនដិលគុន ក្នុងរដ្ឋកាលីហ្វញ៉ា ដើម្បីប្រមូលផ្តុំគ្នានៅទីនោះ ។ ប្រហែលជាមួយអាទិត្យក្រោយ ហ្វ្រាក់ មីលីគុន តំណាងក្រសួងការបរទេសអាមេរិកបានទៅជួប យ៉ុន ពិភាក្សាពីបេសកកម្ម និងគម្រោងផែនការ និងបានឲ្យឈ្មោះបក្សពួកខ្លួនដល់ យ៉ុន ដើម្បីធ្វើការរួមគ្នា ។ ចាប់តាំងពីចេញដំណើរពីសាលាមកដល់ជំរំនេះ គាត់

មាននាទីជាលេខាធិការក្នុងក្រុមដែលមានសមាជិក៣០នាក់រហូតដល់ក្រុមនេះត្រូវរំលាយចោល ។ គាត់បានចូលរួមគ្រប់សកម្មភាពដើម្បីបង្កើតក្រុមអ្នកដែលសុំវិលត្រឡប់មកស្រុកដែលទើបតែបង្កើតនៅចុងខែកញ្ញា ឆ្នាំ១៩៧៥ ដែលមានឈ្មោះ គឹម កឿកឡឿង ជាប្រធាន និង នង សំអឿន ជាអនុប្រធាន ចំណែកគាត់ក៏បាននាទីជាក្រុមប្រឹក្សាដែរ ។ នៅក្នុងជំរំនេះ យ៉ុន បានធ្វើសកម្មភាពដើម្បីបន្លំខ្លួនដើម្បីឲ្យអ្នកផ្សេងមើលឃើញថាគាត់ជាអ្នកចង់ត្រឡប់មកស្រុកខ្មែរវិញដោយចិត្តស្មោះត្រង់ ។ នៅថ្ងៃទី២០ ខែតុលា ឆ្នាំ១៩៧៥ មីលីតុន បានបញ្ជូន យ៉ុន ឲ្យទៅជំរំគេឡូហ្គា នៅរដ្ឋការលីហ្វញ៉ា រួចបញ្ជូនបន្តទៅជំរំហ្វតឆាហ្វី រដ្ឋអាខាន់សាស់ ។ នៅដើមខែវិច្ឆិកា យ៉ុន បានដាក់ឈ្មោះសុំចូលជាសមាជិកក្រុមខេមរនៅសហរដ្ឋអាមេរិក ដែលមានទីចាត់ការនៅក្រុងញូវយ៉ក ដឹកនាំដោយមិត្ត ម៉ុក សាវុធ និងមិត្ត ហ៊ីង សុខុម ។ ក្រុមខេមរជាតិនេះជាអង្គការដែលបម្រើនយោបាយរណសិរ្សរួបរួមជាតិ កម្ពុជានៅក្រុងប៉េកាំង និងនៅក្រុងប៉ារីស ។ នៅជំរំនេះ គាត់បានចូលរួមធ្វើការទាមទារជាមួយក្រុមអ្នកសុំត្រឡប់មកស្រុកវិញទាំងអស់ ដោយឲ្យអាមេរិក និងអង្គការសហប្រជាជាតិ បញ្ជូនខ្លួនឲ្យទៅនៅប្រទេសចិន ឬប្រទេសថៃបណ្ដោះអាសន្នសិន ទំរាំបានសេចក្ដីអនុញ្ញាតពីរដ្ឋាភិបាលកម្ពុជា ។ ការទាមទារនេះពុំបានសម្រេចទេ ។ នៅថ្ងៃទី១១ ខែធ្នូ ឆ្នាំ១៩៧៥ លីមីតុន បានបញ្ជូនគាត់ ជាមួយនឹងក្រុមទាំងអស់ឲ្យនៅក្រុងហ្វីឡាដែលហ្វី រដ្ឋជីនស៊ីវីជីនី ។ នៅទីក្រុងនេះគាត់ស្ថិតនៅក្រោមការទទួលខុសត្រូវរបស់អង្គការសហប្រជាជាតិដូចកាលនៅក្នុងជំរំដែរ និងទទួលការផ្គត់ផ្គង់ពីអង្គការ អេន.អេស.ស៊ីតាំងពីម្ហូបអាហារ សណ្ឋាគារ សុខភាព និងរហូតដល់ចេញថ្ងៃសោហ៊ុយត្រឡប់មកស្រុកខ្មែរវិញទាំងអស់ ។

នៅក្រុងនេះ យ៉ុន បានចូលរួមធ្វើសេចក្ដីថ្លែងការទៅកាន់សារព័ត៌មាន និងបានចូលរួមបំពេញពាក្យសុំសេចក្ដីអនុញាតទៅបេសកកម្មនៃកម្ពុជាប្រជាធិបតេយ្យប្រចាំក្រុងប៉ារីស ។ យ៉ុន បានទៅទីក្រុងប៉ារីសនៅដើមខែមីនា ឆ្នាំ១៩៧៦ ។ បន្ទាប់ពីបានទៅដល់ក្រុងប៉ារីសភ្លាម គាត់បានដាក់ពាក្យសុំក្ដីអនុញ្ញាតម្ដងទៀតទៅបេសកកម្ម និងសុំចូលធ្វើជាសមាជិករណសិរ្សរួបរួមជាតិកម្ពុជាប្រចាំក្រុងប៉ារីស ។ គាត់បានរៀនឯកសារបដិវត្តន៍ជាច្រើនផង និងបានចូលរួមចែកឯកសារ និងសេចក្ដីអញ្ជើញដល់មហាជន និងជួយរៀបចំគ្រប់ពិធីបុណ្យជាតិដែលចាត់ចែងឡើងដោយគណៈកម្មាធិការប្រចាំក្រុងប៉ារីស ។ យ៉ុន ខិតខំធ្វើសកម្មភាពបែបនេះក្នុងគោលបំណងឲ្យតំណាងអង្គការនៅទីនោះមានការទុកចិត្តមកលើខ្លួន ដើម្បីបានសេចក្ដីអនុញ្ញាតឲ្យចូលស្រុកវិញ ។ យ៉ុន បានទទួលការចាត់តាំងពីអង្គការឲ្យត្រឡប់មកប្រទេសកម្ពុជានៅថ្ងៃទី២៥ ខែឧសភា ឆ្នាំ១៩៧៦ ។ គាត់បានមកដល់ភ្នំពេញនៅថ្ងៃទី២៨ ខែឧសភា ឆ្នាំ១៩៧៦ ។ បន្ទាប់ពីមកដល់ក្រុងភ្នំពេញ គាត់ត្រូវបានអង្គការចាត់តាំងឲ្យនៅរៀនសូត្រ អប់រំ ធ្វើការងារពលកម្មនៅក្នុងមន្ទីរអតីតសាលាបច្ចេកទេសមិត្តភាពខ្មែរ-សូវៀត ។ គាត់បានរៀនវគ្គសិក្សាទី១ ចប់សព្វគ្រប់នៅថ្ងៃទី១៧ ខែកក្កដា ឆ្នាំ១៩៧៦ ។ យ៉ុន បានចាប់ផ្ដើមធ្វើការទាក់ទងជាសម្ងាត់ជាមួយ ភួង ផាញ់ រហូតដល់ពាក់កណ្ដាលខែមិថុនា ទើបដាច់ការទាក់ទងដោយ ភួង ផាញ់ ត្រូវបានអង្គការបញ្ជូនឲ្យទៅធ្វើការនៅភូមិតាលៃ ។ នៅក្នុងមន្ទីរ យ៉ុន ខិតខំធ្វើការងារ ដើម្បីយកចិត្តគណៈទទួលខុសត្រូវ ក្នុងគោលបំណងទាក់ទងអ្នកបដិវត្តន៍មកពីបរទេសឲ្យចូលរួមធ្វើសកម្មភាពទៅតាមផែនការរបស់អាមេរិក ។ លុះដល់ថ្ងៃទី១៧ ខែកក្កដា ឆ្នាំ១៩៧៦ យ៉ុន ត្រូវបានអង្គការចាត់តាំងឲ្យទៅធ្វើការនៅភូមិតាលៃ ជាមួយចំនួន៤០នាក់ទៀត ។ ចាប់តាំងពីថ្ងៃនោះមក យ៉ុន បានទាក់ទងគ្នាជាថ្មីជាមួយ ភួង ផាញ់ រហូតដល់បច្ចុប្បន្ន ។

## ផែនការរបស់ចក្រពត្តិអាមេរិកវាយកម្ពុជា

អាមេរិកបានចាត់តាំងក្រុម សេ.អ៊ី.អា ឲ្យមកជាមួយខ្ញុំ (ស៊ីលេណា) ចំនួន២១នាក់ តាមការសុំសេចក្ដីអនុញ្ញាតពីរដ្ឋាភិបាលតាមយន្តហោះ ដោយកាត់តាមទីក្រុងប៉ារីស ទីក្រុងប៉េកាំង និងមកដល់ទីក្រុងភ្នំពេញតែម្ដង ដើម្បីបំពេញបេសកកម្មទៅតាមផែនការរបស់អាមេរិក ។ អ្នកដែលដាក់បេសកកម្ម និងផែនការមានបីនាក់គឺ៖

១) ឈ្មោះ កេ អាបុត ស័ក្តិ៥ អាមេរិក

២) ស្ត្រីអាមេរិក ធ្វើការនៅក្រសួងការបរទេសអាមេរិក

៣) ឈ្មោះ ហ្សាក់ មីលីតុន ធ្វើការនៅក្រសួងការបរទេសអាមេរិក ជាជនស៊ីវិល ។

អ្នកទាំងបីខាងលើនេះ បានដាក់ផែនការមកខ្ញុំមុននឹងចេញមកប្រទេសកម្ពុជា ដែលផែនការទាំងបីនោះគឺ៖

១) ផែនការទី១ៈ ចាប់ផ្ដើមពីខែទី៦ ដល់ខែទី១២ ឆ្នាំ១៩៧៦ ។ ផែនការនេះ ជាផែនការរៀបចំកម្លាំងបះបោរផ្ទៃក្នុងទាំងផ្នែកនយោបាយ និងកម្លាំងអាវុធ ។

២) ផែនការទី២ៈ ចាប់ផ្ដើមពីខែទី១ ដល់ខែទី៦ ឆ្នាំ១៩៧៧ ។ ផែនការនេះ ជាផែនការយោធាដែលត្រូវវាយកម្ពុជាទូទាំងប្រទេស ។

៣) ផែនការទី៣ៈ ជាផែនការយោធាបន្ត វាយប្រហារទ័ពបដិវត្តន៍កម្ពុជា ។ ផែនការនេះចែកចេញជាពីរគឺ ៖ រយៈកាលទី១ ចាប់ផ្ដើមទីខែ៦ ឆ្នាំ១៩៧៧ ដល់ខែទី៦ ឆ្នាំ១៩៨០ រយៈកាលទី២ ចាប់ផ្ដើមពីខែ៦ ឆ្នាំ១៩៨០ ទៅដល់ខែ៦ ឆ្នាំ១៩៨២ ។

ផែនការទី១ ជាផែនការបង្កើតជាសម្ងាត់ ក្រុមបះបោរផ្ទៃក្នុងទាំងពីរប្រភេទ និងក្រុមបះបោរទ័ពព្រៃ ។ ផែនការទី១នេះ ចាប់ផ្ដើមដោយធ្វើការញុះញង់ឲ្យប្រជាជនខ្លះមិនពេញចិត្តចំពោះរបបគ្រប់គ្រងរបស់អង្គការបដិវត្តន៍ រួចប្រមូលប្រជាជន អតីតទាហានយុទ្ធជនដែលលម្អៀងពីអង្គការបដិវត្តន៍បង្កើតចលនាបះបោរ ។ ក្រុមបះបោរផ្ទៃក្នុងនេះ មានផ្នែកនយោបាយ និងកម្លាំងអាវុធ ។ ចំពោះកម្លាំងអាវុធ ត្រូវប្រមូលផ្ដុំរួចបញ្ចូលទៅទ័ពព្រៃបះបោរតាមភូមិភាគដែលនៅជាប់ ឬនៅជិតតំបន់ឈូងសមុទ្រថៃ និងតាមជួរភ្នំដងរែក ។ ចំពោះក្រុមបះបោរដែលនៅតំបន់ឆ្ងាយៗពីតំបន់ឈូងសមុទ្រសៀម និងភ្នំដងរែកទល់ដែនខ្មែរ-សៀម មិនចាំបាច់ធ្វើចលនាប្រមូលកម្លាំងចូលព្រៃទេ គឺគ្រាន់តែត្រៀមនៅភូមិភាគរបស់ខ្លួន ។ ការប្រមូលកម្លាំងចូលទ័ពព្រៃ ត្រូវឲ្យបានយ៉ាងហោចណាស់ប្រាំឬប្រាំមួយម៉ឺននាក់ ក្នុងរយៈពេលប្រាំមួយខែ ។ កម្លាំងទ័ពព្រៃបង្កើតនេះ គឺត្រៀមសម្រាប់ផែនការទី២ ។ ចំណែកក្រុមបះបោរខាងនយោបាយផ្ទៃក្នុងវិញ គឺត្រូវខំពង្រីកចលនាខ្លួនឲ្យបានយ៉ាងហោចណាស់៤០ភាគរយនៃចំនួនប្រជាជនដែលនៅក្នុងភូមិភាគរបស់ខ្លួន ។ ក្នុងផែនការទី១នេះ ក្រុមបះបោរផ្ទៃក្នុងនេះមានបេសកកម្មបង្កើតកម្លាំង ត្រៀមទុកធ្វើចលនា និងសកម្មភាពបះបោរពេញទំហឹងតែម្ដង ។ ក្នុងផែនការទី២ ក្រុមនេះមិនធ្វើសកម្មភាពឲ្យឃើញថា មានការបះបោរ ឬការប្រឆាំងអង្គការបដិវត្តន៍ទេ ។ កម្លាំងប្រជាជនផ្នែកអាវុធដែលចូលទៅរួមកម្លាំងជាមួយទ័ពព្រៃ បះបោរជាមួយទ័ព អ៊ិន តាំ នៅតាមជួរភ្នំដងរែកជាមួយទ័ពខ្មែរសេរីនៅក្នុងភូមិភាគឈូងសមុទ្រថៃ ត្រូវទៅតាំងមូលដ្ឋានខ្លួននៅតំបន់ទាំងនេះ ដោយស្ថិតនៅក្រោមបញ្ជាទ័ពព្រៃខ្មែរសេរី និងទ័ពរបស់ អ៊ិន តាំ តែមិនធ្វើសកម្មភាពអ្វីឲ្យប៉ះពាល់នឹងកងទ័ពបដិវត្តន៍ឡើយ ។

ផែនការទី២ ជាផែនការយោធា ដែលរៀបចំសម្រាប់វាយប្រហារកងទ័ពបដិវត្តន៍ទូទាំងប្រទេស ។ កងទ័ពព្រៃបះបោររួមជាមួយទ័ព អ៊ិន តាំ កងទ័ពខ្មែរសេរីក្នុងភូមិភាគឈូងសមុទ្រថៃ និងទ័ព ស៊ីង ង៉ុកថាញ់ ដែលចុះមកពីកោះត្រល់ ដែលស្ថិតនៅតាមតំបន់ទល់ដែននេះ ត្រូវចាប់ផ្ដើមវាយកាត់ផ្ដាច់យកភូមិភាគដែលមានមូលដ្ឋានរបស់ខ្លួនជាមុនសិន ។ ក្រុមបះបោរផ្ទៃក្នុង ក៏ត្រូវចាប់ធ្វើសកម្មភាពរួមផ្សំជាមួយនឹងការវាយប្រហារពីក្រៅសម្រាប់ជាជំនួយជួយគ្នាទៅវិញទៅមក ។ ក្រុមបះបោរនីមួយៗ ត្រូវចាប់ធ្វើនៅក្នុងភូមិភាគខ្លួន ប្រឆាំងនឹងអង្គការបដិវត្តន៍ ចលនាជ្រួលច្របល់ឥតរបៀបរៀបរយគ្រប់វិស័យ ទាំងផ្នែកនយោបាយ សេដ្ឋកិច្ចសង្គមកិច្ច ដោយប្រើគ្រប់មធ្យោបាយ ។ ចំណែកទ័ពព្រៃរបស់ អ៊ិន តាំ ទ័ពរបស់ខ្មែរសេរីនៅភូមិភាគឈូងសមុទ្រថៃ និងទ័ពរបស់ ស៊ីង ង៉ុកថាញ់ ដែលចូលមកតាមតំបន់តំពត បន្ទាប់ពីវាយដណ្ដើមកាន់កាប់អំណាចពីអង្គការបដិវត្តន៍នៅភូមិភាគដែលមានមូលដ្ឋានរបស់ខ្លួនហើយ ត្រូវចុះសំដៅមកតាមមុខព្រួញរៀងៗខ្លួនសំដៅទៅចាប់ដៃក្រុមបះបោរនៅក្នុងតំបន់ជិតខាងខ្លួនជាបន្តបន្ទាប់ និងនាំយកសម្ភារជំនួយពីអាមេរិកទៅឲ្យដល់ក្រុមបះបោរដើម្បីបង្កើតជាកម្លាំងអាវុធ សម្រាប់កាន់កាប់ និងការពារតំបន់ដែលបានរំដោះ ។ កម្លាំងមួយផ្នែកទៀត ចូលរួមជាមួយនឹងទ័ព អ៊ិន តាំ ទ័ព ស៊ីង ង៉ុកថាញ់ និងទ័ពខ្មែរសេរីនៃតំបន់ឈូងសមុទ្រថៃ ទៅរំដោះតំបន់ដែលនៅជិតគ្នាជាបន្តរហូតដល់កាន់កាប់រដ្ឋអំណាច និងទឹកដីទាំងអស់ ។ មុខព្រួញទ័ពរបស់ អ៊ិន តាំ មានពីរគឺ ១) សំដៅទៅភូមិភាគបាត់ដំបង ដើម្បីទៅភ្ជាប់ជាមួយមុខព្រួញមួយទៀតដែលចេញពីភូមិភាគកោះកុងមក និង ២) សំដៅឧត្ដរមានជ័យ ព្រះវិហារ និងបន្តទៅទិសខាងកើតរហូតដល់រួមដៃគ្នាទាំងបីមុខព្រួញ ។ មុខព្រួញរបស់ទ័ពព្រៃ ខ្មែរសេរី ក្នុងភូមិភាគឈូងសមុទ្រថៃគឺវាយកាត់ផ្ដាច់

យកភូមិភាគនេះទាំងមូល តាំងពីកំពត ទៅកំពង់សោម និងទៅដល់កោះកុង ព្រំដែនខ្មែរ-ថៃ រួចបែរមុខព្រួញសំដៅទៅប៉ៃលិន រួចទៅចាប់ដៃជាមួយទ័ព អ៊ិន តាំ ដែលបន្តពីបាត់ដំបងមកមុខព្រួញមួយទៀត ចេញពីភូមិភាគកំពង់សោម សំដៅទៅតំបន់កំពង់ស្ពឺ និងទៅមុខជានិច្ចសំដៅក្រុងភ្នំពេញ ។ មុខព្រួញរបស់ទ័ព ស៊ីង ង៉ុកថាញ់ វាយចេញពីកំពតយកភូមិភាគតាកែវ និងសំដៅមកភ្នំពេញដែរ ។ មុខព្រួញរបស់ទ័ពបីនេះ គឺវាយកាន់កាប់ភូមិភាគទាំងអស់ ខាងលិចត្រើយទន្លេមេគង្គរួមផ្តុំគ្នានៅក្រុងភ្នំពេញ និងជាចុងក្រោយមុខព្រួញទាំងអស់បែរទៅភូមិភាគនៅខាងកើតត្រើយទន្លេមេគង្គ រហូតដល់រំដោះបានទាំងអស់ ។

គ្រឿងសម្ភារទាំងអស់សម្រាប់ធ្វើការវាយប្រហារអគ្គការបដិវត្តន៍កម្ពុជានេះ មួយភាគធំជាជំនួយរបស់អាមេរិកកាំង និងមួយភាគតូចជាជំនួយរបស់បក្សលោកសេរី ។ ជាដំបូងនៃការផ្តល់គ្រឿងសម្ភារ អាមេរិកបញ្ជូនតាមផ្លូវសម្ងាត់កាត់តាមប្រទេសថៃចូលមកឲ្យកងទ័ព អ៊ិន តាំ និងទ័ពព្រៃខ្មែរសេរីនៅក្នុងឈូងសមុទ្រថៃ ។ នៅពេលដែលកាន់កាប់ភូមិភាគឈូងសមុទ្រថៃបានហើយ ជាពិសេសកំពង់សោម ការផ្តល់ជំនួយសម្ភារមួយចំនួនធំសម្រាប់ធ្វើការវាយប្រហារអគ្គការបដិវត្តន៍នេះ ត្រូវធ្វើតាមសមុទ្រវិញ ។

**ការទាក់ទង និងរាយការណ៍ឲ្យគ្នា រវាងខ្មែរខាងក្នុង និងខាងក្រៅ**

ក្រុមខ្ញុំ (ស៊ីម ស៊ីលេណា) ដែលទទួលបេសកកម្ម និងផែនការពីអាមេរិកមកក្នុងប្រទេសកម្ពុជានេះ ជាខ្សែបង្កប់ថ្មីនៅក្នុងប្រទេសកម្ពុជា ។ ក្រុម សេ.អ៊ី.អា ដែលអាមេរិកបានបង្កប់ទុកក្នុងបដិវត្តន៍កម្ពុជាពីលើកមុន សម្រាប់ត្រៀមទទួលធ្វើផែនការថ្មីរបស់អាមេរិកមកលើកម្ពុជានេះ ជាខ្សែក្នុងចាស់ ចំណែកក្រុម សេ.អ៊ី.អា នៅក្រៅប្រទេសកម្ពុជា ជាខ្សែក្រៅសម្រាប់បន្តការទាក់ទងទៅក្រសួងការបរទេសអាមេរិក និងទីបញ្ជាការ សេ.អ៊ី.អា នៅក្រុងវ៉ាស៊ីនតោន សហរដ្ឋអាមេរិក ។

ការទាក់ទងពីក្រុម សេ.អ៊ី.អា ដែលនៅក្រៅប្រទេសកម្ពុជាមកខ្សែបង្កប់ក្នុងកម្ពុជាទាំងចាស់ទាំងថ្មីមានពីរបែប មួយគឺបញ្ជូនបេសកជនឲ្យចូលក្នុងកម្ពុជាតាមសេចក្តីអនុញ្ញាតនៃរដ្ឋាភិបាលកម្ពុជា ក្នុងលក្ខណៈជាជនជាតិខ្មែរសុំត្រឡប់មកកម្ពុជាវិញ មួយទៀតគឺបញ្ចូលបេសកជនមកក្នុងប្រទេសកម្ពុជាតាមព្រំដែន មកទាក់ទងខ្សែបង្កប់ក្នុងប្រទេសកម្ពុជា រួចលួចចេញទៅវិញ ។ ចំពោះការធ្លាប់ចេញចូលតាមព្រំដែននេះ អាចមានជំនួយតាមយន្តហោះក៏មាន តាមការសម្រេចរបស់ទីបញ្ជាការ សេ.អ៊ី.អា ។ និងម៉្យាងទៀត ការបាចឯកសារ ឬគ្រាក់ជាចំហ ចំពោះកាលៈទេសៈខុះតាមយន្តហោះសម្ងាត់ ដើម្បីឲ្យព័ត៌មានដល់ខ្សែបង្កប់ខាងក្នុងកម្ពុជា ក៏មាននៅក្នុងគម្រោងនៃការទាក់ទងគ្នាដែរ ។

ចំពោះការទាក់ទងគ្នា និងរាយការណ៍ឲ្យគ្នារវាងខ្សែក្នុងដែលបង្កប់ពីមុននៅក្នុងបដិវត្តន៍ជាមួយខ្សែថ្មីដែលទើបតែមកពីសហរដ្ឋអាមេរិក ដើម្បីនាំយកបេសកកម្មថ្មី និងផែនការថ្មីវាយកម្ពុជា ហើយត្រូវតែរកមធ្យោបាយយ៉ាងណាឲ្យមានការទាក់ទងគ្នាបាន ទើបអាចមានលទ្ធភាពគ្រប់គ្រាន់ក្នុងការអនុវត្តផែនការវាយកម្ពុជាទៅតាមគម្រោង ។ ក្រុមដែល សេ.អ៊ី.អា បញ្ជូនមកពីអាមេរិក ដើម្បីធ្វើសកម្មភាពនៅក្នុងកម្ពុជា ត្រូវចាប់ផ្តើមរៀបចំខ្សែទាក់ទងគ្នាថ្មីក្នុងសង្គមកម្ពុជាដើម្បីធ្វើសកម្មភាពទៅតាមបេសកកម្មរបស់ខ្លួន និងរៀបចំការទាក់ទងជាមួយខ្សែ សេ.អ៊ី.អា ដែលបានបង្កប់ទុក មុនកម្ពុជាត្រូវបានរំដោះនៅក្នុងជួរបដិវត្តន៍ ដើម្បីនឹងប្រគល់ឲ្យដល់ក្រុម សេ.អ៊ី.អា ដែលបង្កប់ពីមុននូវបេសកកម្ម និងផែនការវាយប្រហារលើកម្ពុជា និងដើម្បីយកសេចក្តីរាយការណ៍ពីក្រុមចាស់នេះ អំពីសភាពការណ៍ទូទៅ និងអំពីចំណុចនិងទិសដៅរបស់អាមេរិកដែលបានដាក់ឲ្យមក ដើម្បីរួមធ្វើសកម្មភាពជាមួយគ្នា ។ ដូចនេះក្រុមដែលអាមេរិកបញ្ជូនមកធ្វើសកម្មភាពទៅតាមផែនការរបស់វាមកលើកម្ពុជានេះ ត្រូវពឹងផ្អែកទៅលើជំនួយពីក្រុម សេ.អ៊ី.អា ចាស់ដែលបង្កប់នៅក្នុងបដិវត្តន៍ទាំងស្រុងទើបអាចបំពេញបេសកកម្មរបស់ខ្លួនបាន ។ បើធ្វើការទាក់ទងជាមួយក្រុម សេ.អ៊ី.អា បង្កប់ត្រៀមទុកក្នុងបដិវត្តន៍កម្ពុជាមិនបានទេនោះ ផែនការអាមេរិកវាយកម្ពុជាជាថ្មីនេះមិនអាចប្រព្រឹត្តទៅបានទេ ហើយត្រូវមានការកែប្រែជាបន្ទាប់ ។ ដើម្បីធ្វើការទាក់ទងទៅក្រុមបង្កប់ត្រៀមទុកក្នុងបដិវត្តន៍ ដែលជាជំនួយចាំបាច់បំផុតសម្រាប់បេសកកម្មរបស់ខ្ញុំ ទៅតាមការដោះមករបស់ ហ្សាក់ មីលីតុនគឺខ្ញុំត្រូវរិតខំគ្រប់មធ្យោបាយនៅពេលមកដល់កម្ពុជាភ្លាមស៊ើបរកមេក្រុម សេ.អ៊ី.អា ដែលអាមេរិកបង្កប់ទុកក្នុងបដិវត្តន៍តាំងពីឆ្នាំ១៩៧៣ គឺឈ្មោះ កុយ ធួច និង កែវ អុន ដែលជាយុទ្ធជន

បដិវត្តន៍នៅក្រុងភ្នំពេញ ដើម្បីឲ្យអ្នកទាំងពីរជួយខ្ញុំក្នុងការទាក់ទងជាមួយឈ្មោះ ថាច នៅបាត់ដំបង, ដាវ នៅពោធិ៍សាត់, ពូន នៅកំពង់ឆ្នាំង, ចាន់ នៅកំពង់ស្ពឺ និង មុី នៅកំពត ដើម្បីធ្វើសកម្មភាពជាមួយខ្ញុំ ។ ម្យ៉ាងទៀតប្រគល់ឲ្យ ធុច និង អុន នូវឈ្មោះ ចេង សាយ៉ុមប៊ុន ដែល ហ្សាក់ មីលីតុន បានដោឲ្យមកទាក់ទងបញ្ចូលបក្ស និងដើម្បីពង្រីកកម្លាំងរបស់ខ្លួននៅក្នុងបដិវត្តន៍ ។

ចំពោះការទាក់ទងគ្នា និងរាយការណ៍ឲ្យគ្នាទៅវិញទៅមកពីខ្មែរក្នុងនៃកម្ពុជាទៅខ្មែរខាងក្រៅ គឺជាមួយក្រុម សេ.អុី.អា អាមេរិកដែលបង្កប់ខ្លួននៅក្នុងអង្គការមនុស្សធម៌ និងអង្គការកាកបាទក្រហមអន្តរជាតិនៅស្រុកយួន និងស្រុកសៀម ហើយត្រូវប្រព្រឹត្តទៅតាមសភាពការណ៍ជាក់ស្តែង ។ នៅពេលដែលក្រុមខ្ញុំមកដល់កម្ពុជាហើយ ហើយមិនអាចធ្វើការទាក់ទងជាមួយខ្មែរចាស់ដែលបង្កប់នៅក្នុងបដិវត្តន៍ទេ និងមិនអាចពង្រីកខ្មែរទាក់ទងក្រុមថ្មីរបស់ខ្លួនទៅក្នុងសង្គមកម្ពុជា ដើម្បីរាយការណ៍ឲ្យក្រសួងការបរទេសអាមេរិក និងទីបញ្ជាការ សេ.អុី.អា អាមេរិកនៅក្រុងវ៉ាស៊ីនតោនបានទេ គឺត្រូវបញ្ជូនបេសកជនចេញទៅក្រៅ ទោះសៀមក្តី យួនក្តី ដើម្បីទៅទាក់ទងជាមួយនឹងភ្នាក់ងារ សេ.អុី.អា អាមេរិក ដើម្បីធ្វើសេចក្តីរាយការណ៍បន្ត ។ ម្យ៉ាងទៀត កាលបើខ្មែរក្នុងទាំងចាស់ទាំងថ្មីអាចរៀបចំធ្វើការទាក់ទងគ្នាបានហើយនៅតាមគ្រប់តំបន់រហូតជាយដែន ការទាក់ទងគ្នាពីក្នុងទៅក្រៅ និងពីក្រៅមកក្នុង ត្រូវចាត់ធ្វើជាសារ ឬឯកសារផ្ញើទៅមកតាមរយៈខ្មែរនេះវិញ មិនបាច់បញ្ជូនបេសកជនទៅក្រៅទេ លើកលែងតែមានការចាំបាច់ ។ ការទាក់ទងគ្នា និងការរាយការណ៍រវាងខ្ញុំ និងខ្មែរក្នុងក្រៅកន្លងមកមានដូចតទៅ៖

មុននឹងខ្ញុំមកពីសហរដ្ឋអាមេរិក មកបំពេញបេសកកម្មតាមផែនការវាយកម្ពុជាជាថ្មី ហ្សាក់មីលីតុន បានណែនាំខ្ញុំឲ្យទាក់ទងជាមួយ ភួង ផាញ់ ដែលបានបញ្ជូនពីអាមេរិកមកដែរ ឲ្យខ្ញុំទាក់ទងជាមួយខ្មែរ សេ.អុី.អា ដែលបានបង្កប់ទុកក្នុងបដិវត្តន៍កម្ពុជាត្រៀមសម្រាប់ផែនការអាមេរិកវាយកម្ពុជា ដូចដែលបានរាយឈ្មោះខាងលើនេះស្រាប់ និងឲ្យខ្ញុំទាក់ទងជាមួយ សេ.អុី.អា អាមេរិកនៅសៀម និងយួន ដើម្បីរាយការណ៍ឲ្យខ្លួនវិញ ។

ខ្ញុំបានមកដល់កម្ពុជានៅថ្ងៃទី២៨ ខែខសភា ឆ្នាំ១៩៧៦ ។ នៅមន្ទីរភ្នំពេញ ខ្ញុំបានទទួលការណែនាំពី ភួង ផាញ់ ឲ្យទាក់ទងជាមួយឈ្មោះ ហ៊ុល តាប អតីតជា សេ.អុី.អា នៅសល់ពីមុនមក និងជាកម្មកររទេះភ្លើងនៅភ្នំពេញ ដើម្បីជួយខ្ញុំក្នុងការស៊ើបរកក្រុម សេ.អុី.អា ដែលអាមេរិក បានបង្កប់ត្រៀមទុកសម្រាប់ផែនការវាយបដិវត្តន៍កម្ពុជាថ្មី ។ ខ្ញុំបានជួបទាក់ទងជាមួយ ហ៊ុល តាប បានម្តង និងបានទទួលសេចក្តីរាយការណ៍ខ្លះអំពីព្រឹត្តិការណ៍នៅក្នុងប្រទេសកម្ពុជាក្រោយថ្ងៃ១៧ មេសា ១៩៧៥ មកដល់សព្វថ្ងៃ និងអំពីសកម្មភាពខ្លះដែលប្រឆាំងនឹងអង្គការបដិវត្តន៍ពីក្រៅ និងពីក្នុង ។ ខ្ញុំបានណាត់ជួបជាមួយ ហ៊ុល តាប ម្តងទៀតដើម្បីប្រគល់ឈ្មោះដែលខ្ញុំត្រូវទាក់ទងជាមួយទៅគាត់ ឲ្យគាត់ជួយស៊ើបរក ។ តែខ្ញុំឥតបានជួប ហ៊ុល តាប ជាលើកទីពីរទេ ដោយអង្គការបានបញ្ជូនគាត់ឲ្យទៅធ្វើការនៅសហករណ៍បាត់ដំបង ចំណែកខ្ញុំក៏ត្រូវអង្គការបញ្ជូនទៅធ្វើការនៅតាលៃដែរ ។

នៅតាលៃ ភួង ផាញ់ បានណែនាំខ្ញុំឲ្យទាក់ទងឈ្មោះ សូ ភត្រា ដើម្បីស៊ើបមើលចិត្តគំនិតរបស់គាត់ចំពោះអង្គការបដិវត្តន៍កម្ពុជាយ៉ាងណាខ្លះ ។ បើឃើញថា គាត់មានគំនិតចង់សេរីរី លម្អៀងពីអង្គការបដិវត្តន៍កម្ពុជាខ្លះដែរហើយ ត្រូវធ្វើការទាក់ទាញគាត់ឲ្យរួមធ្វើបេសកកម្មទៅតាមផែនការអាមេរិកវាយកម្ពុជាជាថ្មី ព្រោះគាត់ជាបង្អែកមួយខាងកម្លាំងនៅក្នុងកងទ័ពបដិវត្តន៍កម្ពុជា នៅពេលដែលគាត់ចូលទៅកាន់ការក្នុងកងទ័ពបដិវត្តន៍ ។ ខ្ញុំបានជួបទាក់ទង សូ ភត្រា បានម្តង តែមិនបានធ្វើការអូសទាញគាត់ទេ ហើយក៏ខានបានជួបគាត់រហូតដល់អង្គការបានបញ្ជូនខ្ញុំឲ្យទៅធ្វើការនៅព្រែកប្រា ។ ហេតុនេះ ការទាក់ទងរបស់ខ្ញុំជាមួយ សូ ភត្រា ដើម្បីបញ្ចូលគាត់ឲ្យរួមធ្វើសកម្មភាពផ្ទៃក្នុងបដិវត្តន៍នេះ មិនបានសម្រេចទេ ។

ដោយសភាពជាក់ស្តែង ទោះក្នុងបច្ចុប្បន្ននេះក្តី ទៅអនាគតក្តី ក្រុមខ្ញុំមិនអាចរៀបចំទាក់ទងជាមួយខ្មែរដែលអាមេរិកត្រៀមបង្កប់ក្នុងបដិវត្តន៍កម្ពុជាសម្រាប់បំពេញផែនការវាយកម្ពុជាជាថ្មីបានទេ ។ ម្យ៉ាងទៀត ក្រុមខ្ញុំក៏មិនអាចធ្វើការរៀបចំខ្មែរទាក់ទងថ្មីរបស់ខ្លួនឲ្យចូលទៅក្នុងអង្គការបដិវត្តន៍ និងចូលក្នុងប្រជាជនបានទេ ហើយក៏មិនអាចបំពេញផែនការរបស់អាមេរិកវាយកម្ពុជាជាថ្មីបានដែរ ។ ហេតុនេះ ខ្ញុំត្រូវធ្វើសេចក្តីរាយការណ៍ជាបន្ទាន់ទៅ

ក្រសួងការបរទេសអាមេរិក និងទីបញ្ជាការ សេ.អ៊ី.អា អាមេរិក នៅក្រុងវ៉ាស៊ីនតោន។

សេចក្តីរាយការណ៍ដែលត្រូវធ្វើនេះ គឺរាយការណ៍ស្តីពីស្ថានភាពនៃបេសកកម្មរបស់ក្រុមខ្លួន ដែលបញ្ជូនមកពីអាមេរិក និងអំពីសភាពការណ៍ទូទៅក្នុងប្រទេសកម្ពុជាដែលក្រុមខ្លួនអាចក្តាប់បាននៅក្នុងពេលបច្ចុប្បន្ន។

១) ស្ថានការណ៍របស់ក្រុមខ្ញុំតាំងពីចូលមកដល់កម្ពុជា និងដល់ពេលចេញទៅរាយការណ៍ តែមកដល់ភ្លាមត្រូវអង្គការបដិវត្តន៍ចាត់តាំងឲ្យរស់នៅជាក្រុម ក្រោមការត្រួតពិនិត្យយ៉ាងតឹងរ៉ឹង។ ស្ថានភាពរស់នៅបែបនេះ គឺផ្ទុយស្រឡះពីការគ្រោងទុក គឺក្រុមខ្ញុំមិនអាចបែកគ្នាឲ្យទៅរស់នៅលាយឡំជាមួយប្រជាជន ឬអង្គការបដិវត្តន៍ដើម្បីរៀបចំជាខ្សែទាក់ទងគ្នាជាថ្មី និងចាប់ផ្តើមធ្វើសកម្មភាពទៅតាមផែនការបានទេ។ ម្យ៉ាងទៀត ក្រុមខ្ញុំក៏ដូចជាប្រជាជនកម្ពុជាទូទាំងប្រទេសដែរ គឺស្ថិតនៅក្រោមអង្គការវិន័យជានិច្ច មិនអាចទាក់ទងគ្នារហេតរហូតបានឡើយ ដោយផ្ទាល់ក្តី ដោយសំបុត្រក្តី ទាល់តែមានការចាត់តាំងត្រឹមត្រូវទើបធ្វើបាន។ ម្យ៉ាងទៀតមិនអាចកំណត់ថ្ងៃបានទាល់តែសោះថា ថ្ងៃណាក្រុមខ្ញុំអាចចេញទៅរស់នៅលាយឡំជាមួយប្រជាជនបាន។ ជាសរុបគឺខ្ញុំមិនអាចបំពេញបេសកកម្មទៅតាមផែនការទី១ ឲ្យបានសម្រេចទេ ក្នុងរយៈពេលប្រាំមួយខែនេះ ចាប់តាំងពីខែមិថុនា មកទល់នឹងខែធ្នូ ឆ្នាំ១៩៧៦។

២) រាយការណ៍អំពីការទាក់ទងរវាងក្រុមខ្ញុំ និងក្រុមដែលអាមេរិកបានបង្កប់ត្រៀមទុកក្នុងបដិវត្តន៍កម្ពុជា សម្រាប់ផែនការថ្មីនេះ ការទាក់ទងមិនអាចធ្វើបានទេ មូលហេតុមកពីមានការតឹងតែងក្នុងការធ្វើចលនា ក្នុងការស៊ើបសួរ និងមកពីក្រោយថ្ងៃ១៧ មេសា ១៩៧៥ អង្គការបដិវត្តន៍បានធ្វើចលនាផ្លាស់ប្តូរប្រជាជនគ្រប់ទីកន្លែងទាំងអស់ក្នុងប្រទេសកម្ពុជា។ ទោះជាយូរយ៉ាងណាក៏ក្រុមខ្ញុំមិនអាចធ្វើការទាក់ទងបានដែរ។ សុំឲ្យទីបញ្ជាការប្តូរយុទ្ធវិធី ដើម្បីធ្វើការទាក់ទងគ្នារវាងខ្សែចាស់នៅក្នុងបដិវត្តន៍ និងក្រុមខ្ញុំ បើមានផែនការថ្មី។

៣) រាយការណ៍ទូទៅអំពីសភាពការណ៍ក្នុងប្រទេសកម្ពុជា គឺអង្គការបដិវត្តន៍កម្ពុជាបានរៀបចំប្រជាជនទាំងអស់ឲ្យរស់នៅជាសមូហភាព ហើយសមូហភាពនីមួយៗមានកម្លាំងសាមគ្គីគ្រប់គ្រាន់ក្នុងការការពារខ្លួន ចំពោះការជ្រាតចូលពីក្រៅគ្រប់ផ្នែកទាំងអស់ ទាំងនយោបាយ សេដ្ឋកិច្ច និងកម្លាំងយោធា។

៤) សុំឲ្យប្តូរផែនការចាស់ចោល ហើយលើកផែនការថ្មីមួយទៀតជាបន្ទាន់ ទើបបើកការវាយប្រហារមកលើកម្ពុជាបានទាន់ពេលវេលា ហើយក្នុងផែនការនេះត្រូវចាប់ផ្តើមវាយប្រហារលើកម្ពុជា ដោយកម្លាំងអាវុធពីក្រៅចូលក្នុងកម្ពុជា និងបង្កើតឲ្យមានការបះបោរជ្រួលច្របល់ក្នុងផ្ទៃប្រទេសជាមួយគ្នាតែម្តង គឺមិនបាច់បង្កើតចលនាបះបោរត្រៀមទុកក្នុងកម្ពុជាមុនទេ។

ភួង ផាញ់ បានចាត់តាំងខ្ញុំរៀបចំចេញពីប្រទេសកម្ពុជាទៅប្រទេសយួន ដើម្បីទាក់ទងជាមួយភ្នាក់ងារ សេ.អ៊ី.អា អាមេរិកដែលបង្កប់ខ្លួនក្នុងអង្គការមនុស្សធម៌ និងអង្គការកាកបាទក្រហមអន្តរជាតិដែលចូលទៅធ្វើការនៅស្រុកយួន ដើម្បីធ្វើសេចក្តីរាយការណ៍ទៅក្រសួងការបរទេសអាមេរិក និងទីបញ្ជាការ សេ.អ៊ី.អា នៅក្រុងវ៉ាស៊ីនតោន។ ខ្ញុំ និង ញ៉ឹក វ៉េងហួរ ដែលត្រូវចេញទៅជាមួយគ្នា បានត្រៀមខ្លួនចេញតាំងពីនៅតាលៃ តែឱកាសមិនទាន់ហុចឲ្យ។ លុះដល់ថ្ងៃទី១០ ខែសីហា ឆ្នាំ១៩៧៦ អង្គការបានបញ្ជូនខ្ញុំ និង ញ៉ឹក វ៉េងហួរ ព្រមជាមួយមិត្តចំនួន៣០នាក់ទៅធ្វើការនៅព្រែកប្រា ជាប់នឹងមាត់ទន្លេបាសាក់។ ខ្ញុំ និង ញ៉ឹក វ៉េងហួរ បានត្រៀមសង្កេតរកឱកាស និងប្រកបេញទៅស្រុកយួនម្តងទៀត និងបានសម្រេចចិត្តចេញនៅម៉ោងមួយភ្លឺថ្ងៃទី១៨ ខែសីហា ឆ្នាំ១៩៧៦ ដោយដើរកាត់សំដៅទៅទន្លេមេគង្គ រួចចុះបណ្តែតខ្លួនតាមទឹកទៅស្រុកយួនតែម្តង។ ខ្ញុំ និង ញ៉ឹក វ៉េងហួរ បានដើរទៅដល់មាត់ទន្លេមេគង្គនៅពេលទៀបភ្លឺល្មម ហើយសម្ងំពួនចាំដល់ពេលយប់ងងឹតទើបចុះបណ្តែតតាមទឹកទៅក្រោមអស់រយៈពេលមួយយប់ បានទៅដល់ដីឥដ្ឋនៅម៉ោងជិត៥ភ្លឺ ថ្ងៃទី១៩ ខែសីហា ឆ្នាំ១៩៧៦ ហើយបានសម្រេចសម្រាកពួនចាំដល់ពេលយប់ងងឹតទើបចុះជាបន្តទៅទៀត ប៉ុន្តែត្រូវបានបងប្អូននៅសហករណ៍ដីឥដ្ឋបានឃើញ និងចាប់បញ្ជូនខ្លួនប្រគល់ឲ្យអង្គការនៅទីនោះនៅវេលាម៉ោងជាង៦ល្ងាច។ អង្គការបានឃុំខ្លួនខ្ញុំ និង ញ៉ឹក វ៉េងហួរ នៅកៀនស្វាយមួយយប់ និងបានបញ្ជូនយើងទាំងពីរមកភ្នំពេញនៅពេលព្រឹកថ្ងៃទី២០ ខែសីហា ឆ្នាំ១៩៧៦។ **ឆេង ខ៉េង**

# វគ្គបណ្តុះបណ្តាលវិធីសាស្ត្របង្រៀន ប្រវត្តិស
# ដល់គ្រូមូលដ្ឋាន និងពិធីសម្ពោធពាក្យស្លោក នៅវិទ្យា










# ាស្ត្រកម្ពុជាប្រជាធិបតេយ្យ (ពីឆ្នាំ១៩៧៥-៧៩)
# ល័យ ហ៊ុន សែន ត្រពាំងប្រាសាទ ខេត្តឧត្តរមានជ័យ










# វគ្គបណ្តុះបណ្តាលវិធីសាស្ត្របង្រៀន ប្រវត្តិស
# ដល់គ្រូមូលដ្ឋាន និងពិធីសម្ពោធពាក្យស្លោក









# ាស្ត្រកម្ពុជាប្រជាធិបតេយ្យ (ពីឆ្នាំ១៩៧៥-៧៩) នៅវិទ្យាល័យ បន្ទាយឆ្មារ ខេត្តបន្ទាយមានជ័យ









# វគ្គបណ្តុះបណ្តាលវិធីសាស្ត្របង្រៀន ប្រវត្តិស
# ដល់គ្រូមូលដ្ឋាន និងពិធីសម្ពោធពាក្យស្លោក









# ាស្ត្រកម្ពុជាប្រជាធិបតេយ្យ (ពីឆ្នាំ១៩៧៥-៧៩) នៅវិទ្យាល័យ សំពៅលូន ខេត្តបាត់ដំបង









# វគ្គបណ្តុះបណ្តាលវិធីសាស្ត្របង្រៀន ប្រវត្តិស ដល់គ្រូមូលដ្ឋាន និងពិធីសម្ពោធពាក្យស្លោ









# ាស្ត្រកម្ពុជាប្រជាធិបតេយ្យ (ពីឆ្នាំ១៩៧៥-៧៩) ក នៅវិទ្យាល័យ កំរៀង ខេត្តបាត់ដំបង









# វគ្គបណ្តុះបណ្តាលវិធីសាស្រ្តបង្រៀន ប្រវត្តិស
# ដល់គ្រូមូលដ្ឋាន និងពិធីសម្ពោធពាក្យស្លោក









# ាស្ត្រកម្ពុជាប្រជាធិបតេយ្យ (ពីឆ្នាំ១៩៧៥-៧៩)
# ន នៅវិទ្យាល័យ ប្រមោយ ខេត្តពោធិ៍សាត់









# ចម្លើយសារភាពរបស់ សាយ អាត សមាជិកកងតូច កងចល័តនិមិត្ត ភូមិភាគពាយ័ព្យ

***ដកស្រង់ចេញពីឯកសារលេខ J០០០៨៦***

*សាយ អាត អាយុ២៣ឆ្នាំ (ក្នុងឆ្នាំ១៩៦៩) មានស្រុកកំណើតនៅភូមិត្រាង ឃុំបន្ទាយនាង ស្រុកមង្គលបូរី តំបន់៣ ។ អាត ត្រូវបានអង្គការចាប់ខ្លួននៅថ្ងៃទី១២ ខែវិច្ឆិកា ឆ្នាំ១៩៧៧ ។ មុនពេលអង្គការចាប់ខ្លួន អាត មាននាទីជាសមាជិកកងតូច កងចល័តនិមិត្ត ភូមិភាគពាយ័ព្យ ។ កំណត់ហេតុរបស់ អាត ត្រូវបានធ្វើចប់ នៅថ្ងៃទី៣ ខែធ្នូ ឆ្នាំ១៩៧៧ ដោយអ្នកសួរឈ្មោះ ខន ព្រមទាំងមានស្នាមមេដៃទទួលស្គាល់ ដោយសាមីខ្លួន (អាត) ផ្ទាល់ ។ សេចក្តីកំណត់ហេតុអំពីប្រវត្តិរបស់ អាត ត្រូវបានសរសេរឡើងដោយដៃ និងវាយអង្គុលីលេខ មានចំនួនសរុប២៨ទំព័រ ដែលបានរៀបរាប់ពីសកម្មភាពរបស់ អាត ចាប់តាំងពីឆ្នាំ១៩៦៩ រហូតដល់ថ្ងៃអង្គការចាប់ខ្លួន ។ ខាងក្រោមនេះគឺជាសេចក្តីសង្ខេបដែលដកស្រង់ចេញពីសេចក្តីកំណត់ហេតុរបស់ អាត ៖*

*នៅឆ្នាំ១៩៦៩ អាត បានស៊ីឈ្នួលធ្វើស្រែឲ្យគេ ហើយរយៈពេលមួយខែទើបត្រឡប់មកលេងផ្ទះម្តង ។ មកដល់ឆ្នាំ១៩៧១ អាត បានចូលធ្វើទាហាននៅខេត្តបាត់ដំបងជាមួយមនុស្ស២០នាក់ផ្សេងទៀត ។ ពេលនោះ អាត ពាក់ស័ក្តិ១ ។ នៅឆ្នាំ១៩៧៣ សេង សំអ៊ាត, លន់ និង អាន បានបំពាក់ស័ក្តិ២ឲ្យ អាត រួចបាន ចាត់តាំង អាត, ថែន, រ៉ុន, យឿម, ហេង ភី និង លាប ឲ្យធ្វើជាគិញក្នុងបន្ទាយប្រជាយុទ្ធកភ្នំតូច ព្រមទាំងឲ្យកាន់កាំភ្លើងខ្លីមួយដើមសម្រាប់ការពារខ្លួនពេលដើរក្តាប់សកម្មភាពក្រុមខ្មែរក្រហម ។ ក្រោយពីបានចាត់តាំងរួច សេង សំអ៊ាត, លន់ និង អាន បានខទ្ទេសនាម អាត ឲ្យបក្ខពួកខ្សែចាស់របស់គាត់ទាក់ទងស្គាល់គ្នា មានឈ្មោះ គាំ, មុយ, ឃ្វី, វិន និង ឈួត ។ ទន្ទឹមនោះ លន់ និង អាន បានចាត់តាំង វិន និង ឈួត ឲ្យចូលទៅបង្កប់ខ្លួនក្នុងបដិវត្តន៍ នៅតំបន់៥ (សូមបញ្ជាក់ ឈ្មោះ សេង សំអ៊ាត ជាចៅហ្វាយខេត្តបាត់ដំបង, លន់ ជាទាហានស័ក្តិ៣ ភ្នំស្វាយ និង ឈ្មោះ អាន ជាបញ្ជាការកងប្រជាយុទ្ធកនៅបន្ទាយភ្នំតូច) ។ កន្លះខែក្រោយមក ឈួត និង វិន បានចូលទៅបង្កប់ខ្លួនក្នុងទឹកដីរំដោះ នៅតំបន់៥ មាននាទីជាកម្មាភិបាល ចលនា*



*កម្មាភិបាលខ្មែរក្រហមនៅតាមមន្ទីរ កំពុងចាំងសម្អាតស្មៅ*

មុខ ហើយបានផ្តាំផ្ញើ អាត ឲ្យទៅជួបនៅភូមិបឹងវែង តាមរយៈឈ្មោះ ង៉ឿន ជាប្រជាយុទ្ធកបន្ទាយភ្នំតូច ។ ពេលនោះ អាត, ថែន, មុយ និង ឃ្វី ក៏បានទៅជួប ឈួត និង វិន តាមការណាត់ ។ បន្ទាប់មកទៀត អាត បានសួរ ឈួត អំពីសកម្មភាពខ្លះៗរបស់កងទ័ពបដិវត្តន៍ និងអំពីសកម្មភាពរបស់ប្រជាជនថា តើប្រជាជនដែលរស់នៅទីនោះបានរៀបចំបាយទឹកទទួលបក្ខពួកខ្មែរក្រហមដែរឬទេ? ឈួត បានឆ្លើយថា ប្រជាជនបានរៀបចំបាយទឹកទទួលខ្មែរក្រហមពិតមែន ហើយកងទ័ពបដិវត្តន៍បានបោះជំរំនៅភូមិថ្វាន់ទ្រេត ភូមិអំពិលទឹក និងភូមិ ស្រែព្រីង ។ ក្រោយមក អាន បានចាត់តាំង អាត និង ថែន ឲ្យទៅទាក់ទងឈ្មោះ លន់ ដើម្បីដឹកនាំទាហានទៅសៀមព្រមទាំងនាំប្រជាជននៅភូមិតាសល់ និងភូមិអន្ទុងត្នួ ទៅដាក់នៅបន្ទាយភ្នំតូច ។ ដប់ថ្ងៃក្រោយមក អាត, ហេង និង យឿម បានទៅជួប ឈួត និង វិន នៅភូមិបឹងវែងដដែល ដោយបានលើកយកមតិណែនាំរបស់ អាន មកប្រាប់ដល់អ្នកទាំងពីរឲ្យតាមដានខ្សែទាក់ទងដែលមករស់នៅក្នុងដីទាហាន ព្រមទាំងតាមដានកន្លែងដែលកងទ័ពបដិវត្តន៍មកធ្វើការនាពេលខាងមុខនេះ ។

នៅខែមីនា ឆ្នាំ១៩៧៣ អាត បានចាប់ប្រជាជន៤នាក់រស់នៅភូមិអូរញ៉ែរ ដែលបានយកអង្ករឲ្យខ្មែរក្រហម ។ នៅខែខសភាឆ្នាំដដែល អាត, ថែន, មុយ និង ឃ្វី បានមកជួប ឈួត និង វិន ម្តងទៀត ប៉ុន្តែពេលនោះបក្ខពួករបស់ អាត មិនទាន់បានជួបគ្នាទេ បែរជាជួបកងទ័ពបដិវត្តន៍មុន ហើយកងទ័ពបដិវត្តន៍បានបាញ់ត្រូវ ឃ្វី និង មុយ រីឯ អាត និង ថែន បានរត់គេចខ្លួន ។ នៅខែមិថុនា ឆ្នាំ១៩៧៣ ឈួត និង វិន បានសរសេរសំបុត្រមួយច្បាប់ផ្ញើទៅ អាត តាមរយៈឈ្មោះ ខ ដែលពីមុនធ្លាប់ធ្វើទាហានជាមួយ អាត ។ ខ្លឹមសារសំបុត្រគឺឲ្យ អាត ទៅជួបក្រុមខ្លួន (ឈួត និង វិន) នៅភូមិស្វែងគង់ ។ ក្រោយមក អាត, ហេង និង គាំ ក៏បានទៅជួបតាមការកំណត់ ។ ពេលនោះ ឈួត និង វិន បានរាយការណ៍ថា ខ្មែរក្រហមបានកៀរប្រជាជនចូលទៅព្រៃអស់ហើយ រីឯការទាក់ទងរបស់ខ្មែរក្រហមនៅខាងក្នុង គឺតាមរយៈឈ្មោះ ភ្លោះ និង ដិល នៅភូមិចម្ការចេក និងឈ្មោះ យុទ្ធ និង ព្រុំ នៅភូមិថ្នល់បត់ ។

ក្រោយមកទៀត អាត និងបក្ខពួកបីនាក់ទៀតបានទៅរាយការណ៍ឲ្យ អាន ហើយពេលនោះ អាន បានហៅ អាត, ថែន និង លន់ មកប្រជុំដែលមានខ្លឹមសារដូចតទៅ ៖ អាន និង លន់ បានលើកឡើងថា យើងត្រូវប្រមូលកងកម្លាំងទាហានដើម្បីទៅជួយប្រជាជនដែលខ្មែរក្រហមកៀរយកទៅទុកក្នុងព្រៃ ប៉ុន្តែនៅពេលចប់ការប្រជុំ អង្គប្រជុំសម្រេចថា ចាំរដូវប្រាំងនឹងទៅជួយប្រជាជនទាំងនោះ ពីព្រោះពេលនេះជារដូវវស្សា ទឹកច្រើន ។

នៅខែកុម្ភៈ ឆ្នាំ១៩៧៤ អាត, ថែន, វ៉ុន និង គាំ បានទៅជួប ឈួត និង វិន ហើយពេលនោះ អាត បានសួរអ្នកទាំងពីរអំពីស្ថានភាពរបស់ប្រជាជនថា សុខទុក្ខយ៉ាងណា? ឈួត បានឆ្លើយថា ស្ថានភាពរបស់ប្រជាជនកំពុងតែច្របូកច្របល់ ហើយប្រជាជនមួយចំនួនបានរត់ទៅទឹកដីរំដោះ រីឯខ្សែទាក់ទងរបស់ខ្មែរក្រហមខាងក្នុងវិញនៅមានច្រើនទៀត ។ ឈួត បានសួរ អាត វិញថា តើកម្លាំងគិញនៅខាងក្នុងសព្វថ្ងៃនៅសល់ប៉ុន្មាននាក់ដែរ? អាត បានប្រាប់ថា នៅសល់ខ្លះ ពីព្រោះខ្មែរក្រហមទើបតែបាញ់ស្លាប់អស់ពីរនាក់នាពេលថ្មីៗនេះ ។ ឈួត បានផ្តាំផ្ញើ អាន ឲ្យរៀបចំចាត់តាំងកម្លាំងគិញបន្ថែមទៀត ពីព្រោះកងយោធាខ្មែរក្រហមច្រើនណាស់ ដូច្នេះយើងត្រូវតែបន្ថែមកម្លាំងគិញ ។ រហូតដល់ខែមិថុនាឆ្នាំដដែល អាត បានទៅពិភាក្សាជាមួយ អាន ពីការចាត់តាំងកម្លាំងគិញ ហើយ អាន បាននិយាយថា គម្រោងរបស់ខ្លួនគឺត្រូវបន្ថែម១៨នាក់ទៀត ដើម្បីបគ្រប់ឲ្យបាន២០នាក់ រួមទាំងកម្លាំងចាស់ ។ មួយរយៈក្រោយមក ឈួត និង វិន បានសួរ អាត អំពីការចាត់តាំងកម្លាំងគិញ ។ អាត បានឆ្លើយថា មិនទាន់បានចាត់តាំងទេ ប៉ុន្តែគម្រោងនឹងចាប់ផ្តើមនាពេលខាងមុខនេះហើយ ។ ឈួត បានប្រាប់បន្ថែមថា ខ្សែទាក់ទងខ្មែរក្រហមនៅដីយើងមាន៦នាក់ គឺនៅភូមិព្រៃទទឹង២នាក់ នៅភូមិឃិឡិ ២នាក់ និងនៅភូមិគោកទ្រលាប់ ២នាក់ទៀត ។ បន្ទាប់មក អាត បានទៅរាយការណ៍ឲ្យ អាន បានដឹងអំពីខ្សែទាក់ទងរបស់ខ្មែរក្រហមទាំង៦នាក់នោះ ។ បន្ទាប់មក អាន បានចាត់តាំង អាត និងបក្ខពួកឲ្យទៅរកកម្លាំងថ្មី១៨នាក់ទៀត ដើម្បីកសាងជាកម្លាំងគិញថ្មីបន្ថែមលើកម្លាំងចាស់ដែលមាន៦នាក់រួចហើយ ។ អ្នកទាំង១៨នេះ ត្រូវបាន អាត យកមកបន្ទាយភ្នំតូច ។

នៅខែសីហា ឆ្នាំ១៩៧៤ អាត, អាន និង លន់ ត្រូវបានថ្នាក់លើហៅឲ្យទៅជួបនៅបន្ទាយភ្នំតូច ដើម្បីឲ្យចុចឈ្មោះអ្នកដែលត្រូវ

ចាត់តាំងឲ្យធ្វើគិញបន្ថែមទៀត ។ អាន ក៏បានចុចយកឈ្មោះដូចតទៅនេះ ៖ ឈ្មោះ ភី, លាប, ឈឹម, ទី, សេ, សែន, ឆែ, ផាត, ឈេន, វេត, ក្រិត, សឹត, វិន និង មឿន ។ ឈ្មោះ សេង សំអ៊ាត, អាន និង លន់ ក៏បានប្រកាសចាត់តាំងអ្នកទាំង១៨នាក់នោះ ជាខ្មែរគិញទាំងអស់គ្នា រួចបានណែនាំឲ្យធ្វើការទាក់ទងស្គាល់គ្នា ។ ក្រោយមក អាន បានបែងចែកជា៤ក្រុម ដែល ក្រុមទី១) មានឈ្មោះ ភី, ទី, សេ, សែន និង វីន ឲ្យទៅបង្កប់ខ្លួននៅភូមិអូរញ៉ែរ ។ ក្រុមទី២) មានឈ្មោះ ឈឹម, ឆែ, ផាត, សឹត និង មឿន ឲ្យទៅបង្កប់ខ្លួននៅភូមិព្រៃទទឹង ។ ក្រុមទី៣) មានឈ្មោះ វេត, ឈេន, គាំ, ក្រិត និង លាប ឲ្យទៅបង្កប់ខ្លួននៅភូមិដងរុន និងក្រុមចុងក្រោយ មានឈ្មោះ អាត, ហេង, ថែន, វ៉ុន និង យឿម ឲ្យទៅប្រចាំការនៅក្នុងបន្ទាយភ្នំតូច ។

**ភារកិច្ចរបស់ក្រុមទាំង៤ដែលត្រូវធ្វើរួមមាន៖**

១) ពិនិត្យតាមដានខ្មែរក្រហមតាមភូមិ

២) ពិនិត្យមើលអំពីសកម្មភាពរបស់ប្រជាជន ក្រែងលោប្រជាជនយកអង្ករទៅឲ្យខ្មែរក្រហម ។

ចុងខែកញ្ញា ឆ្នាំ១៩៧៤ អាន និង លន់ បានធ្វើការចាត់តាំងម្តងទៀត ដោយឲ្យក្រុមរបស់ អាត ធ្វើជា សេ.អ៊ី.អា វិញ ហើយឲ្យធ្វើការស៊ើបអង្កេតជាសម្ងាត់ និងក្តាប់តែសកម្មភាពប៉ុណ្ណោះ ។ នៅចុងខែមីនា ឆ្នាំ១៩៧៥ កងទ័ពបដិវត្តន៍បានវាយចូលមកបន្ទាយភ្នំតូច បណ្តាលឲ្យកម្លាំងប្រជាយុទ្ធរបស់ អាន រត់បែកគ្នាអស់ រីឯ អាន បានរត់ទៅនៅបន្ទាយភ្នំស្វាយជាមួយ លន់ វិញ ។ បន្ទាប់មក អាន និង លន់ បានឲ្យ អាត ទៅហៅកម្លាំងគិញទាំងអស់ដែលនៅតាមភូមិមកជួបជុំគ្នានៅបន្ទាយភ្នំស្វាយ ដើម្បីពិភាក្សាគ្នារកវិធីទប់ទល់នឹងខ្មែរក្រហម ។ តាមមតិរបស់ លន់ បានលើកឡើងថា ប្រសិនបើយើងនៅទប់ទល់ជាមួយខ្មែរក្រហមតទៅទៀត យើងក៏ទប់ទល់មិនឈ្នះដែរ ដូច្នេះយើងត្រូវតែបែងចែកកងកម្លាំងជាពីរផ្នែក ៖

ផ្នែកទី១ : មានកម្លាំងទាហានមួយវរៈសេនាតូច ៣០០នាក់ គឺយើងត្រូវបែកចែកជាពីរក្រុមទៀត ៖

◆ ក្រុមទី១) មានកម្លាំងទាហាន១៥០នាក់ ឲ្យទៅបង្កប់ខ្លួននៅលើកំពូលភ្នំស្វាយ ហើយត្រូវលាក់ខ្លួននៅក្នុងរូងភ្នំ ។

◆ ក្រុមទី២) កម្លាំងទាហាន១៥០នាក់ ឲ្យទៅលាក់ខ្លួននៅក្នុងរូងភ្នំធំ ។

ផ្នែកទី២ : មានកម្លាំងគិញ និង សេ.អ៊ី.អា ត្រូវទៅបង្កប់ខ្លួននៅតាមភូមិស្ម័យត្រាណ ហើយលាក់ខ្លួនជាមួយប្រជាជនដែលរស់នៅទីនោះ ។

ការរៀបចំបែបនេះ គឺដើម្បីត្រៀមកម្លាំងនៅពេលដែលកងទ័ពបដិវត្តន៍វាយឈ្នះ យើងត្រូវបញ្ជាឲ្យកងកម្លាំងយើងវាយបកពីក្រោយវិញ ។ ក្រោយប្រជុំចប់មិនទាន់បានប៉ុន្មានថ្ងៃផង កងទ័ពបដិវត្តន៍ក៏បានវាយលុកចូលមក ។ ពេលនោះ អាត បានរង់ចាំមើលកងកម្លាំងរបស់ខ្លួនវាយបកមកកងទ័ពបដិវត្តន៍វិញ ប៉ុន្តែមិនមានកងកម្លាំងណាវាយបកទៅវិញទេ ។ ក្រោយថ្ងៃរំដោះបានបីថ្ងៃ អាត និង ថែន ក៏បានទៅជួប ឈួត និង វិន នៅភូមិឃិឡិ ស្រាប់តែ ឈួត បានសួរ អាត ថាកងកម្លាំងយើងបាត់ទៅណាអស់ហើយ ពេលនោះ អាត បានប្រាប់ថា កងកម្លាំងប្រជាយុទ្ធកយើងបានបែកបាក់គ្នាអស់ហើយ តាំងតែពីមុនរំដោះម៉្លេះ រីឯកម្លាំងក្រៅពីនេះ អាន និង លន់ បានរៀបចំបង្កប់នៅលើភ្នំស្វាយ ។

បីថ្ងៃក្រោយមក ឈួត និង វិន បានបបួល អាត ទៅជួប លន់ ដើម្បីពិភាក្សាគ្នាអំពីសកម្មភាពផ្សេងៗ ដែលត្រូវធ្វើបន្តទៅមុខទៀត ។ ភ្លាមនោះ លន់ បានសួរ ឈួត អំពីស្ថានភាពកងទ័ពបដិវត្តន៍ថា តើពេលណាកម្លាំងយើងអាចវាយបកបាន? ឈួត បានឆ្លើយថា ពេលនេះយើងមិនអាចវាយបានទេ ពីព្រោះកងទ័ពបដិវត្តន៍នៅរាយស៊ើរគ្រប់ភូមិ ដូច្នេះយើងពិបាកក្នុងការវាយបក ។ ពេលនោះ លន់ បានបន្ថែមថា ប្រសិនបើយើងវាយកម្លាំងបដិវត្តន៍មិនបានទេ យើងមានតែរំដោះកងកម្លាំងរបស់យើងឲ្យរត់ចូលទៅក្នុងព្រៃនៅភ្នំម៉ាឡៃ ព្រោះកងកម្លាំងរបស់យើងនៅលើភ្នំស្វាយអស់អង្ករហូបហើយ ។ ក្រោយប្រជុំចប់ ក៏មូលមតិគ្នារៀបចំផែនការដូចតទៅ ៖

**សកម្មភាពក្រោយរំដោះ**

១) យកចានក្នុងសហករណ៍ទៅចោលក្នុងអូរ

២) យកនង្គ័លភ្ជួរទៅបោះចោលក្នុងបឹង

៣) លួច នឹម និង នង្គ័ល យកទៅដុតចោល

នៅពាក់កណ្តាលខែឧសភា ឆ្នាំ១៩៧៥ អង្គការបានជ្រើសរើសយុវជន និងយុវនារីនៅស្រុកមង្គលបូរី ឲ្យទៅធ្វើកងចល័តនៅ

និមិត្ត ។ កម្លាំងរបស់ អាត មានចំនួន២២នាក់ បានទៅជាមួយដែរ ។ ពេលនោះ អង្គការបានចាត់តាំង ឈួត និង វិន ឲ្យក្តាប់អ្នកភូមិទាំងមូល (ចំនួនមនុស្សក្តាប់មិនបាន) ។ ក្រោយមកទៀត អង្គការបានចាត់តាំងអ្នកទាំងពីរឲ្យជ្រើសរើសសមាសភាពកាន់កងតូចធំ ។ នៅឃុំបន្ទាយនាង ឈួត បានចាត់តាំង លឿន ឲ្យកាន់វរៈសេនាតូចជាមួយនឹងប្អូនរបស់គាត់ ចំណែកឯ ថែន កាន់កងធំទី១, វ៉ុន អនុកងធំទី១, អាត កាន់កងធំទី២ ហើយ សេ, ហេង, យឿម កាន់កងតូចក្រៅពីនេះនៅយុវជនចល័តទាំងអស់ ។ សូមបញ្ជាក់ថា កងកម្លាំងរបស់ អាត គឺសុទ្ធតែលាក់ប្រវត្តិរូបទាំងអស់ មិនអាចដាក់ឈ្មោះជាទាហានបានទេ គឺដាក់ជាកសិករគ្រប់ៗគ្នា ។ នៅចុងខែមិថុនាក្នុងឆ្នាំ១៩៧៥ ឈួត និង វិន បានទៅភ្នំម៉ាឡៃដើម្បីរកថ្នាំ ។ ពេលត្រឡប់មកវិញ អ្នកទាំងពីរបានប្រាប់ អាត និង លឿន ថាកាលពីទៅភ្នំម៉ាឡៃថ្ងៃមុន បានជួប លន់ និង អាន ហើយ លន់ និង អាន បានប្រាប់ថា សព្វថ្ងៃនេះបានទាក់ទងជាមួយកម្លាំង អ៊ិន តាំ ។ ប្រសិនបើខាងបក្ខពួកយើងចង់ទៅទាក់ទង គឺមិនចាំបាច់ទៅផ្ទាល់ក៏បាន គឺយើងអាចទាក់ទងតាមរយៈ សារ៉ាត ពីព្រោះ សារ៉ាត ជាខ្សែរបស់ អ៊ិន តាំ ។ នៅខែសីហា ឆ្នាំ១៩៧៥ ដដែល អាត, លឿន និង ថែន កសាងកម្លាំងបន្ថែមបាន៦នាក់ទៀត ដែលសុទ្ធសឹងជាអតីតទាហានដែលបម្រុងរត់ទៅស្រុកថៃ ។ ក្រោយពីបានកសាងរួចរាល់ហើយ បក្ខពួកទាំង៦នាក់នោះ ត្រូវបានប្រគល់ភារកិច្ចឲ្យធ្វើ រួមមាន៖ បំផ្លាញចប និងឧបករណ៍ធ្វើស្រែផ្សេងៗ ជួយកសាងកម្លាំងបន្ថែមទៀត ព្រមទាំងពិនិត្យមើលសកម្មភាព ប្រវត្តិរូបរបស់ប្រជាជនមុននឹងកសាង ។

**អំពីសកម្មភាព អាត និងបក្ខពួករបស់ អាត ក្នុងរយៈឆ្នាំ១៩៧៥**

១) បំផ្លាញចប២០ និងចានបាយ៤០ ដោយយកទៅទម្លាក់ចោលនៅក្នុងស្ទឹង ។

២) បំផ្លាញស្រូវអស់៧០ហិកតា ដោយបង្ហូរទឹកចោលឲ្យស្រូវស្កក ជាន់ស្រូវពន្លិចភក់ ព្រមទាំងដកស្រូវបោះចោល ។

៣) លើកភ្លឺស្រែឲ្យវៀច និងកុំឲ្យហាប់ណែន ។

នៅខែកុម្ភៈ ឆ្នាំ១៩៧៦ អាត និង លឿន កសាងកម្លាំងបានពីរនាក់ទៀត រួមមានឈ្មោះ សារុន អតីតប្រជាយុទ្ធក បច្ចុប្បន្នកម្មករលីបាវ នៅរោងម៉ាស៊ីនកិនស្រូវគោកធំ និងឈ្មោះ ហាក់ ជាកម្មកររោងម៉ាស៊ីនកិនស្រូវនៅភូមិគោកធំ ។ បន្ទាប់មក អាត និង លឿន បានដាក់ផែនការឲ្យអ្នកទាំងពីរធ្វើ ដូចទៅៈ យកសំបកបាវទៅកប់ចោលក្នុងអន្លង់ម សារ៉េម៉ាស៊ីនកិនស្រូវដើម្បីកិនអង្ករឲ្យខូច និងបំផ្លាញឧបករណ៍ធ្វើស្រែផ្សេងៗ ។ នៅចុងខែឧសភា ឆ្នាំ១៩៧៦ សារ៉ាត បានហៅ អាត និង លឿន សួរអំពីសភាពការនៅខាងក្នុងយ៉ាងដូចម្តេចហើយ ពេលនោះ អាត បានប្រាប់ថាកងទ័ពបដិវត្តន៍នៅការដ្ឋានមានមិនច្រើនទេ ដូច្នេះយើងអាចវាយបកវិញបានហើយ អ៊ីចឹង សារ៉ាត អាចទៅប្រាប់ អ៊ិន តាំ ឲ្យត្រៀមកម្លាំងវាយចុះ ។ ក្រោយពីពិភាក្សាគ្នាចប់ហើយ អង្គការបានចាត់តាំង អាត និង លឿន ឲ្យទៅបិទភ្លឺស្រែនៅភូមិគោកធំ ហើយពេលនោះ អ្នកទាំងពីរ ក៏បានទៅហៅបក្ខពួកមកប្រជុំនៅខាងត្បូងភូមិដើម្បីដាក់ផែនការថ្មី គឺកាប់ដីក្នុងស្រែយកទៅបិទភ្លឺឲ្យដោយទាំងសន្ធងផង និងបិទភ្លឺឲ្យមានប្រហោងនៅខាងក្រោម ។ មួយរយៈក្រោយមក សារ៉ាត បានហៅ អាត និង លឿន មកជួបម្តងទៀតដើម្បីពិភាក្សាអំពីការកសាងកម្លាំង ។ សារ៉ាត បានណែនាំ អាត និង លឿន ថា ត្រូវប្រាប់ ពីអំពីផែនការរបស់យើងឲ្យកម្លាំងថ្មីនេះដឹងថា យើងមានកម្លាំងវាយមកពីខាងក្រៅ នៅខែវិច្ឆិកា ឆ្នាំ១៩៧៦ នេះផង ។ ប្រសិនបើឮស្នូរកាំភ្លើងមកពីខាងក្រៅ ត្រូវតែប្រមូលកម្លាំងមកជួបជុំគ្នានៅព្រៃខាងត្បូងភូមិនិមិត្ត ហើយនៅពេលកម្លាំងខាងក្រៅចូលមកដល់ យើងត្រូវរត់ចូលទៅយកអាវុធដើម្បីរួបរួមកម្លាំងគ្នា ។ បន្ទាប់មក អាត និង លឿន ក៏បានយករឿងទាំងអស់នេះទៅផ្សព្វផ្សាយជាសម្ងាត់ឲ្យកងកម្លាំងទាំងអស់នោះបានដឹង ។ រហូតមកដល់ខែវិច្ឆិកា ឆ្នាំ១៩៧៦ ផែនការទាំងអស់នេះមិនទាន់បានប្រព្រឹត្តផង ស្រាប់តែកងទ័ពបដិវត្តន៍វាយចូល ភ្នំម៉ាឡៃមុន ហើយវាយយកបានទាំងឡាន គ្រឿងម៉ាស៊ីន និង ស្បៀងមួយចំនួនទៀត រីឯបក្ខពួក អ៊ិន តាំ បានរត់គេចខ្លួនអស់ពីលើភ្នំម៉ាឡៃ ហើយការទាក់ទងគ្នាខាងក្រៅក៏ត្រូវបានដាច់ ។ ទោះបីជាកងទ័ពបដិវត្តន៍បានវាយរហូតដល់បែកបាក់ទាំងកម្លាំងខាងក្នុង និងខាងក្រៅយ៉ាងណាក្តី ប៉ុន្តែសកម្មភាពរបស់ អាត និងបក្ខពួកនៅតែបន្ត ធ្វើជាបន្តបន្ទាប់ដើម្បីប្រឆាំងនឹងកងកម្លាំងបដិវត្តន៍ ព្រមទាំងបន្តធ្វើសកម្មភាពបំផ្លិចបំផ្លាញបដិវត្តន៍ជាប្រចាំ រហូតដល់ថ្ងៃអង្គការចាប់ខ្លួន អាត បាននៅថ្ងៃទី១១ ខែវិច្ឆិកា ឆ្នាំ១៩៧៧ ។ **ហូ ថុនា**

# ការិយាល័យព័ត៌មានសាធារណៈ

*"ការិយាល័យព័ត៌មានសាធារណៈ" របស់មជ្ឈមណ្ឌលឯកសារកម្ពុជាបានបើកបម្រើជូននិស្សិត អ្នកស្រាវជ្រាវ បុគ្គលិករាជការ និងអង្គការក្រៅរដ្ឋាភិបាល និងបុគ្គលទាំងឡាយដែលមានចំណាប់អារម្មណ៍ចង់យល់ដឹងអំពីប្រវត្តិសាស្ត្ររបបកម្ពុជាប្រជាធិបតេយ្យ និងព្រឹត្តិការណ៍វិវឌ្ឍរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ឬសាលាក្តីខ្មែរក្រហម ។*

*មជ្ឈមណ្ឌលឯកសារកម្ពុជាជាកន្លែងប្រមូលផ្តុំ និងចងក្រងឯកសារអំពីរបបកម្ពុជាប្រជាធិបតេយ្យបានច្រើនបំផុត ។ ឯកសារនៅមជ្ឈមណ្ឌលឯកសារកម្ពុជាមានប្រាំប្រភេទ ។ ប្រភេទឯកសារទីមួយគឺឯកសារជាក្រដាសសន្លឹកដែលមានចំនួនជិតមួយលានទំព័រ ។ ប្រភេទឯកសារទីពីរគឺជាបទសម្ភាសន៍ដែលបុគ្គលិកមជ្ឈមណ្ឌលឯកសារកម្ពុជាចុះទៅធ្វើសម្ភាសន៍ជាមួយជនរងគ្រោះនិងអតីតកម្មាភិបាលខ្មែរក្រហម ។ ប្រភេទឯកសារទីបីគឺជារូបថតទាក់ទងទៅនឹងសម័យខ្មែរក្រហម ។ ប្រភេទឯកសារទីបួនគឺជាឯកសារទាក់ទងទៅនឹងការធ្វើផែនទីរណ្តៅសាកសព និងទីតាំងសម្លាប់របស់ខ្មែរក្រហម និងឯកសារប្រភេទទីប្រាំគឺជាខ្សែភាពយន្តឯកសារដែលបានផលិតឡើងក្នុងរបបខ្មែរក្រហម និងសម័យក្រោយមកទៀត ។*

*តាមរយៈការិយាល័យព័ត៌មានសាធារណៈ សាធារណជនអាចអាននិងស្រាវជ្រាវឯកសារទាំងនេះបាន ។ ឯកសារខ្លះទៀតរួមមាន ៖ ប្រវត្តិរូបកម្មាភិបាលខ្មែរក្រហម ចម្លើយសារភាព កំណត់ហេតុរបស់បក្ស ទូរលេខឆ្លើយឆ្លងព័ត៌មានដែលបានមកពីការសម្ភាសន៍ជាមួយអតីតកម្មាភិបាលខ្មែរក្រហម និងទិន្នន័យគន្ថនិទ្ទេសបង្ហាញពីរណ្តៅសាកសព ទីតាំងគុក និងបូជនីយដ្ឋានប្រល័យពូជសាសន៍ ។*

*ការិយាល័យព័ត៌មានសាធារណៈមានទីតាំងនៅអគារលេខ៦៦ មហាវិថីព្រះសីហនុ ខាងកើតវិមានឯករាជ្យ ។ ការិយាល័យរបស់យើងបើកជូនសាធារណជនពីថ្ងៃច័ន្ទដល់ថ្ងៃសុក្រ ពេលព្រឹកពីម៉ោង៨ ដល់ម៉ោង១២ និងពេលរសៀលពីម៉ោង២ដល់ម៉ោង៥ ។ ប្រសិនបើអស់លោកអ្នកមានចម្ងល់ ឬចង់រៀបចំព្រឹត្តិការណ៍ជាក្រុមណាមួយ សូមទាក់ទងបុគ្គលិករបស់យើង អ៊ុន សុដាវី តាមរយៈទូរស័ព្ទលេខ ០២៣ ២១១ ៨៧៥ ឬអ៊ីម៉ែល truthsodavy.u@dccam.org ។*





















# កាលវិភាគបញ្ចាំងខ្សែភាពយន្ត ឯកសាររបស់មជ្ឈមណ្ឌលឯកសារកម្ពុជា
















*រៀងរាល់ថ្ងៃសុក្រ វេលាម៉ោង ១០ ៖ ០០ ព្រឹក*

*ទីតាំង៖ អគារ H នៃវិទ្យាស្ថានជាតិអប់រំ (មហាវិថីព្រះសីហនុ ភ្នំពេញ)*

*សម្រាប់ព័ត៌មានបន្ថែមសូមទាក់ទង៖ អ៊ូច មករា ទូរសព្ទលេខ ៖ ០២៣ ២១១ ៨៧៥ អ៊ីម៉ែល ៖ truthmakara@dccam.org*

# អតីតកម្មាភិបាលវ័យក្មេង ដែលត្រូវបញ្ជូន ឱ្យទៅដឹកនាំនៅតំបន់៥ ភូមិភាគពាយ័ព្យ

នៅខែមិថុនា ឆ្នាំ១៩៧៧ តាម៉ុក បានបញ្ជូន សុខ រុំ និងនារីៗឲ្យទៅដឹកនាំប្រជាជនដែលរស់នៅតាមភូមិឃុំក្នុងភូមិភាគពាយ័ព្យ បន្ទាប់ពីកម្មាភិបាលដឹកនាំចាស់នៅភូមិភាគពាយ័ព្យ ត្រូវបានថ្នាក់ដឹកនាំខ្មែរក្រហមចោទថា ក្បត់ និងចាប់ខ្លួនយកទៅសម្លាប់ ។

សុខ រុំ មានស្រុកកំណើតនៅស្រុកគិរីវង្ស ខេត្តតាកែវ ។ រុំ មានម្ដាយឈ្មោះ សៀង ។ រុំ កំព្រាឪពុកតាំងពីអាយុបានបួនខែ ។ រុំ មានបងប្អូនស្រីចំនួនបីនាក់ ។ កាលពីកុមារ រុំ រៀនបានបន្តិចបន្តួចជាមួយគ្រូនៅក្រោមដើមឈើ និងក្បែរគុម្ពឫស្សី ។ នៅពេលនោះ តែងតែមានយន្តហោះមកទម្លាក់គ្រាប់បែកនៅក្នុងភូមិរបស់ រុំ ជាញឹកញាប់ ។

នៅឆ្នាំ១៩៧៣ ខ្មែរក្រហមបានបញ្ជូន រុំ ឲ្យទៅរស់នៅក្នុងកងកុមារដែលកំព្រាឪពុកម្ដាយ ។ កុមារទាំងអស់តម្រូវឲ្យដេញ ។ ស្រុកគិរីវង្ស ជាប់ព្រំប្រទល់ជាមួយប្រទេសវៀតណាម ។ ក្រោយមក រុំ និងកងកុមារត្រូវបានបញ្ចូលជាសមាជិកកងវរៈសេនាធំលេខ ១០៥ ដែលមានឈ្មោះ វ៉េត ជាប្រធាន ។ រុំ បានឲ្យដឹងថា មានប្រជាជនខ្លះបានឧបត្ថម្ភអង្ករ អំបិល ប្រហុកដល់កងកុមារកំព្រា ប៉ុន្តែអ្នកគ្រប់គ្រងកងកុមារ បែរជាយកអង្ករ អំបិល ប្រហុកយកទៅទម្លាក់ចោលនៅក្នុងទឹកប្រឡាយ និងទឹកព្រែកទៅវិញ ។ អ្នកគ្រប់គ្រងកង បានដាំបបរក្នុងមួយពេលដាក់អង្ករត្រឹមតែបីកំប៉ុង ហើយហាន់ត្រកួន និងព្រលឹតលាយជាមួយ ឲ្យកុមារប្រមាណពី៥០ ទៅ ៦០នាក់ហូប ។



សុខ រុំ និងកូនស្រី នៅផ្ទះរបស់គាត់ក្នុងស្រុកភ្នំព្រឹក ខេត្តបាត់ដំបង

កុមារដែលរស់នៅក្នុងកងកុមារកំព្រា មិនមានសម្លៀកបំពាក់សម្រាប់ស្លៀកពាក់សមរម្យទេ មានតែខោខ្លីមួយសម្រាប់ស្លៀកតែប៉ុណ្ណោះ ។ លើសពីនេះទៅទៀត រាល់ពេលមានភ្លៀងធ្លាក់ម្ដងៗ កុមារទាំងនោះ តែងតែអង្គុយរងារញ័រញាក់ ដូច្នេះកុមារទាំងនេះត្រូវចេញទៅកាប់ស្មៅកុម្មុយនីស្ត (ឬស្មៅជើងក្រាស់) មកប្រក់ដំបូលដើម្បីបាំងទឹកភ្លៀង ។ ទាំងកុមារា និងកុមារី តែងតែប្រុងប្រយ័ត្នចំពោះពាក្យសម្ដីរបស់ខ្លួនឯង ព្រោះបើកាលណានិយាយប៉ះពាល់អ្នកផ្សេង ច្បាស់ជាត្រូវអ្នកគ្រប់គ្រងយកទៅសម្លាប់ជាពុំខាន ។ រុំ ធ្លាប់បានឃើញផ្ទាល់នឹងភ្នែកពីការសម្លាប់មនុស្សទម្លាក់ឲ្យត្រីស៊ី និងការសម្លាប់ក្មេងៗយ៉ាងសាហាវឃោរឃៅនៅទន្លេបាសាក់នេះ ។ ក្មេងៗដែលបានបញ្ជូនពីភូមិតាពៅមកនៅក្នុងកងកុមារកំព្រាឪពុកម្ដាយ ក្នុងស្រុកគិរីវង្សជាមួយ រុំ ប្រមាណ១០នាក់ត្រូវបានសម្លាប់នៅសល់តែ រុំ និង រ៉ូ (ប្រុស) ប៉ុណ្ណោះ ។

នៅឆ្នាំ១៩៧៧ តាម៉ុក បានបញ្ជូន រុំ និងនារីដទៃៗប្រមាណ ៥០០នាក់ទៀតឲ្យទៅដឹកនាំនៅតាមសហករណ៍ភូមិ ឃុំ ក្នុងភូមិភាគពាយ័ព្យ ។ នារីដទៃៗទាំងអស់ត្រូវបានដឹកតាមរថយន្តចេញពីស្រុកគិរីវង្សមកទីរួមខេត្តតាកែវ ។ តាម៉ុក បានបង្រៀននារីទាំងអស់រយៈពេលពីរថ្ងៃអំពីរបៀបរស់នៅ និងដឹកនាំនៅតាមសហករណ៍ ដូចជា ការរស់នៅជាមួយប្រជាជន ការធ្វើការជាមួយប្រជាជនក្នុងមូលដ្ឋាន ជាពិសេសត្រូវមានការប្រុងប្រយ័ត្នឲ្យបានជាប្រចាំ ពីព្រោះនៅភូមិភាគពាយ័ព្យមានប្រជាជនមួយចំនួនក្បត់ ។ នារីទាំងអស់មិនត្រូវដើរទៅណាមកណាតែម្នាក់ឯង និងត្រូវប្រយ័ត្នចំពោះពាក្យសម្ដីរបស់ខ្លួន ។ ជាងនេះទៅទៀត ត្រូវចេះអង្កេតមើល និងស៊ើបការណ៍អំពីសកម្មភាពរបស់ប្រជាជនដែលរស់នៅភូមិភាគ

ពាយ័ព្យ ដើម្បីរាយការណ៍ទៅអង្គការថ្នាក់លើ នៅពេលមានប្រជុំម្តងៗ ។

បន្ទាប់ពីរៀននៅខេត្តតាកែវចំនួនពីរថ្ងៃ រុំ និងនារីជំទង់ផ្សេងទៀតបានបន្តជិះរថភ្លើងមកភ្នំពេញ ។ នារីទាំងអស់ត្រូវស្នាក់នៅមន្ទីរស្ពានជ្រោយចង្វារ ក្នុងក្រុងភ្នំពេញចំនួនបីថ្ងៃ ដើម្បីរៀនសូត្របន្ថែមទៀត ។ អង្គការក៏បានយកឡានទេសចរណ៍ជាច្រើនគ្រឿងមកដឹក រុំ និងនារីជំទង់ទាំងនោះដើរកំសាន្តនៅតាមកន្លែងផ្សេងៗក្នុងទីក្រុងភ្នំពេញដែរ ដូចជា នៅវត្តភ្នំ រាជវាំង និងទីកន្លែងមួយចំនួនទៀត ។ ពេលនោះ រុំ និង កងនារីជំទង់ទាំងនោះ បានហូបអាហារគ្រប់គ្រាន់ គឺក្នុងម្នាក់ទទួលបាននំបុ័ង៥ដើម ហូបជាមួយសម្ងសាច់គោ និងសាច់ជ្រូក ។ ។

បន្ទាប់ពីស្នាក់នៅភ្នំពេញបានរយៈពេលបីថ្ងៃ រុំ និងកងនារីបានបន្តជិះរថភ្លើងទៅខេត្តបាត់ដំបង ។ នៅម៉ោងមួយកន្លះយប់ រថភ្លើងបានទៅដល់ស្ពាយស៊ីសុផុន ហើយខ្មែរក្រហមបានឲ្យ រុំ ស្នាក់នៅផ្ទះថ្មបីជាន់ជាប់នឹងមាត់ស្ទឹង ។ នៅថ្ងៃបន្ទាប់ អង្គការបានបើកអង្គប្រជុំចំនួនបីថ្ងៃជាមួយនារីៗដែលទើបមកដល់ ។ តាចាយ ដែលជាគណៈតំបន់៥ ជាអ្នកដឹកនាំអង្គប្រជុំ ។ ពេលបញ្ចប់អង្គប្រជុំ តាចាយ បានបែងចែកនារីៗជាក្រុមៗឲ្យទៅនៅ និងធ្វើការងារតាមភូមិ និងតាមសហករណ៍ផ្សេងៗ ។

រុំ និងនារីប្រមាណ១៨នាក់ផ្សេងទៀត ត្រូវបានចាត់តាំងឲ្យទៅនៅឃុំសំរោង ស្រុកសេរីសោភណ្ឌ តំបន់៥ ។ រុំ មានតួនាទីជាគណៈប្រធានសហករណ៍ ។ ជឿន ជាប្រធានឃុំសំរោង ។ តាប៉ូ និងតាផាត ជាគណៈស្រុកសេរីសោភណ្ឌ ។ ចំណែក តារិន, តាជាល និងតាចាយ ជាគណៈតំបន់៥ ។

ពេលដែលចេញទៅធ្វើស្រែនៅក្នុងភូមិ មានប្រជាជនមួយចំនួនបានដេញកាប់ ដេញសម្លាប់កងនារីដែលមកគ្រប់គ្រងថ្មី ស្លាប់អស់ជាច្រើននាក់ ព្រោះប្រជាជនគិតថា នារីទាំងអស់នោះជាអ្នកថ្មីចុះមកគ្រប់គ្រងភូមិឃុំរបស់ខ្លួន ។ ដោយឡែក រុំ បានរត់ទៅពួននៅក្រោមជង្រុកស្រូវ ទើបបានរួចផុតពីសេចក្តីស្លាប់ ។

បន្ទាប់ពី រុំ ដឹកនាំប្រជាជនធ្វើស្រែបានមួយរយៈ ប្រជាជននៅក្នុងសហករណ៍បានស្គាល់គាត់កាន់តែច្បាស់ និងស្រឡាញ់រាប់អានគាត់កាន់តែច្រើន ។ ចំណែកទិន្នផលស្រូវ គឺទទួលបានផលច្រើនជាងមុន ហើយប្រជាជនក៏បានហូបចុកគ្រប់គ្រាន់ ។ រុំ បានឲ្យដឹងថា ការដែលអង្គការផ្លាស់ឲ្យមករស់នៅខេត្តបាត់ដំបងនេះ ធ្វើឲ្យគាត់កាន់តែសប្បាយរីករាយ មានអាហារហូប និងមានសាច់ឈាមធាត់ទ្រលុកទ្រលន់ រហូតដល់គាត់លែងនឹកនាដល់ផ្ទះសម្បែង និងគ្រួសារ ។ រុំ ក៏បានចូលក្នុងក្រុមសិល្បៈរាំឲ្យប្រជាជនមើលក្នុងពេលរាត្រីដែរ ។

នៅក្នុងឃុំសំរោង គណៈឃុំបានកំណត់ក្នុងមួយសប្តាហ៍ឲ្យ រុំ មកប្រជុំម្តង ។ នៅក្នុងពេលប្រជុំភាគច្រើនពិភាក្សាទៅលើស្ថានភាពទូទៅនៅក្នុងឃុំ ដូចជា សភាពការណ៍ខ្មាំង ថាតើប្រជាជនមានបាននិយាយអ្វីខ្លះអំពីអង្គការ និងពិភាក្សាអំពីការដោះស្រាយបញ្ហាហូបចុកជាដើម ។ ចំណែកឯយាយ ចែម ដែលទើបផ្លាស់ពីខេត្តតាកែវ មកធ្វើគណៈតំបន់៥ ក៏បានហៅកងនារី និងប្រជាជនមកប្រជុំនៅស្ពាយស៊ីសុផុនរយៈពេល១០ថ្ងៃម្តងដែរ ។ ការប្រជុំបានលើកឡើងអំពីបញ្ហាផ្សេងៗនៅតាមភូមិ ។

នៅដើមឆ្នាំ ១៩៧៩ ពេលដែលកងទ័ពវៀតណាមវាយចូលមកដល់ទីក្រុងភ្នំពេញ ប្រជាជននៅខាងភូមិភាគពាយ័ព្យបានទទួលដំណឹងដោយសារអង្គការប្រជុំប្រាប់ប្រជាជនឲ្យត្រៀមរត់ភៀសខ្លួន ។ រុំ បាននាំគ្នារត់ទៅព្រំដែនថៃ ដើម្បីសុំទាហានថៃចូលទៅរស់នៅក្នុងទឹកដីថៃ ដើម្បីគេចចេញពីការវាយប្រហារពីសំណាក់កងទ័ពវៀតណាម ។

នៅពេលនោះ កងនារីត្រូវស្ពាយសាក់កាដូម្នាក់មួយដែលនៅក្នុងសាក់កាដូនោះមានតែសម្លៀកបំពាក់ អង្រឹងមួយ អង្ករមួយបាវតូចប៉ុណ្ណោះ ។ រុំ និងកម្មាភិបាលខ្មែរក្រហមដទៃទៀតធ្វើដំណើរទាំងយប់ទាំងថ្ងៃ និងបានដេកក្នុងព្រៃតាគង់ ។ បន្ទាប់មកគាត់ក៏បន្តដំណើរទៅម៉ាឡៃ ។ ពេលនោះ រុំ មានការភិតភ័យយ៉ាងខ្លាំង ព្រោះបានឮប្រជាជននិយាយតគ្នាថា កងទ័ពវៀតណាមនឹងសម្លាប់ប្រជាជនខ្មែរ ។

នៅឆ្នាំ១៩៨១ រុំ បានរៀបការជាមួយប្តីឈ្មោះ ឈុន ឈួន ដែលមាន តាប៉ូ ជាអ្នករៀបចំផ្សំផ្គុំឲ្យ ។ មកដល់ឆ្នាំ១៩៩២ ទើប រុំ និងក្រុមគ្រួសារ បានមករស់នៅក្នុងស្រុកភ្នំព្រឹក ខេត្តបាត់ដំបង រហូតដល់សព្វថ្ងៃនេះ ។

**សោម លាភ**

# ឱ្យតែមានបាយហូបគឺគ្រប់គ្រាន់

លុច ដួប មានស្រុកកំណើតនៅភូមិតាភរ ឃុំតាភរ ស្រុកថ្មពួក ខេត្តបន្ទាយមានជ័យ ។ ប្រពន្ធទីមួយរបស់ ដួប ស្លាប់ក្នុងឆ្នាំ១៩៧៥ នៅពេលសម្រាលកូនដំបូង ក្រោយមក ដួប យកប្រពន្ធក្រោយឈ្មោះ អ៊ុចដាម និងកូន៤នាក់ (ប្រុសបីនាក់ស្រីមួយនាក់) ។ ជាគ្រួសារកសិករ ដួប មានឪពុកឈ្មោះ លុច ជុំ (ស្លាប់) និងម្តាយឈ្មោះ មីន វ៉ាង (ស្លាប់) ព្រមទាំងមានបងប្អូនប្រុសស្រី៧នាក់ (ស្រីពីរនាក់ ប្រុស៥នាក់) ។

ដួប បានរៀនត្រឹមថ្នាក់ទី៨ (សង្គមចាស់) ប៉ុណ្ណោះ ព្រោះគ្រួសារគាត់មានជីវភាពក្រលំបាក ។ នៅឆ្នាំ១៩៦៩ គ្រួសាររបស់ ដួប បានផ្លាស់មករស់នៅភូមិបន្ទាយឆ្មារ ដោយប្រកបរបរធ្វើស្រែ ។ ដួប និងគ្រួសាររស់នៅ និងធ្វើស្រែនៅភូមិបន្ទាយឆ្មាររហូតដល់ ពេលខ្មែរក្រហមទទួលបានជ័យជម្នះឆ្នាំ១៩៧៥ ។

នៅឆ្នាំ១៩៧៥ អង្គការបានបំបែកប្រជាជនឱ្យរស់នៅភូមិផ្សេងៗ ។ ដួប ត្រូវបានអង្គការចាត់ឱ្យជាឈ្លបឃុំគោកសំរោង ដែលមានតា យឹម ជាគណៈឃុំ ។ ដួប មានភារកិច្ចដើរយាមល្បាតការពារភូមិ ។ ភូមិរបស់ ដួប មិនមានប្រជាជន ១៧ មេសា មករស់នៅទេ គឺសុទ្ធសឹងជាអ្នកមូលដ្ឋានចាស់ទាំងអស់ ។ ក្រៅពីការងារការពារភូមិ ដួប ក៏មាននាទីដើរស៊ើបក្នុងចំណោមប្រជាជនមូលដ្ឋានដើម្បីរកខ្មាំងស៊ីរូងផ្ទៃក្នុង ។ ឪពុកម្តាយរបស់គាត់ត្រូវបានអង្គការចាត់ឱ្យទៅចាំចម្ការដំឡូងនៅភូមិគោកសំរោង ហើយបងប្អូនឯទៀតត្រូវបានអង្គការចាត់ឱ្យទៅកងចល័ត លើកទំនប់ត្រពាំងថ្ម និងដាំកប្បាស ។ អំឡុងពេលដែល ដួប ធ្វើឈ្លប អង្គការមិនទាន់ចាប់ខ្លួនប្រជាជនទេ ។ ក្រោយមក ទើបអង្គការចាប់ខ្លួន អ្នកទាំងនេះ រួចយកទៅឃុំឃាំងនៅគុកថ្មពួក ដែលមានទីតាំងនៅសាលាថ្មពួក ។ អ្នក



យុវនារី នៅរោងម៉ាស៊ីនកិនស្រូវ តំបន់ស្ទួង កោះធំ កំពុងរែងអង្ករយកទៅឧបត្ថម្ភការដ្ឋានប្រព័ន្ធសំណង់ចាត់ចែងទឹក ការដ្ឋានស្រែប្រាំង និងឧបត្ថម្ភសមរភូមិមុខ

ទោសភាគច្រើនត្រូវបញ្ជូនទៅដោយរទេះសេះ និងឡាន ។ ជួប ក៏ធ្លាប់បានយកសំបុត្រទៅឲ្យគណៈស្រុកថ្មពួកដែរ ។

នៅចុងឆ្នាំ១៩៧៦ បន្ទាប់ពី ជួប រៀបគ្រួសាររួច អង្គការបានដកគាត់ពីកងឈ្លបឲ្យ មកធ្វើជាប្រធានក្រុម គ្រប់គ្រងសមាជិក ៣០ គ្រួសារ ។ ជួប បានរម្លឹកអំពីរបបអាហារដែលគាត់បានទទួលថា មិនខុសពីប្រជាជនដទៃទេ ទោះបីជាគាត់មាននាទីជាប្រធានក្រុមក៏ដោយ ។ ជួប អាចបរិភោគបានឆ្អែត តែពេលដែលអង្គការលើហៅគាត់ទៅរៀនសូត្រប៉ុណ្ណោះ ។ ពេលគាត់ទៅរៀនសូត្រនៅថ្មពួកម្តងៗ អង្គការធ្វើម្ហូប និងដាំបាយសម្រាប់អ្នកចូលរួមហូបគ្រប់គ្រាន់ ។ គាត់បានរំឭកថា មិនចាំបាច់មានម្ហូបក៏បានដែរ ឲ្យតែមានបាយហូបឆ្អែត គឺគ្រប់គ្រាន់ហើយ ។ ចំណែកនៅភូមិវិញ អ្នកភូមិគ្រប់គ្នា ទទួលបានរបបបបរមួយកូនចានស្មើៗគ្នា តែបើនរណាម្នាក់លួចហូបអាហារក្រៅគឺត្រូវចាត់ទុកថា “ខ្មាំងក្បត់សមូហភាព” ។

ក្នុងនាទីជាមេក្រុម ជួប មានកាតព្វកិច្ចដឹកនាំប្រជាជនធ្វើស្រែ ហើយនៅពេលឈប់សម្រាកហូបអាហារ ប្រជាជនមិនចាំបាច់ទៅហូបនៅរោងបាយរួមទេ គឺខាងចុងភៅយករបបមកចែកដល់ការដ្ឋានការងារតែម្តង ។ គ្មាននរណាម្នាក់ហ៊ានរអ៊ូរៀងហូបមិនឆ្អែតនោះទេ តែប្រសិនបើមានអ្នកតវ៉ា ប្រាកដណាស់ ម្នាក់នោះនឹងត្រូវអង្គការហៅទៅរៀនសូត្រមិនខាន ។ ចំពោះការទៅរៀនសូត្រ ជួប បានឲ្យដឹងថា អង្គការលើមិនបានបង្រៀន និងណែនាំអ្វីក្រៅពីដាស់តឿន គ្រើនរំឭកអំពីការសកម្មប្រយុទ្ធជាមួយការងារ ដើម្បីសម្រេចតាមផែនការដែលអង្គការលើដាក់ឲ្យ និងស៊ើបរកខ្មាំងបង្កប់ស៊ីរូងផ្ទៃក្នុងនៅតាមសហករណ៍ទេ ។

នៅឆ្នាំ១៩៧៧ សភាពការណ៍មានការប្រែប្រួលយ៉ាងខ្លាំង ដោយសារអង្គការបានបញ្ជូនកម្មាភិបាលភូមិភាគនិរតីមកគ្រប់តំបន់ដែល ជួប រស់នៅ ។ កម្មាភិបាលតំបន់ ឃុំ ភូមិចាស់ ត្រូវបានអង្គការផ្លាស់ទៅកន្លែងផ្សេង និងទៅរៀនសូត្រ ដោយជំនួសមកវិញដោយកម្មាភិបាលមកពីភូមិភាគនិរតី ដែលមានចរិតកាចសាហាវ និងម៉ឺងម៉ាត់ ។

ជួប បានឲ្យដឹងថា ចាប់តាំងពីក្រុមនិរតីចូលមកដល់ ការគ្រប់គ្រង និងការរស់នៅរបស់ប្រជាជនមានការលំបាក និងតឹងតែងកាន់តែខ្លាំង ហើយការសម្លាប់មនុស្សក៏កើតមានឡើងកាន់តែច្រើនពីមួយថ្ងៃទៅមួយថ្ងៃ ។ កម្មាភិបាលដែលមកពីខាងនិរតី ចាប់ផ្តើមធ្វើការបោសសម្អាត និងស្វែងរកអ្នកដែលមានបងប្អូនជាប់និន្នាការនឹងសង្គមចាស់ ។ ប្រជាជនមួយចំនួនបាននាំគ្នាលួចរត់ទៅព្រំដែនថៃ ។

ជួប បានធ្វើជាប្រធានក្រុមរហូតដល់របបខ្មែរក្រហមដួលរលំ ។ ក្រោយរបបខ្មែរក្រហមដួលរលំ ជួប និងគ្រួសារបានភៀសខ្លួនទៅរស់នៅស្វាយចេក ។ រយៈពេលមួយឆ្នាំដែលគាត់រស់នៅស្វាយចេក ជួប ត្រូវបានអាជ្ញាធរខាងរដ្ឋាភិបាលចាត់ឲ្យធ្វើជាប្រធានយុវជន មាននាទីជ្រើសរើសយុវជនឲ្យចូលបម្រើកងទ័ព ។ ដោយមានការប្រយុទ្ធគ្នាជាញឹកញាប់ ជួប បានស្នើសុំឈប់ធ្វើជាប្រធានក្រុមយុវជន និងនាំគ្រួសារត្រឡប់មករស់នៅភូមិបន្ទាយឆ្មារខាងលិចរហូតដល់បច្ចុប្បន្ន ។ គាត់បានចាប់ផ្តើមជីវិតថ្មីរបស់គាត់ដោយប្រកបការងារជាឆ្មាំយាមប្រាសាទ និងធ្វើស្រែ ។

**ផាន សារៈមុនិន្ទ**

## រឿងរ៉ាវពិតដើម្បីប្រវត្តិសាស្ត្រ

មជ្ឈមណ្ឌលឯកសារកម្ពុជាសង្ឃឹមថា ប្រជាជនកម្ពុជាគ្រប់រូបដែលធ្លាប់ឆ្លងកាត់របបខ្មែរក្រហមបាន និងកំពុងសរសេរអត្ថបទ ឬសៀវភៅអំពីរឿងរ៉ាវពិតផ្ទាល់ខ្លួន នឹងផ្ញើមកមជ្ឈមណ្ឌលឯកសារកម្ពុជាតាមអាសយដ្ឋានខាងក្រោម៖

ផ្ទះលេខ៦៦ មហាវិថីព្រះសីហនុ ភ្នំពេញ
ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទលេខៈ (៨៥៥) (២៣) ២១១ ៨៧៥
ទូរស័ព្ទលេខៈ (៨៥៥) (១២) ៩៩៦ ៧៥០
ទូរសារលេខៈ (៨៥៥) (២៣) ២១០ ៣៥៨
Email: truthbunthorn.s@dccam.org
Home page: www.d.dccam.org

# យុទ្ធនារីពេទ្យបដិវត្តន៍

ព្រាំ ណៃ បានស្ម័គ្រចិត្តចូលរួមគស៊ូបដិវត្តន៍តាំងពីអាយុ១២ ឆ្នាំ រហូតដល់របបខ្មែរក្រហមដួលរលំនៅដើមឆ្នាំ១៩៧៩ ។ ណៃ ជាកូនច្បងក្នុងចំណោមបងប្អូនប្រុសស្រី៨នាក់ (ស្រី៣នាក់) ដែលមានឪពុកឈ្មោះ វ៉ែ សៀង (ស្លាប់) និងម្តាយឈ្មោះ ព្រាំ ឈាក (ស្លាប់) ។ ឪពុកម្តាយ ណៃ ជាកសិកររស់នៅភូមិប្រាំង ឃុំដងពែង ស្រុកស្រែអំបិល ខេត្តកោះកុង ។ ដោយសារតែជីវភាពគ្រួសារទីទាល់ក្រ ណៃ មិនបានរៀនសូត្រទេ ។ គាត់ជួយធ្វើស្រែចម្ការឪពុកម្តាយរហូតដល់ឆ្នាំ១៩៧៣ ទើបស្ម័គ្រចិត្តចូលរួមចលនាតស៊ូរបស់ខ្មែរក្រហម ។ ណៃ បានចូលធ្វើពេទ្យបដិវត្តន៍តាមការជ្រើសរើសរបស់ខ្មែរក្រហម ទាំងគាត់មិនដែលបានដឹងទាល់តែសោះអំពីវិធីព្យាបាលអ្នកជំងឺ ឬរបៀបចាក់ថ្នាំ ។ ណៃ បានរំឭកថា គាត់បានចូលធ្វើពេទ្យដំបូងនៅឆ្នាំ១៩៧៣ នៅពេទ្យឃុំដងពែង ។ អំឡុងពេលនោះ ការប្រយុទ្ធគ្នារវាងខ្មែរក្រហម និងកងទ័ព លន់ នល់ កើតមានឡើងជាញឹកញាយ ហើយអ្នករបួសក៏ច្រើន ។ យុទ្ធនារីពេទ្យបានបង្ហាត់បង្រៀន ណៃ អំពីរបៀបចាក់ថ្នាំឲ្យអ្នកជំងឺ និងលាងរបួសជាដើម បន្ទាប់មកក៏ចាត់តាំង ណៃ ឲ្យអនុវត្តទៅលើអ្នកជំងឺផ្ទាល់តែម្តង ។


យុទ្ធនារីពេទ្យខ្មែរក្រហមចុះពិនិត្យសុខភាពប្រជាជន នៅតាមភូមិ

នៅឆ្នាំ១៩៧៤ ណៃ បានផ្លាស់មកធ្វើពេទ្យនៅស្រុកស្រែអំបិលវិញ ព្រោះពេលនោះ អ្នកជំងឺ និងអ្នករបួសមានចំនួនកើនឡើងជារៀងរាល់ថ្ងៃ ។ នៅឆ្នាំ១៩៧៥ បន្ទាប់ពីជ័យជម្នះរបស់ខ្មែរក្រហមទូទាំងប្រទេស ណៃ ត្រូវបានអង្គការដកពីពេទ្យស្រុកឲ្យមកធ្វើពេទ្យព្យាបាលប្រជាជនតាមភូមិ និងសហករណ៍វិញ ។ នៅអំឡុងឆ្នាំ១៩៧៦-៧៧ ណៃ ត្រូវបានអង្គការផ្លាស់ឲ្យមកធ្វើនៅពេទ្យតំបន់ដែលស្ថិតក្នុងភូមិភាគបស្ចិមវិញ ។ ការងាររបស់ ណៃ គឺដើរព្យាបាលប្រជាជនតាមភូមិ ឃុំ សហករណ៍នៅក្នុងភូមិភាគបស្ចិម ។ ណៃ បានឲ្យដឹងថា ការងារជាពេទ្យ គឺនឿយហត់ណាស់ និងសម្រាកបានតិចតួច ព្រោះមានអ្នកជំងឺច្រើនណាស់ ហើយត្រូវធ្វើដំណើរពីកន្លែងមួយទៅកន្លែងមួយ ។ អំឡុងពេលដែល ណៃ ដើរព្យាបាលអ្នកជំងឺ គាត់បានឃើញទិដ្ឋភាពដ៏គួរឲ្យសង្វេគជាច្រើនដែលប្រជាជនទទួលរង ជាពិសេស ប្រជាជន១៧ មេសា ។ កងចល័តបុរសនារី ដែលជាប្រជាជន១៧មេសាត្រូវបានអង្គការចាត់ឲ្យមកលើកទំនប់បឹងព្រាវ ហើយពេលនោះមានមនុស្សស្លាប់ជាច្រើន ដោយការធ្វើការលើសកម្លាំង និងជំងឺ ។ នៅទីនោះ មានគុកមួយ ប៉ុន្តែ ណៃ មិនចាំថា គុកនោះឈ្មោះអ្វីទេ ។ គាត់នៅចាំបានថា ពេលគាត់កំពុងក្រឡេកមើលទៅអ្នកទោសដោយក្តីអាណិតអាសូរ កម្មាភិបាលខ្មែរក្រហមម្នាក់បាននិយាយ

បែបលេងសើចជាមួយគាត់ថា “បងពេទ្យ! មើលហ្នឹងបែបចង់ចូលខ្លួនឯងហើយមើលទៅ” ។ រឿងដ៏គួរឲ្យរន្ធត់មួយទៀតដែល ណៃ បំភ្លេចមិនបាន គឺមិត្តរួមក្រុមរបស់គាត់ឈ្មោះ វ៉ាន់ បានស្រឡាញ់គ្នាជាមួយយោធាម្នាក់រហូតដល់មានកូន ហើយបែកការណ៍ ។ អង្គការបានចោទអ្នកទាំងពីរថា បានធ្វើខុសសីលធម៌ រួចក៏នាំយោធាដែលខុសសីលធម៌នោះទៅសម្លាប់ ហើយបានយកពេទ្យ វ៉ាន់ ទៅវះពោះយកកូនចេញនៅប្រឡាយទឹកខាងក្រោមទំនប់បឹងព្រាវ ។ ទាំងនេះជាការដាក់ទណ្ឌកម្ម និងជាគំរូចំពោះអ្នកណាដែលហ៊ានប្រព្រឹត្តខុសសីលធម៌ ។

ណៃ បានរំឭកថា ទោះបីជាគាត់បម្រើបដិវត្តន៍ក៏ពិតមែន ប៉ុន្តែអង្គការបានសម្លាប់ឪពុក និងតារបស់គាត់ដោយគ្មានការលើកលែងឡើយ ។ ឪពុករបស់ ណៃ ត្រូវបានអង្គការយកទៅសម្លាប់ដោយចោទថា ខុសសីលធម៌ ។ ចំណែកតារបស់គាត់ ត្រូវបានអង្គការចាត់ឲ្យមើលគោជាមួយនឹងចាស់ៗបីនាក់ទៀត ។ ក្រោយមកតារបស់គាត់បានធ្វើឲ្យបាត់កូនគោពីរបីក្បាល ហើយអង្គការបានចោទតារបស់គាត់ និងអ្នកនៅក្នុងកងបីនាក់ទៀតថា លួចកាប់គោស៊ី រួចក៏បញ្ជាឲ្យកងឈ្លបយកទៅសម្លាប់ចោលទាំងអស់ ។ អ្វីដែលគួរឲ្យតក់ស្លុតគឺមុនពេលសម្លាប់ ឈ្លបបានបញ្ជាឲ្យតាៗទាំងបួនហូបស្លឹកអំពៅឲ្យអស់មួយបាច់ ។ បន្ទាប់ពីហូបរួច ឈ្លបបានសម្លាប់តាៗទាំងបួននៅក្នុងចម្ការអំពៅនោះតែម្តង ។

អំឡុងពេល ណៃ ធ្វើការនៅការដ្ឋានទំនប់បឹងព្រាវ អ្នកជំងឺដែលមកព្យាបាលភាគច្រើន ឈឺរាគមួល គ្រុនចាញ់ គ្រុនក្តៅ ហើម និងខ្យល់គ ដែលបណ្តាលមកពីការបរិភោគអាហារមិនគ្រប់គ្រាន់ និងខ្វះអនាម័យ ។ ចំពោះរបបអាហារដែលប្រជាជនទទួលបាននៅសហករណ៍ ឬការដ្ឋានការងារ ណៃ បានឲ្យដឹងថា គ្មានអ្វីក្រៅពីបបររាវមួយវែកម្នាក់នោះទេ ។ ចំពោះ ណៃ ដែលជាគ្រូពេទ្យបានទទួលរបបគ្រាន់បើជាងប្រជាជនបន្តិច ដោយមានសម្ល ត្រី សាច់ហូបខ្លះ ។

ចាប់តាំងពី ណៃ ចូលបដិវត្តន៍ គាត់បានទៅលេងស្រុកកំណើតបានម្តងប៉ុណ្ណោះ ។ អ្វីដែលតក់ស្លុតនោះ ពេលដែលគាត់ទៅដល់ភូមិ យាយរបស់គាត់បានស្លាប់ទៅហើយ ។ ចំណែកឯផ្ទះរបស់គាត់ ត្រូវបានអង្គការរុះយកឈើទៅដាក់សហករណ៍អស់ ដោយឲ្យយាយរបស់គាត់ទៅរស់នៅផ្ទះខ្ទមជំនួសវិញ ។ តាំងពីពេលនោះមកគាត់មិនដែលបានត្រឡប់ទៅភូមិកំណើតទៀតទេ ។

មួយរយៈក្រោយមក បន្ទាប់ពីអង្គការសម្លាប់ឪពុក ក៏ដូចជាជីតារបស់គាត់ហើយ គាត់ត្រូវបានអង្គការចាត់ក្នុងសមាសភាពមិនល្អ ដែលអង្គការត្រូវតាមដាន និងលត់ដំ ។ ប្រធានពេទ្យតំបន់ឈ្មោះ អែម និង ធារី បានចាត់ឲ្យ ណៃ ទៅវែកដីជាមួយប្រជាជនដទៃ ព្រមទាំងបាននិយាយចំអកថា “ចាំមើល ពេទ្យចេះវែកដីដែរឬទេ?” ។ ប្រធានពេទ្យស្រុកឈ្មោះ វឿន ដែលស្រឡាញ់រាប់អាន ណៃ ដូចបងប្អូនបង្កើតបានអប់រំគាត់ថា ឲ្យខិតខំធ្វើការឲ្យបានល្អ អង្គការនឹងមិនយកទៅណានោះទេ ។ ណៃ បានឲ្យដឹងថា មិនត្រឹមតែកន្លែងវែកដីទេ សូម្បីពេលគាត់ព្យាបាលអ្នកជំងឺ ក៏មានឈ្លបទៅតាមដានដែរ ។ ទោះជាយ៉ាងណា ណៃ ខិតខំធ្វើការ និងរក្សាជីវិតគាត់រហូតដល់របបខ្មែរក្រហមដួលរលំ ។

បន្ទាប់ពីរបបខ្មែរក្រហមដួលរលំនៅដើមឆ្នាំ១៩៧៩ ណៃ ក៏ ដូចជាអ្នកឯទៀត បានភៀសខ្លួនទៅរស់នៅជំរំម៉ៃរ៉ូត នៅក្នុងទឹកដីថៃ ។ គាត់រស់នៅជំរំជាមួយម្តាយមីងឈ្មោះ ឡៃ ដែលពេលនោះប្តីមីង ឡៃ ធ្វើជាប្រធានជំរំ ព្រោះប្តីគាត់ចេះភាសាថៃច្បាស់ ។ មិនយូរប៉ុន្មាន មានអង្គការបរទេសមកធ្វើការសម្ភាសអ្នកដែលចង់ចាកចេញទៅរស់នៅប្រទេសទីបី ។ ណៃ មិនចាំថាអ្នកទាំងនោះមកពីខាងណានោះទេ ។ ម្តាយមីងរបស់ ណៃ និងប្តី បានសម្ភាសជាប់ទៅប្រទេសអាមេរិក ហើយក៏ ណៃ ក៏បានសម្ភាសជាប់ដែរ ប៉ុន្តែគាត់ប្រែចិត្តមិនទៅវិញ ព្រោះគាត់គិតថា ទៅដល់ស្រុកគេតែម្នាក់ឯងមិនមានឪពុកម្តាយគ្រួសារនៅជាមួយ ។

នៅឆ្នាំ១៩៨១ ណៃ បានត្រឡប់មករស់នៅក្នុងដីខ្មែរវិញ និងបានរៀបការជាមួយប្តីឈ្មោះ ឡេង ភាព នៅថ្មដារ ។ ក្រោយមក គាត់ និងប្តី រួមជាមួយកូនប្រុសស្រី៨នាក់ បានផ្លាស់មករស់នៅស្រុកវាលវែង ខេត្តពោធិ៍ ដោយប្រកបរបរធ្វើចម្ការ ។ ក្រោយរបបខ្មែរក្រហមបានបញ្ចប់ ណៃ បានបាត់បង់សមាជិកគ្រួសារ៥នាក់ គឺ យាយតា ឪពុក និងប្អូនប្រុសពីរនាក់ ចំណែកម្តាយរបស់គាត់បានស្លាប់ក្រោយរបបខ្មែរក្រហម ។

**ឆាង សារមុនិន្ទ**

# កងចល័តនៅទំនប់អាងត្រពាំងថ្ម

*យ៉ែម គីមរស់ កើតនៅភូមិប៉ោយសំរោង ឃុំព្រះនេត្រព្រះ ស្រុកព្រះនេត្រព្រះ ខេត្តបន្ទាយមានជ័យ ។ គាត់មានឪពុកឈ្មោះ យ៉ែម ញឹប និងម្តាយឈ្មោះ ចិ លឿន ព្រមទាំងមានបងប្អូន៩នាក់ (ស្លាប់៣នាក់ ក្រោយរបបខ្មែរក្រហមដួលរលំ) ។ កាលពីសង្គម ចាស់ គីមរស់ បានរៀនសូត្រដល់ថ្នាក់ទី១ នៅសាលាស៊ីសុផុន រហូតដល់ថ្ងៃខ្មែរក្រហមទទួលបានជ័យជម្នះទាំងស្រុងលើរដ្ឋាភិបាល លន់ នល់ នៅខែមេសា ឆ្នាំ១៩៧៥ ទើបគាត់ឈប់រៀន ហើយវិលត្រឡប់មកស្រុកកំណើតវិញ ។*

*គីមរស់ មកផ្ទះបានពីរបីថ្ងៃ ក៏ត្រូវខ្មែរក្រហមចាត់ឲ្យទៅនៅកងចល័តភូមិដូនប្រែង ប៉ុន្តែអំឡុងពេលនោះ ខ្មែរក្រហមមិនទាន់រឹតត្បិតខ្លាំងទេ គាត់អាចមកលេងផ្ទះបានម្តងម្កាល ។ នៅក្នុងឆ្នាំដដែល គីមរស់ ត្រូវបានខ្មែរក្រហមផ្លាស់ទៅលើកទំនប់នៅដើមគរ៣ដើម ស្ថិតក្នុងភូមិព្រៃមាន់ ។ ការងារលើកទំនប់នោះ អង្គការបានបែងចែកជាក្រុម ដោយមានក្រុមរែកដី ក្រុមកាប់ដីបណ្តាក់គ្នា ។ គីមរស់ បានឲ្យដឹងថា អំឡុងពេលនោះ ម្នាក់ៗធ្វើការងារមិនសូវហត់នឿយទេ ហើយអង្គការក៏បានចែករបបអាហារឲ្យគ្រប់គ្រាន់ដែរ ។ មួយរយៈក្រោយមក គីមរស់ ឃើញអង្គការបញ្ជូនអ្នកថ្មីមករស់នៅ និងលើកទំនប់ជាបន្តបន្ទាប់ ។ នៅឆ្នាំ១៩៧៦ អង្គការបានផ្លាស់ គីមរស់ មកធ្វើកងចល័តនៅភូមិដូនប្រែងវិញ ។ រស់នៅ និងធ្វើការនៅភូមិបានមួយឆ្នាំ អង្គការបានចាត់តាំង គីមរស់ ឲ្យទៅលើកទំនប់នៅអាងត្រពាំងថ្ម ដែលមានទីតាំងនៅក្នុងស្រុកភ្នំស្រុក ខេត្តបាត់ដំបង (សព្វថ្ងៃ ខេត្តបន្ទាយមានជ័យ) ។*

*គីមរស់ បានរម្លឹកអំពីការងារនៅទំនប់អាងត្រពាំងថ្មថា អង្គការតម្រូវឲ្យម្នាក់ៗលើកដីឲ្យបាន៣ម៉ែត្រគូប ហើយម្នាក់ៗត្រូវធ្វើឲ្យបានគ្រប់ផែនការដែលអង្គការដាក់ឲ្យ ទើបអាចសម្រាក និងហូបអាហារបាន ។ បើនិយាយអំពីកន្លែងសម្រាកវិញ គីមរស់ បានឲ្យដឹងថា គាត់និងអ្នកដទៃទៀតស្នាក់នៅរោងវែងដែលធ្វើអំពីឈើ ដោយមិនមានគ្រែ ឬមុងអ្វីឡើយ ។ ម្នាក់ៗត្រូវថែរក្សាចប បង្គី របស់ខ្លួន ។ អង្គការបានប្រកាសប្រាប់រួចហើយថា ម្នាក់ៗត្រូវឯករាជ្យ ម្ចាស់ការ និងទទួលខុសត្រូវរៀងៗខ្លួន ។ ប្រសិនបើនរណាម្នាក់ ធ្វើឲ្យបាត់ចប ឬបង្គី គឺត្រូវទទួលខុសត្រូវចំពោះការងារ និងអង្គការ ។ ចំពោះរបបអាហារវិញ អង្គការបានចែករបបក្នុងម្នាក់ៗ បានបាយមួយកូនចានចង្កឹះតូច ជាមួយនឹងទឹកប្រហុក ។*

*គីមរស់ បានរំឭកថា នៅទំនប់អាងត្រពាំងថ្ម មានប្រជាជនជាច្រើនពាន់នាក់ បានបាត់បង់ជីវិតនៅទីនោះ ដោយសារឈឺគ្មានថ្នាំព្យាបាល និងខ្មែរក្រហមយកទៅសម្លាប់ ដោយចោទថា ខ្ជិលធ្វើការងារ ។ អំឡុងពេលលើកទំនប់ គីមរស់ បានធ្វើនៅខ្សែត្រៀមទីបី ដោយត្រូវលើកទំនប់ប្រដេញពីទំនប់មួយទៅទំនប់មួយ រហូតដល់ទំនប់កូនខ្លែង ដែលមានទីតាំងនៅខាងជើងអាងត្រពាំងថ្ម ។ ការងារនៅទំនប់កូនខ្លែង គឺមានការលំបាកជាងការងារនៅទំនប់អាងត្រពាំងថ្មទៅទៀត ព្រោះនៅរដូវប្រាំង ការដ្ឋានការងារនេះនៅឆ្ងាយពីប្រភពទឹកដែលជាហេតុធ្វើឲ្យមានការខ្វះខាតទឹកសម្រាប់ផឹក និងងូត ។ អង្គការបានបែងចែកទឹក ក្នុងមួយវរៈដែលមានគ្នា៣០០នាក់ ត្រឹមតែទឹក៣០លីត្រប៉ុណ្ណោះក្នុងមួយថ្ងៃ ។ ដោយសារខ្វះខាតទឹក ម្នាក់ៗមិនបានងូតទឹកជាច្រើនខែ បានធ្វើឲ្យកើតចៃសាច់ ពេញខ្លួន និងក្បាលគ្រប់គ្នា ។*

*ឆ្នាំ១៩៧៨ អង្គការបានដក គីមរស់ មកនៅភូមិវិញ ហើយមួយរយៈក្រោយមក អង្គការបានចាត់គាត់ឲ្យទៅធ្វើការនៅភ្នំកងវ៉ា ដោយមាននាទីបាញ់ថ្នាំកប្បាស ។ នៅដើមឆ្នាំ១៩៧៩ បន្ទាប់ពីរបបខ្មែរក្រហមត្រូវបានផ្តួលរំលំ គីមរស់ បានរត់មករកគ្រួសារនៅភូមិវិញ ។ បន្ទាប់មក គាត់បានចុះឈ្មោះចូលធ្វើជាគ្រូបង្រៀននៅសាលាបឋមសិក្សាព្រះនេត្រព្រះ និងបានបន្តទៅរៀនវគ្គបំប៉នគរុកោសល្យនៅបាត់ដំបង ។ ក្រោយពីបញ្ចប់វគ្គបំប៉នបានបីខែ គីមរស់ បានផ្លាស់មកបង្រៀននៅអនុវិទ្យាល័យព្រះនេត្រព្រះរហូតមកដល់សព្វថ្ងៃ ។*

**ហូ ថុនា**

# ទោះបីហូបមិនឆ្អែតក៏មិនហ៊ានត្អូញត្អែរ

ស្រុកអន្លង់វែងគឺជាស្រុកមួយស្ថិតនៅក្នុងខេត្តឧត្តរមានជ័យ ។ ស្រុកនេះ ត្រូវបានមនុស្សស្ទើរគ្រប់គ្នាស្គាល់ ដោយសារអន្លង់វែងជាមូលដ្ឋានរឹងមាំចុងក្រោយរបស់ខ្មែរក្រហម ។ តាមរយៈដំណើរទស្សនកិច្ចសិក្សាដែលរៀបចំឡើងដោយមជ្ឈមណ្ឌលសន្តិភាពអន្លង់វែង ខ្ញុំមានឱកាសមកកាន់តំបន់ប្រវត្តិសាស្ត្រនេះ និងបានសម្ភាសជាមួយប្រជាជនដែលរស់នៅតំបន់អន្លង់វែងអំពីដំណើរជីវិតរបស់គាត់ មុន និងក្រោយមករស់នៅអន្លង់វែង ។

ខ្ញុំបានសម្ភាសជាមួយតា សុខ វង់ មានវ័យ៦៩ឆ្នាំ ។ តា វង់ មានប្រពន្ធឈ្មោះ ពាធិ ធឿប ។ អ្នកទាំងពីរមានស្រុកកំណើតនៅស្រុកស្រីស្នំ ខេត្តសៀមរាប ។ តា វង់ មានកូនប្រុសស្រី៩នាក់ (ស្រី៥ ប្រុស៤នាក់) ។ ដោយសារតែវ័យរបស់ តាវង់ ជរាបន្តិច ហេតុនេះ គាត់មិនសូវចងចាំបានល្អិតល្អន់ទេ ។ តាវង់ បានរៀបរាប់ប្រាប់ខ្ញុំថា បន្ទាប់ពីរដ្ឋប្រហារឆ្នាំ១៩៧០ គាត់និងក្រុមគ្រួសាររស់នៅស្រុកស្រីស្នំនៅឡើយ ។ ប៉ុន្តែមួយរយៈក្រោយមក ដោយមានការទម្លាក់គ្រាប់បែកនៅភូមិស្រុកដែលគាត់រស់នៅ ទើបគាត់និងគ្រួសារបានសម្រេចចិត្តចេញពីភូមិទៅរស់នៅខាងសំរោងរហូតដល់ចលនាតស៊ូរបស់ខ្មែរក្រហមទទួលជ័យជម្នះ និងគ្រប់គ្រងប្រទេសទាំងស្រុង ។

ក្រោយឆ្នាំ១៩៧៥ អង្គការបានជម្លៀសគ្រួសារ តាវង់ ឲ្យទៅរស់នៅភូមិខ្ញុំ ឃុំកូនក្រោល ។ នៅទីនោះ តា វង់ ត្រូវបានអង្គការចាត់តាំងចូលកងចល័តលើកទំនប់ ។ គាត់បានចូលរួមលើកទំនប់ពីរកន្លែង គឺ (ទំនប់លោក) និង (ទំនប់ត្រពាំងវែង) ដែលមានទីតាំងស្ថិតនៅខាងត្បូងភូមិខ្ញុំចម្ងាយប្រហែលពីរគីឡូម៉ែត្រ ។ តា វង់ បានបន្តថា ប្រជាជនជាច្រើនបានចូលរួមក្នុងការលើកទំនប់នេះ ដែលប្រជាជនទាំងនោះមកពីស្រុកថ្មពួក ស្រុកសំរោង និងស្រុកចុងកាល់ ។ ក្រៅពីការងារលើកទំនប់ តា វង់ ក៏ត្រូវទៅធ្វើស្រែ ដកស្ទូងដែរ ។ គាត់បានរំឭកថា ប្រជាជនម្នាក់ៗត្រូវអង្គការដាស់ឲ្យងើបទៅធ្វើការតាំងពីម៉ោង៣ព្រឹក រហូតដល់ម៉ោង១១ថ្ងៃ ទើបអាចសម្រាកហូបបបរ បន្ទាប់មកបន្តធ្វើការរហូតដល់ពេលល្ងាចទើបហូបបបរម្តងទៀត ។ របបបបរដែល តាវង់ ទទួលបានគឺមិនគ្រប់គ្រាន់ជាមួយកម្លាំងដែលគាត់បានធ្វើពេញមួយថ្ងៃឡើយ ។ ទោះបីជា ហូបមិនគ្រប់គ្រាន់ក៏ដោយ ក៏ តា វង់ មិនហ៊ានតវ៉ា និងលួចអាហារ ដូចជា បន្លែ កូនត្រី ក្តាម នៅតាមវាលស្រែយកមកហូបដែរ ព្រោះទង្វើនេះ ត្រូវបានអង្គការចាត់ទុកថា "ក្បត់សមូហភាព" ហើយនឹងត្រូវយកទៅកសាងភ្លាមៗ ប្រសិនបើឈ្លបចាប់បាន ។


រូបខាងឆ្វេង ៖ ហាក់ ដឺលីណា សម្ភាសជាមួយតា សុខ វង់ នៅស្រុកអន្លង់វែង ខេត្តឧត្តរមានជ័យ

តាវង់ បាននិយាយថា ជាញឹកញយ ពេលដែលគាត់ត្រឡប់មកពីស្រែវិញ ខោអាវរបស់គាត់សើមប្រឡាក់ដោយភក់ជ្រាំ ប៉ុន្តែដោយសារគាត់អស់កម្លាំង និងមិនមានពេលគ្រប់គ្រាន់ ទើបគាត់មិនបានបោក

សម្ភារ គឺគាត់ដេកទាំងសើម ។ គាត់គិតតែធ្វើយ៉ាងណាសម្រាកយកកម្លាំងដើម្បីធ្វើការនៅថ្ងៃស្អែកបន្តទៀត ។ ការធ្វើការលើសកម្លាំង ខ្វះអាហារ និងអនាម័យ បានធ្វើឲ្យប្រជាជនដែលធ្វើការនៅតាមសហករណ៍ធ្លាក់ខ្លួនឈឺពីមួយថ្ងៃទៅមួយ ហើយម្នាក់ៗស្គមស្គាំង នៅសល់តែស្បែកដណ្តប់ឆ្អឹងប៉ុណ្ណោះ ។ តា វង់ បានឲ្យដឹងថា អង្គការបានតាមសង្កេតមើលប្រជាជនណាដែលធ្វើការយឺត និងឈឺច្រើនដើម្បីយកទៅសម្លាប់ចោល ព្រោះអង្គការយល់ថា អ្នកទាំងនោះធ្វើឲ្យរាំងស្ទះដល់ចលនាបង្កបង្កើនផលរបស់អង្គការ ។ ដូច្នេះប្រជាជនខិតខំប្រឹងប្រែងធ្វើការដើម្បីកុំឲ្យអង្គការចាប់ផ្ដាក់បាន ។ ក្មេងតូចៗត្រូវអង្គការយកទៅដាក់ឲ្យយាយៗមើល ហើយស្ត្រីដែលទើបសម្រាលកូនរួច អង្គការចាត់ឲ្យបុកស្រូវនៅរោងបាយ ។ តា វង់ បន្តថា គ្មាននរណាម្នាក់គេចពីការធ្វើការងាររួចឡើយ ។ តា វង់ នៅចាំបានថា យូរៗម្ដង ទើបអង្គការចែកចេកម្នាក់២ផ្លែ និងអំបុកម្នាក់១កំប៉ុង ។ រីឯពិធីបុណ្យប្រពៃណីជាតិដូចជា ភ្ជុំបិណ្ឌ ឬ ចូលឆ្នាំ គឺមិនមានទេ ហើយការប្រតិបត្តិសាសនាផ្សេងៗក៏ត្រូវបានហាមឃាត់ដែរ ។ តា វង់ នៅតែមានចម្ងល់រហូតមកដល់សព្វថ្ងៃថា អំឡុងពេលនោះ សហករណ៍នីមួយៗធ្វើស្រែបានទិន្នផលច្រើនណាស់ ប៉ុន្តែគាត់មិនដឹងថាអង្គការយកទៅណាទេ ទើបធ្វើឲ្យប្រជាជនអត់ឃ្លានបែបនេះ ។

ពេលធ្វើការនៅតាមការដ្ឋាន អង្គការជាអ្នកផ្គត់ផ្គង់ផ្នែកសម្ភារ ដូច្នេះរៀងរាល់ម៉ោងធ្វើការប្រជាជនអាចទៅយកនង្គ័ល រនាស់ ចបកាប់ បង្គីពីសហករណ៍ ។ ប៉ុន្តែប្រសិនបើប្រជាជនធ្វើឲ្យបែកបាក់ឧបករណ៍ធ្វើការណាមួយ នឹងត្រូវអង្គការចោទថា បំផ្លាញសហករណ៍ ហើយត្រូវប្រជុំទិតៀនមិនខាន ។ ចំពោះខោអាវ អង្គការបើកឲ្យពាក់ម្ដងមួយកំប្លេ ខោខ្មៅអាវខ្មៅ គឺគ្មានពណ៌ឆើតឆាយទេ ។ អង្គការមិនបានកំណត់ថា អាវមួយត្រូវពាក់បានប៉ុន្មានខែទេ រហូតអង្គការឃើញផ្ទាល់នឹងភ្នែកថា ខោអាវដែលពាក់នោះរហែកប៉ះលែងបាន ទើបអង្គការបើកខោអាវថ្មីឲ្យពាក់ទៀត ។

ជាទូទៅ អង្គការបានបំបែកស្រីៗធ្វើការតាមកងស្រីៗ ប្រុសៗធ្វើការតាមកងប្រុសៗ ។ ស្រីៗធ្វើការងារខាងស្ទូងដក ដាំដំណាំ ដាល់អង្ករ ត្បាញ និងរវៃអំបោះ ជាដើម ។ ចំណែកប្រុសៗវ័យជំទង់ រហូតដល់អាយុ៤០ឆ្នាំ អង្គការចាត់តាំងឲ្យធ្វើការងារនៅតាមការដ្ឋាន និងវាលស្រែ ។ ចំណែកប្រុសៗមានអាយុ៥០ រហូតដល់ ៦០ឆ្នាំឡើងទៅ អង្គការចាត់ឲ្យធ្វើនង្គ័ល បង្គី កញ្ជើ ចង្អេរ ជាដើម ។ នៅក្នុងសហករណ៍នីមួយៗតែងតែមានឈ្លបយកការណ៍ជានិច្ច ។ រាល់ថ្ងៃ ឈ្លបដើរឃ្លាំចាំមើលពីសកម្មភាពរបស់ប្រជាជនគ្រប់ពេល រួចហើយរាយការណ៍នូវអ្វីដែលមិនប្រក្រតីទៅអង្គការ ។

នៅក្នុងរបបខ្មែរក្រហម តា វង់ មិនដែលភ្លេចនូវអំពើព្រៃផ្សៃដែលខ្មែរក្រហម បានប្រព្រឹត្តមកលើប្រជាជនឡើយ ។ តាវង់បានឲ្យដឹងថា ខ្មែរក្រហមសម្លាប់មនុស្សមិនញញើតដៃទេ គ្រាន់តែមានអ្នករាយការណ៍ ឬ ចោទថា នរណាម្នាក់ជាខ្មាំង ឬ ធ្វើឲ្យប៉ះពាល់ដល់អង្គការ ម្នាក់នោះនឹងត្រូវកងឈ្លបយកទៅធ្វើទារុណកម្ម ឬសម្លាប់ដោយគ្មានការវិនិច្ឆ័យឡើយ ។ តា វង់ ធ្លាប់បានអង្គការព្រមានពីរបីដង ព្រោះតែគាត់ក្រោកទៅធ្វើការមិនទាន់ម៉ោង ។

ថ្ងៃមួយ តា វង់ បានចេញដំណើរទៅស្រែ ដោយមានឆ្កែមួយក្បាលរត់ទៅជាមួយ ប៉ុន្តែចៃដន្យឆ្កែនោះរត់ទៅមុនគាត់ ហើយជាន់មីនផ្ទុះ ធ្វើឲ្យអំបែងគ្រាប់ខ្ទាតមកត្រូវគាត់បណ្ដាលឲ្យរងរបួស ។ ភ្លាមនោះ តា វង់ ត្រូវបានប្រជាជនធ្វើស្រែនៅម្ដុំនោះដឹកតាមរទេះគោយកទៅពេទ្យសហករណ៍ ប៉ុន្តែដោយសារពេទ្យសហករណ៍មិនមានឧបករណ៍ និងថ្នាំព្យាបាល ទើបប្រជាជនដឹកគាត់បន្តទៅពេទ្យតំបន់ ។ តា វង់ ចាំបានថា នៅពេទ្យតំបន់មានសុទ្ធតែនារីពេទ្យទាំងអស់ និងមានថ្នាំចិនល្អៗ ។ ជីវិតរបស់គាត់ ក៏បានរួចផុតពីសេចក្ដីស្លាប់ម្ដងទៀត ។

ក្រោយពេលកម្លាំងដែលនៅសេសសល់របស់ខ្មែរក្រហមបានធ្វើសមាហរណកម្មជាមួយរាជរដ្ឋាភិបាល តា វង់ និងគ្រួសារបានជួបជុំគ្នាវិញ ហើយធ្វើដំណើរមករស់នៅក្នុងភូមិលំទងចាស់ ។ ពេលមកនៅភូមិដំបូង មិនមានការគ្រប់គ្រងច្បាស់លាស់ទេ គឺគ្រួសារណាយកផ្ទះ ដីស្រែបានមុន អ្នកនោះនឹងក្លាយជាម្ចាស់កម្មសិទ្ធិ ។ ចំណែកការងារ គឺប្រជាជននៅធ្វើរួមគ្នាដូចសម័យខ្មែរក្រហមដដែល ប៉ុន្តែមិនមានការរឹតតែបន្តឹង និងជិះជាន់កម្លាំងពលកម្មរបស់ប្រជាជនទេ ។ បន្ទាប់ពីសាងសង់ផ្ទះស្នាក់នៅបានស្រួលបួលហើយ តា វង់ ត្រូវបានខ្មែរក្រហមចាត់ឲ្យធ្វើជាប្រធានក្រុមភ្ជួររាស់ដឹកនាំអ្នកភូមិធ្វើស្រែចម្ការរួមគ្នា ដើម្បីខិតខំគ្នាទៅវិញទៅមក ។

**ហាក់ ដីលីណា**

# សហព្រះរាជអាជ្ញា បញ្ចប់ការធ្វើសេចក្តីសន្និដ្ឋានផ្ទាល់មាត់ក្នុងសំណុំរឿង០០២/០២

សហព្រះរាជអាជ្ញារងអន្តរជាតិ ដាល់ លីសាក់ បន្តការធ្វើសេចក្តីសន្និដ្ឋានរបស់ខ្លួន៖

លោក លីសាក់ បានរម្លឹកប្រាប់អង្គជំនុំជម្រះថា លោកបានពិភាក្សាអំពីឧក្រិដ្ឋកម្មនៃការឃុំឃាំង និងការដកហូតសិទ្ធិសេរីភាពពីមនុស្សរាប់ពាន់នាក់នៅក្នុងមន្ទីរសន្តិសុខ ដោយគ្មានការវិនិច្ឆ័យទោស ។ លោកសហព្រះរាជអាជ្ញារងចាប់ផ្តើមជាមួយនឹងការពិភាក្សាអំពីការប្រើប្រាស់ឯកសារចម្លើយសារភាពមកពីមន្ទីរស-២១ដែលជាចម្លើយសារភាពដែលទទួលបានពីការធ្វើទារុណកម្ម ហើយមានជាប់ទាក់ទងនឹងមនុស្សដទៃទៀត ចាត់ទុកជាមូលដ្ឋានសម្រាប់ការចាប់ខ្លួន ។


ខៀវ សំផន (រូបថតៈ អ.វ.ត.ក)


នួន ជា (រូបថតៈ អ.វ.ត.ក)

លោក លីសាក់ កត់សម្គាល់ឃើញថា ប្រធានមន្ទីរស-២១ និងអនុរបស់ខ្លួន២នាក់ទៀតបានផ្តល់សក្ខីកម្មថា ចម្លើយសារភាពត្រូវបានផ្ញើពីភ្នំពេញទៅលេខាកងពល៨០១ ហើយបន្ទាប់មកឈ្មោះដែលមាន ត្រូវបានចាប់ខ្លួននៅក្នុងកងពល និងបញ្ជូនទៅដាក់នៅគុកកងពលនៅអូរកន្សែង ។ ភស្តុតាងដែលគាំទ្រដល់សក្ខីកម្មនេះរួមមាន ឯកសារចម្លើយសារភាពរបស់មន្ទីរស-២១ ដែលនៅសេសសល់ដែលមានកំណត់ហេតុសរសេរដោយដៃ ពីឈ្មោះ ខៀវ ទៅសមមត្តិ វឿន ស្នើឲ្យ វឿន យកឈ្មោះអ្នកដែលមានជាប់ទាក់ទងនៅក្នុងកងពល៨០១ ។ នៅក្នុងរបាយការណ៍ជាបន្តបន្ទាប់ពីលេខាកងពលទៅ សុន សេន បានបង្ហាញថា ពួកគេកំពុងតាមដានសកម្មភាពថ្មី និងចាស់ដែលប្រឆាំងបដិវត្តន៍ ហើយដែលមានជាប់ទាក់ទងនឹងខ្មាំង ។

សហព្រះរាជអាជ្ញារងបានផ្តល់ជាឧទាហរណ៍ពីការអនុវត្តដូចគ្នា និងឯកសារភស្តុតាងដែលបានកើតឡើងនៅភ្នំក្រោល ក្នុងតំបន់១០៥ ។ កម្មាភិបាលជាន់ខ្ពស់ ដែលមកពីតំបន់១០៥ (ស្លាប់ហើយ មុននឹងមានសវនាការ) បាននិយាយក្នុងបទសម្ភាសជាមួយការិយាល័យសហចៅក្រមស៊ើបអង្កេតថា គាត់បានឃើញចម្លើយសារភាពដែលត្រូវបានផ្ញើទៅប្រធានយោធាតំបន់១០៥ ។ លើសពីនេះទៅទៀតមានឯកសារភស្តុតាងជាសារទូរលេខដែលផ្ញើពីលេខាតំបន់១០៥ ឈ្មោះ សោ សារុន ទៅកាន់ថ្នាក់ដឹកនាំនៅភ្នំពេញ ដើម្បីបញ្ជាក់អំពីការចាប់ខ្លួនអ្នកដែលប្រព្រឹត្តខុសសីលធម៌ និងមានឈ្មោះជាប់ទាក់ទងជាមួយនឹងចម្លើយសារភាពដទៃទៀត ។ នៅក្នុងសារទូរលេខដដែលនេះ លេខាកងពលក៏បានសុំសេចក្តីណែនាំពីបក្សថា តើគួរធ្វើយ៉ាងណាទៀតចំពោះអ្នកទោស? វាគឺជាកំណត់ហេតុសរសេរដោយដៃនៅលើសារទូរលេខ ដែលបញ្ជាក់ថា សារទូរលេខនេះពិតជាបានបញ្ជូនទៅ នួន ជា ។

សោ សារុន បានផ្តល់សក្ខីកម្មថា នៅក្នុងករណីនេះ គាត់បានផ្ញើសារទូរលេខទៅ ។ សោ សារុន បានអះអាងថា រាល់សេចក្តីណែនាំដែលគាត់បានទទួលពីថ្នាក់ដឹកនាំបក្ស គឺដោះលែងអ្នកទោស ។ ប៉ុន្តែ សាក្សីផ្សេងទៀតបានផ្តល់សក្ខីកម្មថា អ្នកទោសបានបាត់ខ្លួនពីមណ្ឌលគិរី ហើយក៏មិនឃើញអ្នកទាំងនោះត្រឡប់មកវិញដែរ ។

សៅ សារុន បានផ្តល់សក្ខីកម្មទៀតថា គាត់បានទទួលឈ្មោះពីបក្ស អំពីឈ្មោះកម្មាភិបាលតំបន់១០៥ ដែលជាប្រធានមន្ទីរពាណិជ្ជកម្មតំបន់១០៥ ដែលមានជាប់ទាក់ទងនៅក្នុងចម្លើយសារភាពនៅមន្ទីរស-២១ ។

សហព្រះរាជអាជ្ញារងបានទាញយកឧទាហរណ៍ផ្សេងទៀតដែលបង្ហាញថា ញាតិសន្តាន ក៏ត្រូវបានចាត់ទុកជាគោលដៅក្នុងការចាប់ខ្លួនដែរ ។ សាក្សីបានផ្តល់សក្ខីកម្មថា មានបុរសមួយក្រុមបាននាំគ្នារត់គេចខ្លួនពីមន្ទីរពាណិជ្ជកម្មទៅវៀតណាម ដោយទុកឲ្យប្រពន្ធចោល ។ ប្រពន្ធរបស់អ្នកទាំងនោះ ត្រូវបានចាប់បញ្ជូនមកមនុស្សដែលគួរឲ្យស្អប់ខ្ពើមផ្សេងទៀតដែរ ។ មនុស្សដែលត្រូវចាប់បញ្ជូនទៅ ព្រោះតែឧបទ្ទវហេតុក្នុងការបើកបរចំនួនបីដងដែលបង្ហាញថា គាត់មិនដឹងពីវិធីចាប់ហ្វ្រាំងឲ្យបានសមស្រប ។ គាត់ធ្លាប់បានប្រើប្រាស់ឡានខុសទៅស្លូចឡានផ្សេងទៀត និងធ្វើឲ្យឡើងកំដៅម៉ាស៊ីន ហើយគាត់ក៏បានបំផ្លាញប៉ែលត្រាក់ទ័រកាយដីនៅពេលដែលគាត់បើកវាចុះពីភ្នំ ហើយបានបំបាក់ប៉ែលកាយដីដោយអូសវានឹងផ្លូវ ដែលធ្វើឲ្យប៉ែលកាយដីបាក់ ។ អ្នកបើកបរត្រូវបានបញ្ជូនមកមន្ទីរស-២១ ហើយបីសប្តាហ៍ក្រោយមកត្រូវបានបញ្ជូនទៅសម្លាប់ ។ លោក លីសាក់ បានសង្កត់ធ្ងន់ថា នេះ



មេដឹកនាំខ្មែរក្រហមរង់ចាំទទួលគណៈប្រតិភូបរទេស នៅព្រលានយន្តហោះពោធិ៍ចិនតុង (ឆ្នាំ១៩៧៥-១៩៧៩)

មន្ទីរស-២១ ។

មានឯកសារជាច្រើនដែលអាចរកបានពីមន្ទីរស-២១ ហើយមានការបញ្ជាក់អះអាងជាច្រើនអំពីគោលនយោបាយនៃការបញ្ជូនអ្នកទោសទៅមកមន្ទីរស-២១ ដោយផ្អែកលើចម្លើយសារភាពដែលបានមកពីអ្នកទោសផ្សេងទៀត ។ លោក លីសាក់ បាននិយាយថា ការរំលោភបំពាន និងការចាប់ខ្លួនក្រៅប្រព័ន្ធតុលាការត្រូវបានបង្ហាញនៅក្នុងសំបុត្រផ្ញើទៅ ឌុច ពីសមាជិកនៃមជ្ឈិមបក្សនៅកំពង់ផែកំពង់សោម ចំពោះកម្មាភិបាលភូមិភាគឧត្តរដែលត្រូវចាប់បញ្ជូនទៅមន្ទីរស-២១ ។ នៅក្នុងសំបុត្របានសរសេរថា មនុស្សដែលគួរឲ្យស្អប់ខ្ពើមត្រូវបានបញ្ជូនទៅមន្ទីរស-២១ ជាមួយនឹងប្រពន្ធដែលគួរឲ្យស្អប់ខ្ពើមរបស់វា ហើយវាក៏មានជាប់ពាក់ព័ន្ធនឹងជាឧទាហរណ៍ជាក់លាក់មួយនៃមូលហេតុនៃការអនុវត្តគឺមានភាពចាំបាច់មុននឹងការដកហូតសិទ្ធិសេរីភាពពីមនុស្ស ។

សហព្រះរាជអាជ្ញារង លីសាក់ បានលើកជាឧទាហរណ៍ស្រដៀងគ្នានេះដែរពីគុកក្រាំងតាចាន់ ។ ឯកសារមួយដែលនៅសេសសល់ពីគុកបានបង្ហាញពីអត្តសញ្ញាណអ្នកទោស២៩នាក់ ។ អ្នកទោស២០នាក់ដំបូង ភាគច្រើនជាអតីតទាហាន លន់ នល់ ដែលត្រូវបានចាប់ខ្លួនដោយសារជាខ្សែបណ្តាញដែលមានផែនការគេចខ្លួនទៅប្រទេសថៃ និងវៀតណាម ។ អ្នកទោស៧នាក់ផ្សេងទៀតបានធ្វើឲ្យបាក់ស្នាបព្រា ឬចបកាប់ នៅក្នុងសហករណ៍ ។ អ្នកទោសលេខ២៨ បានតវ៉ាអំពីម្ហូបអាហារ ហើយអ្នកទោសលេខ២៩ ជាអតីតមេភូមិដែលលួចយកអាហារទៅបរិភោគ ។

លោក លីសាក់ បានបង្ហាញថា យោងទៅលើការវិភាគនៃភស្តុតាងពីក្រាំងតាចាន់ ប្រហែលជាពាក់កណ្តាលនៃឯកសារអ្នកទោសក្រាំងតាចាន់គឺជាអតីតទាហាន លន់ នល់ អ្នករដ្ឋការ ឬប៉ូលិសនៃរបបសាធារណរដ្ឋខ្មែរ ។ សាក្សីបានផ្តល់សក្ខីកម្មថា យោងទៅលើការណែនាំដែលផ្តល់ដោយគណៈស្រុកត្រាំកក់ ដោយឲ្យកំណត់ និងបោសសម្អាតអតីតទាហាន លន់ នល់ ។ បីបួននាក់នៃអ្នកទោសដែលជាអតីតទាហាន លន់ នល់ នៅក្រាំងតាចាន់ មានតួនាទីជាព្រិន្ទុបាលទោ ឬ ធំជាងនេះ ។

ជាមួយនឹងការបោសសម្អាតអតីតអ្នករដ្ឋការ លន់ នល់ ក្រុមការពារក្តី នួន ជា បាន ផ្តល់ភាពផ្ទុយគ្នាពីសាក្សី ។ លោក លីសាក់ បានរំឭកប្រាប់អង្គជំនុំជម្រះថា សាក្សីមកដល់ត្រាំកក់មុនរបបនេះ ហើយរឿងរបស់គាត់ត្រូវបានបែកការណ៍ដោយសារបងប្រុសរបស់គាត់ជាអតីតទាហាន លន់ នល់ ដែលត្រូវចាប់ខ្លួន និងដាក់គុកក្នុងរបបនេះ ។

ថ្វីបើមានភាពផ្ទុយគ្នា ឬការជំទាស់របស់សក្ខីកម្មរបស់សាក្សីលើគោលនយោបាយនៅត្រាំកក់ គឺត្រូវបានដោះស្រាយដោយរបាយការណ៍ដែលនៅសេសសល់ពីឃុំ ដែលជាឯកសារច្បាស់លាស់នៃសេចក្តីណែនាំ និងគោលនយោបាយចំពោះការកំណត់គោលដៅលើមន្ត្រី លន់ នល់ ។ លោក លីសាក់ បានរំឭកអំពីឯកសារពីរនៃឯកសារឃុំ ដែលបង្ហាញលម្អិតអំពីការប្រើងប្រែងស្វែងរក និងកម្ទេចខ្មាំងដែលជាអតីតអ្នករដ្ឋការ ។

លោកសហព្រះរាជអាជ្ញារងអន្តរជាតិ បាននិយាយថា ការចាប់ខ្លួន ឬឃុំឃាំងញាតិសន្តាន ពីព្រោះតែពួកគេកាន់តួនាទី និងគាំទ្រអតីតរបប លន់ នល់ គឺមិនមែនជាការអនុវត្តទេ ប៉ុន្តែជាការធ្វើទុកបុកម្នេញ ។

រឿងមួយទៀតដែលទាក់ទងនឹងក្រាំងតាចាន់ដែរ សាក្សីដំបូងមុនអង្គជំនុំជម្រះក្នុងសំណុំរឿងនេះ បានផ្តល់សក្ខីកម្មថា ស្ទើរតែគ្រួសារគាត់ទាំងអស់ត្រូវបានចាប់ខ្លួន និងដាក់គុកនៅក្រាំងតាចាន់ ដោយសារតែឪពុក និងបងថ្លៃប្រុសរបស់គាត់ព្យាយាមបោះឆ្នោតទម្លាក់មេភូមិមូលដ្ឋាន ។ លោក លីសាក់ បានផ្តល់ឯកសារដែលមានជាប់ទាក់ទងនឹងការឃុំឃាំង និងការសម្លាប់ឪពុក និងបងថ្លៃប្រុសរបស់គាត់ ។ សហព្រះរាជអាជ្ញារង បានផ្តល់ឧទាហរណ៍ផ្សេងទៀតអំពីស្ត្រី និងកូនដែលត្រូវឃុំខ្លួននៅក្រាំងតាចាន់មួយឆ្នាំកន្លះ ព្រោះតែចម្លើយសារភាពរបស់អ្នកធ្វើការជាមួយឆ្លើយដាក់ ។

លោក លីសាក់ បានរំឭកឡើងវិញអំពីស្ថានភាពនៅក្នុងគុក ។ សហព្រះរាជអាជ្ញារង កត់សម្គាល់ឃើញថា មានការពិត៥អំពីការដាក់ឲ្យនៅក្នុងលក្ខខណ្ឌមិនមែនជាមនុស្ស នៅគ្រប់មន្ទីរសន្តិសុខ ។

១) អ្នកទោសត្រូវបានដាក់ខ្នោះនៅក្នុងគុក

២) អ្នកទោសអាចបន្ធូរខ្នោះខ្លួនឯងបាន អំឡុងពេលដាក់ខ្នោះនៅក្នុងគុក

៣) អនាម័យ គឺមិនអាចរស់នៅបាន

៤) អ្នកទោសមិនទទួលបានរបបអាហារគ្រប់គ្រាន់

៥) អ្នកទោសជាទូទៅធ្លាក់ខ្លួនឈឺ មិនមានការព្យាបាលសមរម្យ ហើយជាលទ្ធផលអ្នកទោសជាច្រើនបានស្លាប់ ។

ជាមួយនឹងការប្រើប្រាស់ខ្នោះ លោក លីសាក់ បានបង្ហាញរូបភាពនៃវិធីផ្សេងគ្នា ដែលអ្នកទោសត្រូវដាក់ខ្នោះនៅគុកផ្សេងគ្នា ។ ជាឧទាហរណ៍ នៅក្នុងគុកធំ ខ្នោះត្រូវភ្ជាប់ជាមួយនឹងដែករនុកវែង ។ អ្នកទោសជាច្រើនត្រូវដាក់ខ្នោះគ្រប់ពេល រួមទាំងពេលដេក ។ សាក្សីបានផ្តល់សក្ខីកម្មថា ផលប៉ះពាល់នៃការដាក់ខ្នោះគឺធ្វើឲ្យមានការឈឺចាប់ ស្ពឹកជើង និងធ្វើឲ្យពិបាក ។

លោក លីសាក់ បានពិពណ៌នាពីភាពកង្វះអនាម័យដែលបានបណ្តាលឲ្យអ្នកទោស ឈឺចាប់ពីសត្វសង្កើច ឬចៃសាច់ ។ អ្នកទោសត្រូវបានរំខានដោយសត្វសង្កើច និងសត្វកណ្តុរ ។ សាក្សីបានផ្តល់សក្ខីកម្មថា ផលប៉ះពាល់ដែលបណ្តាលមកពីកង្វះអនាម័យ គឺមានទាំងផ្លូវកាយ និងផ្លូវចិត្ត ។ សាក្សីក៏បានពិពណ៌នាអំពីក្លិនអសោចនៃសាកសពនៅក្នុងគុកទៀតផង ។

សហព្រះរាជអាជ្ញារងអន្តរជាតិ បានផ្តល់ជាឧទាហរណ៍នៃការកង្វះអាហារនៅក្នុងគុក ។ សាក្សីបានពិពណ៌នាអំពីសេចក្តីស្រេកឃ្លានរបស់ខ្លួននៅក្នុងគុក ហើយនឹងទំហំនៃរបបអាហារដែលទទួលបាន ។ ចំណែកដែលទទួលបានមិនគ្រប់គ្រាន់ឡើយ ដូចជាស្ត្រីមិនអាចផលិតទឹកដោះបានគ្រប់គ្រាន់ ដែលជាលទ្ធផលកូនៗរបស់ខ្លួនបានស្លាប់ដោយសារមិនមានទឹកដោះបៅ ។ សាក្សីបាននិយាយថា ពួកគេមិនបានគិតអ្វីទាំងអស់ក្រៅពីសេចក្តីស្រេកឃ្លាន

និងស្រេកទឹក ហើយសាក្សីម្នាក់ទៀតបាននិយាយថា គាត់ធ្លាប់បានបរិភោគសាច់មនុស្ស ហើយនៅតែមិនអាចបញ្ឈប់នូវសេចក្ដីស្រេកឃ្លាន ។

ចុងបញ្ចប់នេះ គឺផ្ដោតទៅលើប្រធានបទការព្យាបាល ។ លោក លីសាក់ បានរំឭកពីសក្ខីកម្មរបស់ប្រធានគុកអូរកន្សែងថា អ្នកទោសជាច្រើនបានស្លាប់ដោយសារជំងឺជាជាងការសម្លាប់ ។ នៅក្រាំងតាចាន់ ពេលដែលអ្នកស្លាប់ អ្នកទាំងនោះត្រូវទុកចោលពេញមួយយប់ ។ នៅមន្ទីរស-២១ របាយការណ៍ប្រចាំថ្ងៃ បានសរសេរនៅខាងលើដោយអក្សរសរសេរដោយដៃយ៉ាងលម្អិតអំពីការស្លាប់របស់អ្នកទោសដោយជំងឺ ។ សាក្សីម្នាក់បានផ្ដល់សក្ខីកម្មថា ឪពុករបស់គាត់មានសុខភាពល្អមុនពេលដែលត្រូវចាប់ខ្លួន ហើយបានដាក់នៅមន្ទីរស-២១ បានមួយខែ ឪពុករបស់គាត់បានស្លាប់ដោយរោគមូល និងរបួស ។

សហព្រះរាជអាជ្ញារងអន្តរជាតិ បានកត់សម្គាល់ឃើញថា ឧបសម្ព័ន្ធ F បានបំពេញជាមួយនឹងសេចក្តីសន្ទេបនៃការដាក់ទោសចុងក្រោយ ។ បញ្ជីសរុបជាប្រចាំពីបញ្ជីគ្រប់គ្រងប្រចាំថ្ងៃរបស់មន្ទីរស-២១ ដែលបានកត់ត្រាពីការស្លាប់រៀងរាល់ថ្ងៃដោយសារជំងឺ ។ មានរបាយការណ៍ដែលប្រើការបានសម្រាប់២៥៨ថ្ងៃ និងអំឡុងពេលនេះ ។ អ្នកទោស២៣៥នាក់ បានស្លាប់ដោយជំងឺនៅស-២១ ជាមួយនឹងការកើនឡើងចំនួននៃការស្លាប់គ្រប់ពេល ។

លោក លីសាក់ ផ្ដោតទៅលើសក្ខីកម្មរបស់ ជុំ ម៉ី អំពីស្ថានភាពនៅក្នុងមន្ទីរស-២១ ។ ជុំ ម៉ី បានផ្ដល់សក្ខីកម្មថា គាត់មិនដែលធ្លាប់គិតសោះថា គាត់អាចរួចជីវិតពីមន្ទីរស-២១ ហើយរៀងរាល់ថ្ងៃគាត់ទន្ទឹងតែសេចក្ដីស្លាប់ប៉ុណ្ណោះ ។ លោក លីសាក់ បានកត់សម្គាល់ឃើញថា ក្រុមការពារក្ដី នួន ជា បានសួរសំណួរពីការឃុំឃាំងរបស់ ជុំ ម៉ី នៅមន្ទីរស-២១ ទោះបីជា ឌុច និងអ្នករស់រានជីវិតផ្សេងទៀត បានផ្ដល់សក្ខីកម្មថា ជុំ ម៉ី ត្រូវបានជាប់ឃុំឃាំងនៅមន្ទីរស-២១ ។ មានបញ្ជីគុកជាច្រើនដែលបញ្ជាក់ថា ជុំ ម៉ី នៅមន្ទីរស-២១ និង ចម្លើយសារភាពរបស់គាត់ គឺមាននៅកំណត់ត្រានៃមន្ទីរស-២១ដែលនៅសេសសល់ ។

**មន្ទីរសន្តិសុខ និងការធ្វើទារុណកម្ម**

លោក លីសាក់ បានលើកពីបទឧក្រិដ្ឋនៃការធ្វើទារុណកម្ម មកធ្វើការពិភាក្សា ។ គាត់បាននិយាយការដែលអំពើទារុណកម្មត្រូវបានប្រើនៅក្នុងមន្ទីរឃុំឃាំង គឺត្រូវបានបញ្ជាក់យ៉ាងជាក់លាក់ ដោយសារថាអ្នករួចជីវិតមួយចំនួនបានពណ៌នាពីរឿងនេះ ហើយជាពិសេសអ្នកសួរចម្លើយ និងប្រធានមន្ទីរសន្តិសុខក៏បានសារភាពថា រឿងនេះជាការពិតផងដែរក្នុងអំឡុងពេលសវនាការជំនុំជម្រះរបស់គាត់ ។ មិនតែប៉ុណ្ណោះ ក្នុងសៀវភៅកំណត់ហេតុជាច្រើនក្បាលដែលត្រូវបានរក្សាទុកដោយអ្នកសួរចម្លើយនៃមន្ទីរសន្តិសុខស-២១ ក៏មានកំណត់ត្រាជាលាយលក្ខណ៍អក្សរដែលបង្ហាញពីការទារុណកម្ម និងវិធីសាស្ត្រធ្វើទារុណកម្មដែរ ។ ការធ្វើទារុណកម្មនៅមន្ទីរស-២១ មិនមែនមានលក្ខណៈស្រាលទេ ពោលគឺមានរួមបញ្ចូលទាំងការវាយដំធ្ងន់ធ្ងរ ការឆក់ខ្សែភ្លើងរហូតដល់ជនរងគ្រោះសន្លប់បាត់ស្មារតី ព្រមទាំងការដកក្រចកដៃ និងក្រចកជើង ។

បន្ទាប់មក លោក លីសាក់ បានផ្ដល់ជាឧទាហរណ៍យ៉ាងច្រើនទាក់ទិននឹងអំពើទារុណកម្មដែលឧទាហរណ៍ទាំងនេះត្រូវបានផ្ដល់សក្ខីកម្មដោយសាក្សី និងបញ្ជាក់ជាការពិតដោយភស្តុតាងឯកសារ ។ ភស្តុតាងឯកសារសំខាន់ៗបំផុតមួយចំនួនគឺសៀវភៅកំណត់ហេតុរបស់អ្នកសួរចម្លើយដែលក្នុងនោះរួមមានបទបញ្ជា និងការហ្វឹកហ្វឺនដែលពួកគេបានទទួល ។ ក្នុងបទបញ្ជាមានការចែងយ៉ាងច្បាស់អំពីការប្រើអំពើទារុណកម្ម ពោលគឺអំពើទារុណកម្មមិនអាចជៀសបានឡើយ តែសំខាន់គួរតែសួរថាអំពើទារុណកម្មត្រូវប្រើកម្រិតស្រាល ឬធ្ងន់ ។ បទបញ្ជានេះក៏បានបញ្ជាក់ផងដែរថា គោលដៅនៃអំពើទារុណកម្មគឺដើម្បីទាញយកចម្លើយសារភាពពីជនរងគ្រោះ ដូច្នេះទាល់តែជនរងគ្រោះមានអារម្មណ៍ឈឺចាប់ទើបពួកគេផ្ដល់ចម្លើយសារភាពឆាប់រហ័ស ។

លោក លីសាក់ ក៏បានពិនិត្យមើលសក្ខីកម្មសាក្សីបន្ថែមទៀតរបស់អ្នកទោសនៅមន្ទីរសន្តិសុខផ្សេងៗដែលបានរួចជីវិត ឬជាសាក្សីនៃអំពើទារុណកម្មនៅតាមមន្ទីរសន្តិសុខទាំងនោះ ។ ចំណុចសំខាន់មួយនៃបទបង្ហាញរបស់លោក លីសាក់ ស្ដីពីអំពើទារុណកម្ម គឺភាពជាប់ពាក់ព័ន្ធស្រដៀងគ្នានៃវិធីសាស្ត្រធ្វើទារុណកម្មនៅទូទាំងមន្ទីរសន្តិសុខទាំងអស់ ។ ជាឧទាហរណ៍ គាត់បានពីបង្ហាញភស្តុតាង របាយការណ៍ពីឃុំក្រាំងតាចាន់ និងឃុំត្រពាំងធំ ដែលបានបញ្ជាក់អំពីការប្រើប្រាស់ ការសួរចម្លើយតាមវិធីក្ដៅ

និងត្រជាក់ទៅលើអ្នកទោស ។ លោក លីសាក់ គិតថា ភាពជាប់ទាក់ព័ន្ធនៃវិធីសាស្រ្តសួរចម្លើយបែបក្តៅ និងត្រជាក់នៅក្នុងតំបន់នេះ គឺមានសារសំខាន់ធំធេងណាស់ ព្រោះថាវិធីសាស្រ្តក្តៅ និងត្រជាក់ដែលមានលក្ខណៈស្រដៀងគ្នានេះក៏ត្រូវបានប្រើនៅក្នុងមន្ទីរស-២១ផងដែរ ។ លោក លីសាក់ បានបញ្ជាក់ថាភ័ស្តុតាងនេះបង្ហាញថាអំពើទារុណកម្មមានលក្ខណៈទូលំទូលាយ និងតាមបែបបទ ព្រមទាំងត្រូវបានគេប្រើប្រាស់នៅគ្រប់មន្ទីរសន្តិសុខទាំងអស់ ។ ការប្រើទារុណកម្មក៏ត្រូវបានគេដឹងយ៉ាងទូលំទូលាយផងដែរ ចាប់តាំងពីមេឃុំទៅដល់មេដឹកនាំបក្ស ។ ជាឧទាហរណ៍ សមាជិកម្នាក់នៃគណៈកម្មាធិការអចិន្ត្រៃយ៍នៃបក្សកុម្មុយនីស្តកម្ពុជា គឺ វន វេត បានបង្ហាត់ ឌុច ឲ្យចេះរបៀបធ្វើទារុណកម្ម ដោយការប្រើប្រាស់ថង់ប្លាស្ទិក ។

ទាក់ទងទៅនឹងការដែលជនជាប់ចោទបានដឹងឮអំពីការប្រើអំពើទារុណកម្ម លោក លីសាក់ បានពន្យល់ថា ចំណារបន្ថែមនានាលើឯកសារដូចជាលើរបាយការណ៍សង្ខេបចម្លើយសារភាពជាដើមបានបង្ហាញថា របាយការណ៍ទាំងនោះត្រូវបានចែកចាយដល់ថ្នាក់ដឹកនាំតាមតំបន់ភូមិភាគ កងពល និងថ្នាក់ដឹកនាំក្រសួងនៅទូទាំងប្រទេស ។ ជារឿយៗ សេចក្តីសង្ខេបចម្លើយសារភាព តែងមានសេចក្តីពិពណ៌នាអំពីការប្រើទារុណកម្ម ។

នួន ជា បាននិយាយផ្ទាល់ទៅកាន់លោក ថេត សម្បត្តិ ដែលជាអ្នកសរសេរជីវប្រវត្តិរបស់គាត់ថា ជាធម្មតាអ្នកទោសបានធ្វើការសារភាពបន្ទាប់ពីការវាយដំ និងធ្វើទារុណកម្ម ឯ ខៀវ សំផន វិញក៏បានសារភាពចំពោះមុខអ្នករាយការណ៍ម្នាក់មកពីសារព័ត៌មាន *Le Monde* ថា (កាលនោះ ពិតជាមានស្ថាប័នរដ្ឋមួយ "មន្ទីរស-២១" ដែលបានដាក់បញ្ចូលឧក្រិដ្ឋកម្ម ការធ្វើទារុណកម្ម និងការសម្លាប់រង្គាលជាលក្ខណៈប្រព័ន្ធ ក្នុងគោលនយោបាយរបស់ខ្លួនមែន) ។

## មន្ទីរសន្តិសុខ ឃាតកម្ម និងការសម្លាប់រង្គាល

តមក លោក លីសាក់ បានបង្ហាញភ័ស្តុតាងអំពីបទឧក្រិដ្ឋមនុស្សឃាត និងការសម្លាប់រង្គាល ។ តាមរយៈការសបញ្ជាក់របស់គាត់ ភ័ស្តុតាងនេះបានបង្ហាញឲ្យឃើញថា ការសម្លាប់នៅមន្ទីរសន្តិសុខត្រូវបានធ្វើឡើងក្នុងទ្រង់ទ្រាយធំដែលភ័ស្តុតាងមានវិសាលភាពធំធេងមិនអាចជំទាស់បានឡើយ ។

ក្នុងឧទាហរណ៍ដំបូងរបស់គាត់ លោក លីសាក់ បានពន្យល់ពីការដែលប្រធាន និងអនុប្រធានមន្ទីរសន្តិសុខ និងអ្នកទោសដែលរួចជីវិតពីមន្ទីរសន្តិសុខ បានផ្តល់សក្ខីកម្មយ៉ាងដូចម្តេចខ្លះអំពីការប្រហារជីវិតអ្នកទោសមកពីប្រទេសវៀតណាមប្រមាណ១០០ ទៅ ២០០នាក់ ដែលបានប្រព្រឹត្តនៅមន្ទីរសន្តិសុខ ។ ប្រធាន និងអនុប្រធានមន្ទីរសន្តិសុខ ក៏បានផ្តល់សក្ខីកម្មថាពួកគេបានទទួលបញ្ជាឲ្យសម្លាប់អ្នកទោសដែលបញ្ជូនមកពីកងពលលេខ៨០១ ប៉ុន្តែកងពលលេខ៨០១ ក៏បានទទួលបញ្ជានេះបន្តពីលេខាធិការភូមិភាគភាគឦសានដែរ ។ ដូច្នេះ បញ្ជាទាំងនេះមានការពាក់ព័ន្ធគ្នា ពីព្រោះថាលេខាធិការភូមិភាគឦសានជាអ្នកដែលបានរាយការណ៍ថា កងពលលេខ៨០១ បានឃាត់ខ្លួនជនជាតិវៀតណាមចំនួន២០៩នាក់ ដែលឆ្លងកាត់ព្រំដែន ហើយក៏ជាអ្នកដែលបានធ្វើការទាក់ទងនឹងការស្នើមេដឹកនាំបក្សថាត្រូវអនុវត្តបន្តដោយវិធីណាទៀតចំពោះអ្នកដែលបានឃាត់ខ្លួនទាំងនេះ ។ ការស្នើសុំបទបញ្ជានេះត្រូវបានផ្ញើតាមរយៈទូរលេខ ដែលទូរលេខនេះត្រូវបានថតចម្លងឲ្យ នួន ជា ការិយាល័យ ៨៧០ និងរក្សាទុកជាឯកសារទៀតផង ។

លោក លីសាក់ បានសន្និដ្ឋានថា អ្វីដែលបានលើកឡើងក្នុងឧទាហរណ៍នេះបានបង្ហាញយ៉ាងច្បាស់ គឺថាមេដឹកនាំបក្សនៅភ្នំពេញវិញទេ ជាអ្នកសម្រេចនូវជោគវាសនារបស់អ្នកទោសទាំងនេះ ។

លោកលីសាក់ បានផ្តល់ឧទាហរណ៍ពីរបន្ថែមទៀតអំពីការសម្លាប់ជាលក្ខណៈទ្រង់ទ្រាយធំនៅមន្ទីរសន្តិសុខ "ក្រាំងតាចាន់" និង "ត្រាំកក់" ។ សន្តិសុខយាមជាច្រើនរូប និងអ្នករួចជីវិតមួយចំនួនតូចពីពន្ធនាគារក្រាំងតាចាន់បានផ្តល់សក្ខីកម្មថា អ្នកទោសដែលត្រូវបានបញ្ជូនទៅមន្ទីរសន្តិសុខក្រាំងតាចាន់ ត្រូវបានសម្លាប់ទាំងអស់លើកលែងតែករណីពិសេសខ្លះប៉ុណ្ណោះ ។ គាត់បានផ្តល់ឧទាហរណ៍នៃសក្ខីកម្មរបស់សាក្សី និងដើមបណ្តឹងរដ្ឋប្បវេណីដែលបានបញ្ជាក់បន្ថែមពីរឿងនេះ ។ សក្ខីកម្មរបស់សាក្សីទាំងនេះ គឺមានខ្លឹមសារពិតដូចនឹងឯកសារមកពីមន្ទីរសន្តិសុខក្រាំងតាចាន់ ។ លោក លីសាក់ បានបង្ហាញរបាយការណ៍ប្រចាំខែរបស់មន្ទីរ

សន្តិសុខ ក្រាំងតាចាន់ ដែលមានសរុបនៃចំនួនអ្នកទោសដែលបានបញ្ជូនចូលមក ចំនួនអ្នកដែលត្រូវបានសម្លាប់ ចំនួនអ្នកស្លាប់ដោយសារជំងឺ និងចំនួនអ្នកទោសដែលសេសសល់ក្នុងមន្ទីរសន្តិសុខ ។ នៅក្នុងរបាយការណ៍សួរចម្លើយរបស់មន្ទីរសន្តិសុខក្រាំងតាចាន់មួយទៀត មានការសរសេរដោយដៃពីលេខាតំបន់ ១៣ ដែលមានអត្ថន័យឲ្យ "កម្ទេចពួកគេចោលទាំងអស់" ។

លោក លីសាក់ ក៏បានលើកឡើងពីសក្ខីកម្មរបស់សាក្សី និងភ័ស្តុតាងឯកសារដែលបានចង្អុលបង្ហាញថា លេខាស្រុកត្រាំកក់បានអនុញ្ញាតឲ្យមានការសម្លាប់កុមារ និងកូនក្មេងតូចៗណាចចេសមិនព្រមបែកពីម្តាយខ្លួនដែលត្រូវយកទៅប្រហារជីវិត ។ លោក លីសាក់ បានមានប្រសាសន៍ថា ការសម្លាប់ទាំងនេះមិនមែនជាអំពើប្រាសចាកច្បាប់ទម្លាប់ទេ ប៉ុន្តែត្រូវបានធ្វើឡើងដោយស្របតាមគោលនយោបាយ និងបទបញ្ជាពីមេដឹកនាំបក្សកុម្មុយនីស្តកម្ពុជា ។

លោក លីសាក់ បានធ្វើការវាយតម្លៃឡើងវិញទៅលើការធ្វើកោសល្យវិច័យអដ្ឋិធាតុនៃរណ្តៅសាកសពធំៗនៅក្រាំងតាចាន់ ដោយគាត់បានកត់សម្គាល់ថា អដ្ឋិធាតុទាំងនោះមិនត្រូវបានថែរក្សាឲ្យបានត្រឹមត្រូវទេក្នុងអំឡុងប៉ុន្មានឆ្នាំមកនេះ ដូច្នេះចំនួននៃអដ្ឋិធាតុដែលត្រូវបានធ្វើកោសល្យវិច័យមិនអាចតំណាងឲ្យចំនួនដើមនៃអដ្ឋិធាតុឡើយ ។ ការធ្វើកោសល្យវិច័យលើឆ្អឹងលលាដ៏ក្បាលចំនួនប្រមាណ១.៩០០នៅក្រាំងតាចាន់បង្ហាញឲ្យឃើញនូវស្លាកស្នាមយ៉ាងច្បាស់ក្រឡែតដែលបណ្តាលមកពីការប៉ះទង្គិចដោយហិង្សាលើលលាដ៏ទាំងនេះ ។

បន្ទាប់មក លោក លីសាក់ បានពិនិត្យភ័ស្តុតាងនៃឃាតកម្ម និងការសម្លាប់រង្គាលនៅមន្ទីរស-២១ ។ គាត់បានកត់សម្គាល់ថា ឌុច និងពួកកម្មាភិបាលនៅមន្ទីរសន្តិសុខបានផ្តល់សក្ខីកម្មថា អ្នកទោសប៉ុន្មានដែលត្រូវបានបញ្ជូនមកមន្ទីរស-២១ត្រូវតែកម្ទេចចោលឲ្យអស់ ។ សក្ខីកម្មនេះបានមកពីកម្មាភិបាលម្នាក់ដែលមានតួនាទីកត់ឈ្មោះអ្នកទោសទាំងអស់ដែលមកដល់មន្ទីរ ឆ្នាំដែលបានដឹកអ្នកទោសពីបរិវេណមន្ទីរស-២១ទៅកាន់វាលពិឃាតជើងឯក និងឆ្នាំដែលបាននាំអ្នកទោសទៅដល់រណ្តៅពិឃាដជើងឯកដែលជាកន្លែងដែលអ្នកទោសត្រូវបានសម្លាប់ ។ ការធ្វើកោសល្យវិច័យនៃសាកសពនៅវាលពិឃាដជើងឯកត្រូវបានធ្វើឡើងរួចហើយដែលក្នុងនោះមានឆ្អឹងលលាដ៍ក្បាលជាង ៦.០០០ ត្រូវបានពិនិត្យ ប៉ុន្តែមានតែលលាដ៏ក្បាលមួយប៉ុណ្ណោះដែលមិនមានស្លាកស្នាមនៃការប៉ះទង្គិចដោយហិង្សា ។

បន្ទាប់ពីនេះ លោក លីសាក់ បានលើកភ័ស្តុតាងឯកសារស្តីពីបញ្ជីពិឃាតមកពិភាក្សា ។ ក្នុងការផ្តល់សម្អាងខ្លះៗ លោកបានកត់ចំណាំថាក្នុងការបោសសម្អាតខ្មាំងអំឡុងឆ្នាំ១៩៧៧ និងឆ្នាំ១៩៧៨ យ៉ាងហោចណាស់មាន២៧ករណីនៃការសម្លាប់រង្គាលដែលក្នុងនោះមានអ្នកទោសជាង១០០នាក់ត្រូវបានប្រហារជីវិតក្នុងមួយថ្ងៃ ។ ក្នុងនោះក៏មានខែមួយដែលមានអ្នកទោសជាង ១.០០០នាក់ត្រូវបានប្រហារជីវិត ។ នាខែតុលា ឆ្នាំ១៩៧៧ គ្រាន់តែក្នុងមួយថ្ងៃប៉ុណ្ណោះមានមនុស្សដល់ទៅ៤១៨នាក់ត្រូវបានសម្លាប់ចោលនៅឯមន្ទីរស-២១ ។ បញ្ជីពិឃាតទាំងនេះបង្ហាញពីចេតនាសម្លាប់ជាលក្ខណៈទ្រង់ទ្រាយធំ ហើយសបញ្ជាក់ថាឧក្រិដ្ឋកម្មនៃការសម្លាប់រង្គាលពិតជាត្រូវបានប្រព្រឹត្តមែន ។

បន្ទាប់មក លោក លីសាក់ បានបំភ្លឺពីការប្រែប្រួលចំនួនមនុស្សដែលត្រូវបានសម្លាប់នៅមន្ទីរស-២១ដែលការប្រែប្រួលនេះបានកើតឡើងចាប់តាំងពីការបញ្ចប់សំណុំរឿង០០១ ។ នៅពេលដែល ឌុច ត្រូវបានចោទសួរពីចំនួនអ្នកទោសដែលស្លាប់ គាត់បានលើកឡើងថាចំនួនពិតប្រាកដនៃអ្នកទោសដែលត្រូវបានសម្លាប់នៅមន្ទីរស-២១ អាចលើសពីចំនួននៃឈ្មោះអ្នកទោស ១២.៣០០នាក់ ដែលត្រូវបានចងក្រងទុកក្នុងបញ្ជីមួយ ។ កាលពីឆ្នាំទៅការិយាល័យសហចៅក្រមស៊ើបអង្កេត បានដាក់បញ្ចូលឈ្មោះអ្នកទោសថ្មីទៅក្នុងបញ្ជីពិឃាតនៅមន្ទីរស-២១ ដោយពិនិត្យឡើងវិញនូវកំណត់ត្រាចូលឈ្មោះទាំងអស់នៅមន្ទីរស-២១ ព្រមទាំងបញ្ចូលឯកសារដើមឲ្យឈ្មោះអ្នកទោសម្នាក់ៗនៅក្នុងបញ្ជី ។ ដោយសារតែឧបសគ្គជាច្រើនបានដាក់កំហិតលើពេលវេលា ការិយាល័យសហចៅក្រមស៊ើបអង្កេតបានត្រឹមតែត្រួតពិនិត្យបញ្ជីចូលឈ្មោះនៅមន្ទីរស-២១តែប៉ុណ្ណោះ ហើយក្រោយមកទៀតទើបក្រុមព្រះរាជអាជ្ញាពិនិត្យមើលកំណត់ត្រាពិឃាតទាំងអស់ដែលមានក្នុងបណ្តុំភ័ស្តុតាង ។ ក្រុមព្រះរាជអាជ្ញាបានធ្វើបច្ចុប្បន្នភាព លើបញ្ជីដោយបំពេញកាលបរិច្ឆេទពិឃាតណាដែល

នៅមានចន្លោះឲ្យឈ្មោះអ្នកទោសដែលមាននៅក្នុងបញ្ជីស្រាប់ ព្រមទាំងបញ្ចូលឈ្មោះអ្នកទោសទាំងឡាយណាដែលមិនទាន់ត្រូវបានចុះបញ្ជី ។ មូលហេតុដែលក្រុមព្រះរាជអាជ្ញាអាចរកឃើញឈ្មោះអ្នកទោសថ្មីៗបាន គឺដោយសារតែទាំងបញ្ជីចូល ឈ្មោះ និងបញ្ជីពិឃាតនៃមន្ទីរស-២១ នៅមានចន្លោះកំណត់ត្រាជាច្រើន ។

នៅពេលក្រុមព្រះរាជអាជ្ញាបានបញ្ចប់ការងារ ពួកគេបានកំណត់អត្តសញ្ញាណអ្នកទោសប្រមាណ១៨.០០០នាក់ ដែលត្រូវបានឃុំខ្លួនដើម្បីសួរចម្លើយនៅមន្ទីរស-២១ ហើយចំពោះបញ្ជីឈ្មោះដើមរបស់ការិយាល័យសហចៅក្រមស៊ើបអង្កេតដែលមានចំនួនកាលបរិច្ឆេទពិឃាតតែ៥.០០០ នោះព្រះរាជអាជ្ញាបានបញ្ចូលកាលបរិច្ឆេទពិឃាតចំនួន៦.០០០បន្ថែមទៀត ហើយសរុបមកកាលបរិច្ឆេទពិឃាតដែលបានបញ្ជាក់ទាំងអស់មានចំនួន ១១.០០០ ។

តមកទៀត លោក លីសាក់ បានលើកមកពិភាក្សាអំពីបញ្ហាសំខាន់ទាក់ទងនឹងតួនាទីរបស់ នួន ជា នៅមន្ទីរស-២១ ។ ភស្តុតាងមួយចំនួនក្នុងចំណោមភស្តុតាងដែលមានប្រសិទ្ធភាពខ្លាំងជាងគេក្នុងការវាយប្រហារ នួន ជា គឺមានប្រភពមកពី ឌុច ដោយគាត់បានផ្តល់សក្ខីកម្មថា គាត់ធ្វើការរាយការណ៍ដោយផ្ទាល់ជូន នួន ជា ក្រោយពេល សុន សេន ត្រូវបានចាត់តាំងឲ្យទៅសមរភូមិភាគខាងកើតដើម្បីបញ្ជាការទ័ពប្រយុទ្ធនឹងពួកវៀតណាម ។ នួន ជា បានចេញបញ្ជាផ្ទាល់ឲ្យ ឌុច ប្រតិបត្តិជាច្រើនរួមមានការបោសសម្អាតខ្លាំងនៅតំបន់បូព៌ា និងការបោសសម្អាតខ្មាំងក្នុងជួរកម្មាភិបាលនៃកងទ័ពបដិវត្តរហូតដល់ទីបញ្ចប់នៃរបបខ្មែរក្រហម ។ ចម្លើយសក្ខីកម្មរបស់ ឌុច ស្តីពីទំនាក់ទំនងរបស់គាត់ជាមួយ នួន ជា ក៏ត្រូវបានបញ្ជាក់ដោយភស្តុតាងឯកសារ និងសក្ខីកម្មរបស់សាក្សីដទៃទៀត ហើយចម្លើយនេះត្រូវបានលោក លីសាក់ រៀបរាប់យ៉ាងលម្អិត ។ ចម្លើយសក្ខីកម្មនេះរួមបញ្ចូលនូវកំណត់ហេតុសរសេរដៃរបស់ ឌុច ស្តីពីបញ្ជាដែលគាត់បានទទួលពី នួន ជា ឲ្យលុបឈ្មោះមួយចំនួនចេញពីចម្លើយសារភាពមួយ សក្ខីកម្មរបស់កងការពារ នួន ជា ថាគាត់បាននាំយកសំបុត្រមួយចំនួនពីជនជាប់ចោទ (នួន ជា) ទៅប្រគល់ឲ្យ ឌុច ដោយផ្ទាល់ ហើយទទួលយកស្រោមសំបុត្រយ៉ាងក្រាស់ជាច្រើនពី ឌុច រួចយកប្រគល់ត្រឡប់ឲ្យ នួន ជា វិញ ។ ជាចុងក្រោយបំផុត មានវីដេអូឃ្លីបមួយដែលបង្ហាញថា នួន ជា បានសារភាពប្រាប់លោក ថេត សម្បត្តិ ថា គាត់ពិតជាបានទទួលចម្លើយសារភាពជាច្រើនពី ឌុច ហើយបានយកចម្លើយទាំងនោះមកប្រើប្រាស់ក្នុងការអប់រំកម្មាភិបាលជាន់ទាប ។

លោក លីសាក់ បានបញ្ជាក់ថា ភស្តុតាងនេះហើយដែលបង្ហាញថាលោក នួន ជា ពិតជាបានដើរតួនាទីសំខាន់ក្នុងការិយាល័យ សន្តិសុខពិតមែន ។

បន្ទាប់មក លោក លីសាក់ បានពន្យល់ថាថ្វីបើ ខៀវ សំផន មិនបានដើរតួនាទីធំធេងដូច នួន ជា ចំពោះដំណើរការមន្ទីរស-២១ ក៏ដោយ ក៏ ខៀវ សំផន បានជ្រាបដឹងពីរឿងនេះច្បាស់លាស់ ហើយជាពិសេសគាត់បានរួមចំណែកយ៉ាងសំខាន់នៅក្នុងសហប្រតិបត្តិការឧក្រិដ្ឋកម្មទាំងនេះ ។

សូចនាករមួយនៃតួនាទីរបស់ ខៀវ សំផន បានចង្អុលបង្ហាញពីទំនួលខុសត្រូវរបស់គាត់ចំពោះសម្តេចនរោត្តម សីហនុ ដែលអាចថាបាន ថាគាត់ជាអ្នកទោសសំខាន់បំផុតនៅក្នុងប្រទេសកម្ពុជាកាលជំនាន់នោះ ។ នៅខែមីនា ឆ្នាំ១៩៧៦ ពេលដែលព្រះបាទនរោត្តម សីហនុ បានសុំលាលែងពីតំណែង ខៀវ សំផន គឺជាអ្នកដែលបានស្នើសុំទៅគណៈកម្មាធិការអចិន្ត្រៃយ៍ដែលក្រោយមកមានការសម្រេចថាមិនអនុញ្ញាតឲ្យព្រះអង្គចាកចេញពីប្រទេសបានឡើយ តែព្រះអង្គនឹងត្រូវឃុំព្រះកាយនៅក្នុងព្រះបរមរាជវាំង និងទុកព្រះអាយុឲ្យប្រសិនបើព្រះអង្គមិនប្រឆាំងរើបម្រាស់ ។ ពួកគេក៏បានសម្រេចឲ្យផ្ញើទូរលេខទៅកាន់បុត្ររបស់ព្រះអង្គឲ្យវិលត្រឡប់មកកម្ពុជាឲ្យបានឆាប់ក្នុងឱកាសប្រារព្ធពិធីបុណ្យចូលឆ្នាំថ្មី ។ ប៉ុន្តែ ហេតុផលពិតប្រាកដដែលពួកគេហៅបុត្រព្រះអង្គឲ្យត្រឡប់ចូលស្រុកវិញនោះ ត្រូវបានឯកភាពទទួលស្គាល់ក្នុងអំឡុងពេលនៃកិច្ចប្រជុំថាគឺដើម្បីឲ្យ "បញ្ហាអាចត្រូវបានដោះស្រាយដល់បុគ្គល" ។ លោក លីសាក់ បានបញ្ជាក់ថាយើងបានដឹងហើយថា ទាំងបុត្រ និងព្រះរាជវង្សានុវង្សជាច្រើនអង្គរបស់សម្តេចតាត្រូវបានធ្វើគុត ។

លោក លីសាក់ បានបង្ហាញវីដេអូឃ្លីបរបស់ ខៀវ សំផន ដែលក្នុងនោះ ខៀវ សំផន បានបង្ហាញថា គាត់បានដឹងពូពីកិច្ចប្រជុំ និងការសម្រេចចិត្តរបស់គណៈកម្មាធិការអចិន្ត្រៃយ៍ក្នុងការ

ចាប់ខ្លួនសមាជិករបស់បក្សកុម្មុយនីស្តកម្ពុជា ។ លោក លីសាក់ បង្ហាញថា ខៀវ សំផន បានពិពណ៌នាយ៉ាងលម្អិតនៅក្នុងវីដេអូឃ្លីប នេះអំពីការសម្រេចចិត្តចាប់ខ្លួនដែលធ្វើឡើងដោយ ប៉ុល ពត និង គណៈកម្មាធិការអចិន្ត្រៃយ៍ ។ សមាជិកគណៈកម្មាធិការអចិន្ត្រៃយ៍ ពីររូបដែលបានចូលរួមប្រជុំយ៉ាងទៀងទាត់ជាមួយ ខៀវ សំផន និង នួន ជា ត្រូវបានចាប់ខ្លួនបញ្ជូនទៅមន្ទីរស-២១ ហើយក្រោយ មកសមមិត្ត និងសហសេវិករបស់ ខៀវ សំផន ក៏ត្រូវបានចាប់ខ្លួន បញ្ជូនទៅមន្ទីរស២១ផងដែរ ។ ទោះបីជាយ៉ាងនេះក្តី លោក ខៀវ សំផន នៅតែបន្តគាំទ្រ និងអនុវត្តយ៉ាងពេញទំហឹងនូវគោលនយោ បាយបក្សកុម្មុយនីស្តកម្ពុជា ។ ភ្លាមៗបន្ទាប់ពីការចាប់ខ្លួននៃ សមមិត្តរបស់គាត់ក្នុងឆ្នាំ១៩៧៧ ខៀវ សំផន បានលើកបញ្ជាក់ ថា «យើងដាច់ខាតត្រូវតែអនុវត្តតាមគោលនយោបាយបក្ស កុម្មុយនីស្តកម្ពុជា ហើយការអនុវត្តគ្រប់យ៉ាងត្រូវធ្វើប្រកបដោយ ភាពរៀបរយ និងហ្មត់ចត់» ។

ក្នុងបទសម្ភាសជាមួយលោក ស៊ីវ ហេង៍រ ៖ ខៀវ សំផន បាននិយាយបកស្រាយយ៉ាងទូលំទូលាយអំពីការដែលភ្នាក់ងារ វៀតណាមបានបង្កប់ខ្លួនក្នុងរចនាសម្ព័ន្ធខ្ពស់បំផុតរបស់បក្ស ដែល ក្នុងនោះរួមមានគណៈកម្មាធិការអចិន្ត្រៃយ៍ និងគណៈកម្មាធិការ មជ្ឈិម ។ ជនជាប់ចោទ ខៀវ សំផន បានលើកឡើងថា «យើងបាន សម្រេចជោគជ័យក្នុងការចាត់ការពួកនោះទាំងស្រុង» ។

លោក លីសាក់ បានបញ្ជាក់ថា ភ័ស្តុតាងនេះបង្ហាញឲ្យ ឃើញថាលោក ខៀវ សំផន បានកុហកម្តងហើយម្តងទៀតនៅមុខ ការិយាល័យសហចៅក្រមស៊ើបអង្កេតថា លោកមិនបានដឹងពីការ ចាប់ខ្លួននរណាម្នាក់ក្នុងអំឡុងរបបកម្ពុជាប្រជាធិបតេយ្យនៅទេ ។ ជាទីបញ្ចប់ លោក លីសាក់ បានធ្វើការពិភាក្សាអំពីភ័ស្តុតាង ពាក់ព័ន្ធនឹងកិច្ចប្រជុំអប់រំនយោបាយ និងការគាំទ្ររបស់ជនជាប់ ចោទ (នួន ជា) ចំពោះគោលនយោបាយបក្សកុម្មុយនីស្តកម្ពុជា ។ លោកបានកត់សម្គាល់ថា នៅក្នុងសវនាការជំនុំជម្រះទាំងពីរនេះ អង្គជំនុំជម្រះបានជ្រាបដឹងពីកិច្ចប្រជុំអប់រំនយោបាយដែលរៀប ចំដោយជនជាប់ចោទនីមួយៗ (ខៀវ សំផន និង នួន ជា) ឬទាំងពីរ នាក់រួមគ្នានៅពេលខ្លះ ព្រមទាំងបានដឹងពីការរៀបរាប់របស់ សាក្សីអំពីកិច្ចប្រជុំអប់រំនយោបាយ ។ ក្នុងចំណោមសាក្សីទាំង នោះ មានសាក្សីម្នាក់ធ្លាប់ស្តាប់ខ្សែអាត់សំឡេងចម្លើយសារភាព ដែល នួន ជា បានចាក់ក្នុងកិច្ចប្រជុំមួយ ។

លោក លីសាក់ បានរំឭកឡើងវិញនូវការផ្តល់សុន្ទរកថា មួយរបស់ ខៀវ សំផន ទៅកាន់ប្រជាជននៅភូមិភាគបូព៌ាដែលក្នុង នោះគាត់បានបង្គាប់ប្រជាជនកុំឲ្យហ៊ានក្បត់បក្សឲ្យសោះ បើមិន ដូច្នេះទេនឹងត្រូវយកទៅសម្លាប់ជាមិនខាន ។ នៅក្នុងបទសម្ភាសន៍ មួយជាមួយលោក ថេត សម្បត្តិ, នួន ជា បានបញ្ជាក់យ៉ាងច្បាស់ ពីការគាំទ្រពេញទំហឹងរបស់គាត់ចំពោះការសម្លាប់ជនក្បត់របប នេះដោយគាត់បាននិយាយថា ការសម្លាប់ជនក្បត់បានជួយសង្គ្រោះ ប្រជាជនខ្មែរ ដូច្នេះហើយការបញ្ជាឲ្យសម្លាប់ជនក្បត់ពិតជាការ សម្រេចចិត្តដ៏ត្រឹមត្រូវបំផុត ។ គាត់ក៏បាននិយាយដែរថា ប្រសិន បើមានបុគ្គលណាម្នាក់ក្លាយជាបញ្ហាខបសគ្គរបស់យើង យើង ត្រូវតែធ្វើការចាត់ការលើបុគ្គលនោះ ។ នួន ជា បានសារភាព ដោយផ្ទាល់ថា ខ្លួនពុំមានការសោកស្តាយបន្តិចណាឡើយចំពោះ អ្នកដែលត្រូវបានសម្លាប់ ដោយសារតែបុគ្គលទាំងនោះ គឺជា សត្រូវរបស់ប្រជាពលរដ្ឋ ។ គាត់បានយឯកភាពនឹងការសម្រេច ចិត្តរបស់ ប៉ុល ពត ក្នុងការសម្លាប់ជនក្បត់ទាំងអស់នៅពេលនោះ ដោយសារតែនៅគ្រានោះគាត់គ្រាន់តែចង់ដោះស្រាយបញ្ហា ប៉ុណ្ណោះហើយការសម្រេចចិត្តសម្លាប់ជនក្បត់គឺជាដំណោះ ស្រាយដ៏ត្រឹមត្រូវបំផុត ។ ក្រោយមក លោក ថេត សម្បត្តិ បាន សួរទៅកាន់ នួន ជា ថា ហេតុអ្វីបានជាមេដឹកនាំបក្សកុម្មុយនីស្ត កម្ពុជាត្រូវតែសម្លាប់ជនក្បត់ជំនួសឲ្យការដាក់គុកពួកគេអស់មួយ ជីវិត? នួន ជា បានឆ្លើយតបថា «សំណួរនេះជាសំណួរដែលងាយ ស្រួលសួរណាស់ ប៉ុន្តែវាពិបាកក្នុងការឆ្លើយ ។ នៅគ្រានោះ យើងពុំមានពន្ធនាគារត្រឹមត្រូវទេ តែប្រសិនបើយើងរក្សាពួកគេ ក្នុងគុក ពួកគេប្រាកដជានឹងរីករាលដាល និងបង្កបក្ខពួក ហើយ យើងនឹងត្រូវសម្លាប់ក្នាពួកគេជាច្រើនទៀត» ។ លោក លីសាក់ បានកត់សម្គាល់ថា ការគាំទ្ររបស់ នួន ជា ចំពោះការសម្លាប់មិន ត្រឹមតែសំដៅទៅជនដែលត្រូវចោទប្រកាន់ពីបទក្បត់បក្សនោះ ទេ តែការសម្លាប់នេះក៏សំដៅទៅអ្នកដែលពាក់ព័ន្ធនឹងជនជាប់ ចោទផងដែរ ។

**វ៉ូនិត អាវី**

# ជនសង្ស័យនៅក្នុងសំណុំរឿង០០៤ មិនត្រូវបានអនុញ្ញាតឱ្យពិនិត្យមើលសំណុំរឿង

សហចៅក្រមស៊ើបអង្កេតអន្តរជាតិ ដែលចេញសេចក្តីសម្រេចតែម្នាក់ឯង បានប្រានចោលសិទ្ធិរបស់ជនសង្ស័យក្នុងសំណុំរឿង០០៣ និង ០០៤ ក្នុងការចូលពិនិត្យមើលសំណុំរឿង និងចូលរួមក្នុងកិច្ចដំណើរការស៊ើបសួរជាលើកចុងក្រោយ នៅអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ។ សំណុំរឿង០០៣ និង ០០៤ ត្រូវបានដាក់ឲ្យស្ថិតនៅក្រោមការស៊ើបសួរចាប់តាំងពីខែកញ្ញា ឆ្នាំ២០០៩ រហូតមានការតែងតាំងចៅក្រមអន្តរជាតិ៤រូបផ្សេងគ្នា និងមានការលោតត្រដាងជាបន្តបន្ទាប់នូវការរារាំងផ្នែករដ្ឋបាល និងតុលាការចំពោះដំណើរការរបស់ខ្លួន ។ ទោះបីគ្មានជនសង្ស័យណាម្នាក់ត្រូវបានបញ្ជាក់ឈ្មោះ ឬចោទប្រកាន់ជាផ្លូវការនៅក្នុងសំណុំរឿងទាំងពីរនេះ ឈ្មោះជនសង្ស័យដែលមានវ័យចំណាស់ចំនួន៥រូប (ជនសង្ស័យម្នាក់ ក្នុងចំណោមអ្នកទាំង៥នាក់នោះ បានទទួលមរណភាពនៅខែមិថុនា ឆ្នាំ២០១៣) និងលក្ខណៈទូទៅនៃបទចោទប្រកាន់ ត្រូវបានគេដឹងជាសាធារណៈចាប់តាំងពីពាក់កណ្តាលឆ្នាំ២០១១មក ហើយជនសង្ស័យទាំងនោះត្រូវបានអ្នកសារព័ត៌មានជាតិ និងអន្តរជាតិស្វែងរក និងសម្ភាសម្តងហើយម្តងទៀត ។

នៅដើមឆ្នាំ២០១០ អង្គភាពគាំពារការការពារក្តីរបស់អង្គជំនុំជម្រះវិសាមញ្ញ បានព្យាយាមស្នើសុំជាច្រើនដងក្នុងផ្តល់អ្នកតំណាងផ្លូវច្បាប់ជូនជនសង្ស័យទាំងនោះ រួមបញ្ចូលទាំងការពិនិត្យមើលសំណុំរឿង ដោយអះអាងថា "ការបន្តដំណើរការនីតិវិធីទាំងនោះ ដោយពុំមានការចូលរួមពីមេធាវីការពារក្តី និងរំលោភបំពានលើផ្នែកជាច្រើននៃសិទ្ធិទទួលបានការជំនុំជម្រះក្តីប្រកបដោយយុត្តិធម៌ រួមទាំងសិទ្ធិទទួលបានសមភាពនៃមធ្យោបាយតតាំងក្តី


តា អាន ជនសង្ស័យនៅក្នុងសំណុំរឿង០០៤


តា ទិត្យ ជនសង្ស័យនៅក្នុងសំណុំរឿង០០៤

សិទ្ធិទទួលបានការតំណាងប្រកបដោយប្រសិទ្ធភាព និងសិទ្ធិទទួលបានការគោរពគោលការណ៍ចំពោះមុខ» ។ ទាំងសហចៅក្រមស៊ើបអង្កេត និងអង្គបុរេជំនុំជម្រះ បានច្រានចោលសំណើទាំងនោះ ដោយចេញសេចក្តីសម្រេចថា សិទ្ធិទាំងឡាយដែលអង្គភាពគាំពារការការពារក្តីរៀបរាប់នោះ គឺផ្តល់ជូនសម្រាប់តែជនសង្ស័យណាម្នាក់ដែលត្រូវបាននាំមកនៅចំពោះមុខចៅក្រម ឬត្រូវបានចោទប្រកាន់តែប៉ុណ្ណោះ ។ ទោះបីជាយ៉ាងណាក៏ដោយចៅក្រម ម៉ាក ហាម៉ុន ដែលកំពុងកាន់តំណែងជាសហចៅក្រមស៊ើបអង្កេតអន្តរជាតិ បានបញ្ជាក់ថា ដោយសារតែបុព្វាធិការីអ្នកបម្រើការមុនរបស់គាត់ គឺលោកសហចៅក្រមស៊ើបអង្កេតអន្តរជាតិបម្រុង កាស្តើ អានសឺម៉េត បានជូនដំណឹងដល់ជនសង្ស័យក្នុងសំណុំរឿង០០៤ អំពីឋានៈជា «ជនសង្ស័យ» និងប្រាប់ជនសង្ស័យនោះថា មានសិទ្ធិទទួលបានមេធាវីការពារក្តី ដូច្នេះជនសង្ស័យនោះត្រូវបានផ្តល់សិទ្ធិទទួលបានមេធាវីការពារក្តី ធ្វើជាតំណាង ដូចមានចែងក្នុងវិធាន២១(១)(ឃ) នៃវិធានផ្ទៃក្នុងរបស់អង្គជំនុំជម្រះវិសាមញ្ញ និងទទួលបានមេធាវីដែលបង់កម្រៃសេវាដោយតុលាការ ។ ដូច្នេះ ចៅក្រម ហាម៉ុន ទទួលស្គាល់ជាផ្លូវការនូវឋានៈជាសហមេធាវីការពារក្តីជាតិ និងអន្តរជាតិរបស់ជនសង្ស័យ ។ ទោះបីជាយ៉ាងណា ចៅក្រម ហាម៉ុន មិនអនុញ្ញាតឲ្យសហមេធាវីរបស់ជនសង្ស័យនោះពិនិត្យមើលសំណុំរឿងឡើយ ។

ដោយកត់សម្គាល់ថា សហចៅក្រមស៊ើបអង្កេតអន្តរជាតិ ហាម៉ុន ធ្លាប់បានអនុញ្ញាតឲ្យមេធាវីដើមបណ្តឹងរដ្ឋប្បវេណីដែលត្រូវបានទទួលស្គាល់នៅក្នុងសំណុំរឿង០០៤ ចូលពិនិត្យសំណុំរឿង មេធាវីរបស់ជនសង្ស័យអះអាងថា ខ្លួនត្រូវតែបានអនុញ្ញាតឲ្យចូលពិនិត្យមើលសំណុំរឿងដែរ ដើម្បីធានានូវសមភាពនៃមធ្យោបាយតតាំងក្តីរវាងភាគីទាំងពីរ ។ បន្ថែមលើនេះទៀត មេធាវីជនសង្ស័យកត់សម្គាល់ថា ថ្វីត្បិតការស៊ើបអង្កេតនៅតែបន្តធ្វើជាសម្ងាត់ ប៉ុន្តែឈ្មោះរបស់ជនសង្ស័យ និងបទចោទប្រកាន់ដោយសហព្រះរាជអាជ្ញាប្រឆាំងនឹងជនសង្ស័យ ត្រូវបានពិភាក្សានៅក្នុងប្រព័ន្ធផ្សព្វផ្សាយព័ត៌មាន ។ ក្រុមមេធាវីជនសង្ស័យចង់ដឹងបទចោទប្រកាន់ជាក់លាក់ ដើម្បីអាចការពារសិទ្ធិកូនក្តីរបស់ខ្លួនបាន ។ ក្រុមមេធាវីការពារក្តីស្នើសុំបន្ថែមទៀតនូវសិទ្ធិតតាំងជាមួយសាក្សីទាំងអស់ ដែលបានសម្ភាសដោយសហចៅក្រមស៊ើបអង្កេត និងសិទ្ធិដែលត្រូវបានអនុញ្ញាតឲ្យចោទសំណួរទៅសាក្សីទាំងនោះតាមរយៈសហចៅក្រមស៊ើបអង្កេត ។

នៅក្នុងសេចក្តីសម្រេចដែលធ្វើនៅខែកក្កដា បានចេញផ្សាយជាសាធារណៈនៅសប្តាហ៍មុននេះ ចៅក្រម ហាម៉ុន បានឆ្លើយតបថា គឺពុំដូចជាការទទួលស្គាល់ដើមបណ្តឹងរដ្ឋប្បវេណីឡើយ ដោយបញ្ជាក់ថា «វិធានផ្ទៃក្នុងបែងចែកយ៉ាងច្បាស់រវាងជនសង្ស័យ និងជនត្រូវចោទ ហើយផ្តល់សិទ្ធិជូនជនត្រូវចោទកាន់តែទូលំទូលាយ» ។ ចៅក្រម ហាម៉ុន រកឃើញថា វិធានផ្ទៃក្នុងរក្សាទុកសិទ្ធិចូលពិនិត្យមើលសំណុំរឿងសម្រាប់ភាគីនៅក្នុងដំណើរការនីតិវិធី ដែលជនសង្ស័យពុំត្រូវបានរាប់បញ្ចូលជាភាគីនៅក្នុងកិច្ចដំណើរការនីតិវិធីឡើយ ។ ដូចគ្នានេះដែរ នៅក្រោមវិធានផ្ទៃក្នុងមានតែភាគីតែប៉ុណ្ណោះដែលអាចចូលរួមកិច្ចដំណើរការស៊ើបសួរ ។ ការដែលចៅក្រម ហាម៉ុន រកឃើញដូច្នេះ គឺបានផ្តល់ដោយយុត្តិសាស្ត្រអន្តរជាតិ ដែល «បញ្ជាក់ថា លក្ខណៈជាសារវន្តនៃសិទ្ធិពិនិត្យមើលសំណុំរឿង ត្រូវបានទទួលស្គាល់ចំពោះជនទាំងឡាយណាដែលត្រូវបានចោទប្រកាន់» ។

នៅក្រោមវិធានផ្ទៃក្នុងរបស់អង្គជំនុំជម្រះវិសាមញ្ញ «សហចៅក្រមស៊ើបអង្កេតមានសិទ្ធិអំណាចសម្រេចចោទប្រកាន់ចំពោះជនសង្ស័យដែលមានឈ្មោះនៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួររបស់សហព្រះរាជអាជ្ញា ឬជនផ្សេងៗទៀតដែលមានភស្តុតាងច្បាស់លាស់ និងអាចជឿជាក់បាន» ។ យោងទៅលើការលើកឡើងរបស់សហចៅក្រមស៊ើបអង្កេត ដំណើរការនៃការចោទប្រកាន់គឺរួមបញ្ចូលទាំងការវាយតម្លៃអំពីការទទួលខុសត្រូវចំពោះឧក្រិដ្ឋកម្ម អង្គហេតុនៃអំពើឧក្រិដ្ឋដែលជូនដំណឹងដល់ជនសង្ស័យ និងការកំណត់បទល្មើសនៃអំពើឧក្រិដ្ឋដែលដាក់ឲ្យស្ថិតនៅក្រោមការស៊ើបសួរ ។ សម្រាប់ហេតុផលនេះត្រឹមតែអង្គហេតុដែលសហចៅក្រមស៊ើបអង្កេតអន្តរជាតិបម្រុង ជូនដំណឹងដល់ជនសង្ស័យអំពីបទចោទប្រកាន់របស់សហព្រះរាជអាជ្ញា គឺពុំធ្វើឲ្យជនសង្ស័យនោះក្លាយជា «ជនត្រូវចោទ» ឬផ្តល់សិទ្ធិឲ្យជននោះចូលពិនិត្យមើលសំណុំរឿងឡើយ ។ ទោះបីជាសហចៅក្រមស៊ើបអង្កេតអន្តរជាតិបម្រុង បានផ្តល់យ៉ាងជាក់លាក់ឲ្យជនសង្ស័យនោះមានសិទ្ធិ

ចូលពិនិត្យមើលសំណុំរឿង «នេះជាការរំលោភលើវិធានផ្ទៃក្នុង» ព្រោះថា ជនសង្ស័យនោះពុំទាន់ត្រូវបានចោទប្រកាន់ជាផ្លូវការ ហើយ «បង្កើតឲ្យមានការរំលោភបំពានលើឆន្ទានុសិទ្ធិតុលាការ» ពីព្រោះការសម្រេចនេះធ្វើឡើងដោយគ្មានសំអាងហេតុគាំទ្រ ។ អស់រយៈពេលមួយឆ្នាំ នៅក្នុងកិច្ចការស៊ើបអង្កេតរបស់ខ្លួន ចៅក្រម ហាម៉ុន «ពុំទាន់បានកំណត់នូវឡើយថា (ភ័ស្តុតាងច្បាស់លាស់ និងអាចជឿជាក់បាន) នេះ ត្រឹមកម្រិតណាអាចទទួលយកបាន» ។ ហេតុដូច្នេះចៅក្រម ហាម៉ុន ធ្វើមោឃភាពសេចក្តីសម្រេចរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិបម្រុង ត្រង់ចំណុចដែលអនុញ្ញាតឲ្យជនសង្ស័យមានសិទ្ធិចូលពិនិត្យមើលសំណុំរឿង ។

បន្ទាប់មកចៅក្រម ហាម៉ុន បានពិចារណាថា តើមានកត្តាផ្សេងៗទៀតដែលអនុញ្ញាតឲ្យចូលពិនិត្យមើលសំណុំរឿង និងថា តើជនសង្ស័យត្រូវបាន «ប៉ះពាល់យ៉ាងធ្ងន់ធ្ងរ» ដោយសារការស៊ើបអង្កេតដែរឬអត់ ។ ចៅក្រម ហាម៉ុន បានកត់សម្គាល់ថា តាមយុត្តិសាស្ត្ររបស់តុលាការសិទ្ធិមនុស្សអឺរ៉ុប និងសាលាក្តីពិសេសសម្រាប់លីបង់ ចង្អុលបង្ហាញថា នៅពេលជនណាម្នាក់ត្រូវបានឃុំខ្លួន «ទោះបីគ្មានការចោទប្រកាន់ជាផ្លូវការក៏ដោយ» ជននោះគួរត្រូវបានអនុញ្ញាតឲ្យចូលពិនិត្យមើលសំណុំរឿង ដើម្បីតតាំងអំពីភាពស្របច្បាប់ចំពោះការឃុំខ្លួន និងបានកំណត់ថា ការដែលគ្រាន់តែទទួលបានការជូនដំណឹងថា ជននោះកំពុងដាក់ឲ្យស្ថិតនៅក្រោមការស៊ើបអង្កេតចំពោះឧក្រិដ្ឋកម្មធ្ងន់ធ្ងរ គឺមិនមែនជាលក្ខខណ្ឌដែលអាចធ្វើការប្រៀបធៀបបានឡើយ ។

ការដោះស្រាយសម្រាប់ផលប៉ះពាល់ជាលើកដំបូងដោយសារការចាប់អារម្មណ៍របស់ប្រព័ន្ធផ្សព្វផ្សាយ ដែលឈានទៅដល់ការបង្ហាញជនសង្ស័យ និងបទចោទប្រកាន់ មុនពេលជនសង្ស័យនោះទទួលបានការជូនដំណឹងអំពីសិទ្ធិមានមេធាវីការពារក្តី និងសិទ្ធិនៅស្ងៀមមិនឆ្លើយតប ចៅក្រម ហាម៉ុន រកឃើញថា «ការចាប់អារម្មណ៍របស់ប្រព័ន្ធផ្សព្វផ្សាយ គឺមិនមែនជាកត្តា» និងមិន «មានទម្ងន់ ឬតម្រូវឲ្យមានដំណោះស្រាយដូចគ្នា» ទៅនឹងជនណាម្នាក់ដែលត្រូវបានឃុំខ្លួនឡើយ ។ ចៅក្រម ហាម៉ុន សម្រេចថា ការតំណាងដោយមេធាវីការពារក្តីសម្រាប់ជនសង្ស័យនៅក្នុងសំណុំរឿង០០៤ នាពេលបច្ចុប្បន្ន ការជូនដំណឹងជនសង្ស័យអំពីបទចោទប្រកាន់ និងប្រាប់អំពីសិទ្ធិនៅស្ងៀមមិនឆ្លើយតប គឺ «បានធានាគ្រប់គ្រាន់សម្រាប់សិទ្ធិរបស់ជនសង្ស័យ និងគោរពតាមបទដ្ឋានយុត្តិធម៌អន្តរជាតិបានយ៉ាងពេញលេញ» ។

ដូច្នេះចៅក្រម ហាម៉ុន រកឃើញថា ពុំមានយុត្តិកម្មដើម្បីផាកចេញពីលក្ខខណ្ឌតម្រូវនៃវិធានផ្ទៃក្នុងឡើយ ។

**អាន ហាញដល**



អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា (រូបថត៖ អ.វ.ត.ក)

# សហចៅក្រមស៊ើបអង្កេត ចេញសំអាង ហេតុលើកលែងការចោទប្រកាន់សំណុំរឿង០០៤/១

នៅថ្ងៃនេះ សហចៅក្រមស៊ើបអង្កេត (ស.ច.ស) បានចេញសំអាងហេតុសម្រាប់ដីកាដំណោះស្រាយដែលបានចេញកាលពីថ្ងៃទី២២ ខែកុម្ភៈ ឆ្នាំ២០១៧ និងដែល ស.ច.ស បានលើកលែងការចោទប្រកាន់លើ អ៊ឹម ចែម ដោយសារមិនមានយុត្តាធិការបុគ្គលគ្រប់គ្រាន់ ។ នៅក្នុងសេចក្តីប្រកាសព័ត៌មាននេះ ស.ច.ស សង្ខេបអំពីសំអាងហេតុចម្បងៗនៃការលើកលែងការចោទប្រកាន់នេះ ។ សាធារណជនអាចរកបានសំណៅកោសលុបនៃសំអាងហេតុដែលលម្អិតជាងនេះ នៅគេហទំព័ររបស់ អ.វ.ត.ក៖

*https://www.eccc.gov.kh/document/court/39772*

*https://eccc.gov.kh/document/court/39770*

ដោយសារមានការលើកលែងការចោទប្រកាន់ដោយមូលហេតុថាមិនមានយុត្តាធិការគ្រប់គ្រាន់នោះ ទើប អ៊ឹម ចែម នៅតែបន្តមានសិទ្ធិទទួលបានការសន្មតថាគ្មានទោស និងសិទ្ធិឯកជនរបស់គាត់ដែលបណ្តាលឲ្យមានការរឹតត្បិតនូវព័ត៌មានមួយចំនួនដែលអាចផ្សព្វផ្សាយជាសាធារណៈ ហើយការរឹតត្បិតនេះមានលក្ខណៈគឺឯរ៉ុងជាងករណីដែលបញ្ជូនគាត់ទៅជំនុំជម្រះ ។ សិទ្ធិទាំងនេះអនុវត្តបានមែន ប៉ុន្តែនៅតែអាចបើកផ្លូវឲ្យសាធារណជនទទួលបាននូវព័ត៌មានគ្រប់គ្រាន់អំពីការវិវត្តនៃកិច្ចដំណើរការនីតិវិធី ។ ទោះជាយ៉ាងណាក៏ដោយ ការលើកលែងការចោទប្រកាន់ដោយមូលហេតុថាមិនមានយុត្តាធិការគ្រប់គ្រាន់នេះ មិនមែនមានន័យថា ជនត្រូវចោទពុំបានប្រព្រឹត្តឧក្រិដ្ឋកម្មណាមួយឡើយ ។ ហេតុនេះសេណារីយ៉ូដែលលើកឡើងដោយគ្មានព្រំដែនកំណត់ថា ជនត្រូវចោទបាន "រួចផុត" ពីបទចោទហើយ ដូចដែលធ្លាប់បានលើកឡើងកន្លងមកនៅក្នុងប្រព័ន្ធផ្សព្វផ្សាយខ្លះចំពោះសំណុំរឿងនេះ គឺមិនត្រឹមត្រូវឡើយ ។ ជាសេណារីយ៉ូពុំត្រឹមត្រូវឡើយដែលសារព័ត៌មានមួយចំនួនពុំបានគិតពិចារណាឲ្យបានស៊ីជម្រៅក្នុងការលើកឡើងថា បទចោទប្រកាន់នានាត្រូវបានលុបលាងចេញចំពោះជនត្រូវចោទ ។

នៅក្នុងដីកាដំណោះស្រាយ ការសិក្សាអង្គហេតុគឺផ្អែកលើបទដ្ឋាននៃព្រឹត្តិការណ៍ដែលអាចនឹងកើតឡើង ដែលជាលក្ខខណ្ឌ



អ៊ឹម ចែម ជនសង្ស័យនៅក្នុងសំណុំរឿង០០៤/១ ដែលត្រូវតុលាការលើកលែងការចោទប្រកាន់ បច្ចុប្បន្នរស់នៅឃុំត្រពាំងតាវ ស្រុកអន្លង់វែង ខេត្តឧត្តរមានជ័យ

តម្រូវសម្រាប់ចេញដី កាសម្រេចបញ្ជូនរឿងទៅជំនុំជម្រះ ហើយមិនមែនផ្អែកលើបទដ្ឋាន «គ្មានវិមតិសង្ស័យ» ដែលជាលក្ខខណ្ឌសម្រាប់ចេញសេចក្តីសម្រេចផ្តន្ទាទោសបន្ទាប់ពីការជំនុំជម្រះក្តីនោះទេ ។ ប៉ុន្តែ ការសម្រេចជាទូទៅរបស់ ស.ច.ស ដែលថា អ៊ឹម ចែម មិនស្ថិតនៅក្នុងយុត្តាធិការបុគ្គលរបស់ អ.វ.ត.ក គឺជាការសម្រេចដែលធ្វើឡើងដោយបានពិចារណាយ៉ាងល្អិតល្អន់បំផុតលើភ័ស្តុតាងដែលមាន ។

### យុត្តាធិការបុគ្គលនៅ អ.វ.ត.ក និងជំហររបស់ អ.វ.ត.ក នៅក្នុងប្រព័ន្ធច្បាប់កម្ពុជា

គោលបំណងនៃកិច្ចព្រមព្រៀងរវាងអង្គការសហប្រជាជាតិ ជាមួយប្រទេសកម្ពុជា ចុះថ្ងៃទី០៦ ខែមិថុនា ឆ្នាំ២០០៣ «គឺកំណត់អំពីកិច្ចសហប្រតិបត្តិការរវាងអង្គការសហប្រជាជាតិនិងរាជរដ្ឋាភិបាលកម្ពុជាដើម្បីកាត់សេចក្តីមេដឹកនាំជាន់ខ្ពស់កម្ពុជាប្រជាធិបតេយ្យនិងជនទាំងឡាយដែលទទួលខុសត្រូវខ្ពស់បំផុតចំពោះឧក្រិដ្ឋកម្ម [...] ដែលបានប្រព្រឹត្តនៅក្នុងអំឡុងថ្ងៃទី ១៧ ខែមេសា ឆ្នាំ១៩៧៥ ដល់ ថ្ងៃទី៦ ខែមករា ឆ្នាំ១៩៧៩» ។ អង្គជំនុំជម្រះតុលាការកំពូល (អ.ជ.ត.ក) របស់ អ.វ.ត.ក បានបកស្រាយថា ពាក្យ «មេដឹកនាំជាន់ខ្ពស់កម្ពុជាប្រជាធិបតេយ្យ និងជនទាំងឡាយដែលទទួលខុសត្រូវខ្ពស់បំផុត» សំដៅលើជនពីរប្រភេទគឺមេដឹកនាំខ្មែរក្រហមជាន់ខ្ពស់ដែលស្ថិតនៅក្នុងចំណោមជនទាំងឡាយដែលទទួលខុសត្រូវខ្ពស់បំផុត និងជនដែលមិនមែនជាមេដឹកនាំខ្មែរក្រហមជាន់ខ្ពស់ ប៉ុន្តែជាជនស្ថិតនៅក្នុងចំណោមជនទាំងឡាយដែលទទួលខុសត្រូវខ្ពស់បំផុត ។ ជនទាំងពីរប្រភេទនេះត្រូវតែជាមន្ត្រីខ្មែរក្រហម និងស្ថិតនៅក្នុងចំណោមជនទាំងឡាយដែលទទួលខុសត្រូវខ្ពស់បំផុត ហើយលក្ខណៈវិនិច្ឆ័យទាំងនេះមានលក្ខណៈត្រួតលើគ្នា មិនមែនដាច់ដោយឡែកពីគ្នាទេ ។

តុលាការធម្មតារបស់កម្ពុជា មិនមានយុត្តាធិការសេសសល់ណាមួយលើឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តឡើងដោយជនដែលមិនស្ថិតនៅក្នុងប្រភេទជា «មេដឹកនាំជាន់ខ្ពស់» ឬ «ជនទាំងឡាយដែលទទួលខុសត្រូវខ្ពស់បំផុត» ទេ ។ ការសិក្សាយ៉ាងល្អិតល្អន់លើប្រវត្តិនៃការចរចាគ្នាមុនពេលបង្កើត អ.វ.ត.ក និងការវិវត្តនានាចាប់តាំងពីពេលនោះមកបង្ហាញឲ្យឃើញថា នាពេលបច្ចុប្បន្ននេះតុលាការកម្ពុជាផ្សេងទៀតពុំមានយុត្តាធិការលើបុគ្គល ឬ ព្រឹត្តិការណ៍នានាដែលស្ថិតនៅក្នុងយុត្តាធិការបុគ្គល យុត្តាធិការពេលវេលានិងយុត្តាធិការរឿងក្តីរបស់ អ.វ.ត.ក ទេ ។ ហេតុនេះ អាចមានទស្សីករណេលើកឡើងថា ស.ច.ស គួរតែប្រឆាំងតបនឹងទស្សនៈដែលបានស្តែងឲ្យឃើញជាក់ច្បាស់បែបនេះ ហើយអនុវត្តនូវឆន្ទានុសិទ្ធិរបស់ខ្លួនឲ្យបានទូលំទូលាយតាមដែលអាចធ្វើទៅបានដើម្បីគាំទ្រឲ្យមានយុត្តាធិការបុគ្គលចៀសវាងកុំឲ្យមានសំណល់នៃគម្លាតនិទណ្ឌភាព ។ ស.ច.ស ពុំយល់ស្របតាមទស្សីករណ៍បែបនេះទេ ។ ទាំងរដ្ឋាភិបាលកម្ពុជា ទាំងអង្គការសហប្រជាជាតិមិនដែលមានការប៉ុនប៉ងណាមួយក្នុងការស៊ើបអង្កេត និងការកាត់សេចក្តីជនណាម្នាក់ដែលមិនបានបំពេញតាមលក្ខខណ្ឌយុត្តាធិការបុគ្គលរបស់ អ.វ.ត.ក ឡើយ ។ គឺជាការសមហេតុផលណាស់ ដែលគោលបំណងស្វែងរកសន្តិភាព និងការផ្សះផ្សាជាតិដែលតម្រូវឲ្យធ្វើសមាហរណកម្មខ្មែរក្រហមចូលក្នុងសង្គមជាតិវិញ គឺជាអំណះអំណាងសំខាន់បំផុតរបស់រដ្ឋាភិបាលកម្ពុជា ។អ្នកតាក់តែងសេចក្តីព្រាងច្បាប់ស្តីពីការបង្កើត អ.វ.ត.ក បានដឹងថា មានប្រភេទនៃចារីចំនួនដ៏ច្រើនសន្ធឹកសន្ធាប់ ហើយពួកគេនឹងមិនត្រូវជំនុំជម្រះក្តីនៅចំពោះមុខ អ.វ.ត.ក ទេ ។ ត្រង់ចំណុចនេះដើម្បីព្យាយាមឲ្យដឹងកាន់តែច្រើនតាមដែលអាចធ្វើទៅបានអំពីគោលបំណងរបស់ភាគីនៅក្នុងកិច្ចព្រមព្រៀងស្តីការបង្កើត អ.វ.ត.ក សហចៅក្រមស៊ើបអង្កេតអន្តរជាតិ បានស្នើសុំពីផ្នែកបណ្ណសាររបស់អង្គការសហប្រជាជាតិនូវកំណត់ហេតុនៃការចរចាគ្នារវាងអង្គការសហប្រជាជាតិ ជាមួយរដ្ឋាភិបាលកម្ពុជា ក៏ប៉ុន្តែអង្គការសហប្រជាជាតិបានបដិសេធមិនបង្ហាញឯកសារភាគច្រើនក្នុងចំណោមឯកសារដែលបានស្នើសុំទេ ដោយផ្អែកលើមូលហេតុរក្សានូវការសម្ងាត់ ។

ហេតុនេះ អានុភាពនៃច្បាប់ស្តីពីយុត្តាធិការបុគ្គល មានពីរផ្នែកៈ

ក) ច្បាប់នេះកម្រិតយុត្តាធិការបុគ្គលផ្ទាល់ របស់ អ.វ.ត.ក នៅត្រឹមជនទាំងឡាយដែលទទួលខុសត្រូវខ្ពស់បំផុត និង

ខ) ច្បាប់នេះមិនរាប់បញ្ចូលយុត្តាធិការនៅតុលាការធម្មតារបស់ប្រទេសកម្ពុជា លើព្រឹត្តិការណ៍នានាដែលស្ថិតនៅក្នុងយុត្តាធិការពេលវេលារបស់ អ.វ.ត.ក ។

## គោលការណ៍ច្បាប់ព្រហ្មទណ្ឌ

ក្នុងចំណោមកត្តាដែលត្រូវពិចារណាដើម្បីអនុវត្តឆន្ទានុសិទ្ធិ គឺមានគោលការណ៍វិមតិសង្ស័យត្រូវបានជាប្រយោជន៍ដល់ជនចាប់ចោទ និងការបកស្រាយច្បាប់ព្រហ្មទណ្ឌយ៉ាងតឹងរ៉ឹង ។ ការអនុវត្តគោលការណ៍ វិមតិសង្ស័យបានជាប្រយោជន៍ដល់ជនជាប់ចោទ ឬ ការបកស្រាយយ៉ាងតឹងរ៉ឹង គឺមានសារសំខាន់ជាងគេនៅក្នុងប្រព័ន្ធមួយដែលច្បាប់ ជាញឹកញាប់មិនបានចែងឲ្យបានពេញលេញ ហើយករណីនេះក៏កើតមានច្រើនដងដែរនៅក្នុងវិស័យផ្សេងៗនៃច្បាប់ព្រហ្មទណ្ឌអន្តរជាតិ (អន្តរជាតិភាវូបនីយកម្ម) ។ ជាពិសេស តាមទស្សនៈរបស់មេធាវីការពារក្តីបទចោទ និងខ្ទឹមសារអង្គច្បាប់ ជារឿយៗហាក់ដូចជាមានលក្ខណៈពន្រឹកមុខសញ្ញាទៅមុខ ។ ការបកស្រាយខុសៗគ្នាជាច្រើនទៅលើទស្សនទានច្បាប់តែមួយនៅ អ.វ.ត.ក និងតុលាការផ្សេងទៀត គឺជាភ័ស្តុតាងយ៉ាងច្បាស់បញ្ជាក់ពីបញ្ហាបែបនេះ ។ តុលាការពិសេសមួយដែលកំណត់អត្ថន័យយ៉ាងតឹងរ៉ឹងអំពីយុត្តាធិការបុគ្គល យុត្តាធិការរឿងក្តី និងយុត្តាធិការពេលវេលា បានផ្អែកលើការចរចាគ្នាយ៉ាងចម្រូងចម្រាស រវាងរដ្ឋាភិបាលជាតិមួយជាមួយសហគមន៍អន្តរជាតិនៅក្នុងសេណារីយ៉ូអន្តរកាលក្រោយសង្គ្រាម ហើយតុលាការនេះបានចាប់ផ្តើមដំណើរការនីតិវិធីក្នុងរយៈពេលជិត៣០ឆ្នាំ ក្រោយព្រឹត្តិការណ៍ឧក្រិដ្ឋកម្មទាំងនោះបានកើតឡើង ។ តុលាការពិសេសបែបនេះគឺជាឧទាហរណ៍មួយយ៉ាងសំខាន់ដែលចាំបាច់ត្រូវកម្រិតការបកស្រាយច្បាប់តាមផ្លូវតុលាការ ។

ទាំងនេះគឺជាការពិត ពីព្រោះដោយសារតែមានសម្ពាធពីការរំពឹងទុករបស់សាធារណជន និងពីប្រព័ន្ធផ្សព្វផ្សាយអំពីការព្រួយបារម្ភទាក់ទងនឹងទស្សនៈនៃនិទណ្ឌភាពចំពោះអំពើឃោរឃៅយង់ឃ្នង របៀបវារៈនយោបាយ ព្រមទាំងការស្រាវជ្រាវប្រវត្តិសាស្ត្រពីមុនៗលើព្រឹត្តិការណ៍សំខាន់ទាំងនោះ ។ នៅក្នុងសេណារីយ៉ូប្រភេទនេះ ពិរុទ្ធភាពរបស់ជនសង្ស័យ ជនត្រូវចោទ និងជនជាប់ចោទ ជារឿយៗហាក់ដូចជាមិនមានការពិភាក្សាដេញដោលទេ ហើយមានការរំពឹងទុកថានឹងមានកិច្ចដំណើរការនីតិវិធីតាមផ្លូវតុលាការដោយគ្រាន់តែដើម្បីឲ្យមានការយល់ស្របជាផ្លូវការទៅលើការយល់ឃើញទូទៅលើប្រវត្តិសាស្ត្រដែលមានអត្ថិភាពរួចហើយ ។

តាមន័យសត្យានុម័ត អ.វ.ត.ក អនុវត្តយុត្តិធម៌តាមការជ្រើសរើស ពីព្រោះថា មានតែមនុស្សមួយក្រុមតូចប៉ុណ្ណោះដែលនឹងត្រូវកាត់សេចក្តីនៅក្នុងតុលាការកម្ពុជាចំពោះអំពើឃោរឃៅដែលបានកើតឡើងនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ពោលគឺជនទាំងឡាយដែលស្ថិតនៅក្នុងវង្វង់យុត្តាធិការរបស់តុលាការនេះ ។ ការចុះកិច្ចព្រមព្រៀងស្តីពីការបង្កើត អ.វ.ត.ក ដោយមិនមានបន្សល់ទុកនូវយុត្តាធិការសេសសល់ណាមួយសម្រាប់តុលាការធម្មតារបស់កម្ពុជានោះ គឺជាជម្រើសនយោបាយដែលបានដឹងរួចហើយនៅក្នុងអំឡុងពេលចរចាគ្នា ដោយបានថ្លឹងថ្លែងឲ្យស្មើគ្នារវាងការអំពាវនាវធ្វើសមាហរណកម្មខ្មែរក្រហមដែលនៅសេសសល់ឲ្យចូលក្នុងសង្គមវិញ ជាមួយនឹងគោលបំណងនៃការបញ្ចប់តាមផ្លូវតុលាការសម្រាប់ការឈឺចាប់ខ្លោចផ្សាររបស់ជនរងគ្រោះ ។ វាពិតជាពិបាកណាស់សម្រាប់សាធារណជន និងជនរងគ្រោះក្នុងការទទួលយកទាហានដែលសម្លាប់កូនក្មេងជាទម្លាប់ដោយបោកក្បាលនឹងគល់ឈើ ឬក៏ប្រកួតគ្នាសម្លាប់មនុស្សឲ្យបានច្រើនជាងគេ ។ នៅក្នុងប្រព័ន្ធច្បាប់ព្រហ្មទណ្ឌរបស់ប្រទេសជាច្រើន អំពើបែបនេះនាំឲ្យមានការដាក់ទោសមួយជីវិតដោយគ្មានថ្ងៃដោះលែង ហើយក្នុងប្រទេសខ្លះ អាចមានទោសប្រហារជីវិតចំពោះអំពើនីមួយៗរបស់ជនល្មើសម្នាក់ៗ ។ ទាំងភាគីជាតិ និងភាគីអន្តរជាតិបានដឹងអំពីភាពខុសគ្នានេះរួចទៅហើយនៅក្នុងអំឡុងពេលចរចាគ្នា ។ម្យ៉ាងចៅក្រមនៅ អ.វ.ត.ក ត្រូវតែគោរពតាមសេចក្តីសម្រេចផ្អែកនយោបាយរបស់អ្នកតាក់តែងសេចក្តីព្រាងច្បាប់ដែលបានជាដឹងមុនរួចហើយ ម្យ៉ាងទៀតស្ថានភាពនេះមិនត្រូវ និងមិនអាចមានន័យថាជាការសន្មតដោយស្វ័យប្រវត្តិនូវការទទួលខុសត្រូវថ្នាក់លើដែលបណ្តាលឲ្យមានការទទួលខុសត្រូវរបស់មនុស្សមួយក្រុមតូចដែលបានបញ្ជូនមកនៅចំពោះមុខ អ.វ.ត.ក ដោយសារតែមានការចោទប្រកាន់ពីអយ្យការនោះទេ ។ ក្រោយរយៈពេលដ៏យូរអង្វែងដែលភ័ស្តុតាងខ្លះក្នុងចំណោមភ័ស្តុតាងសំខាន់ៗ ដូចជាសាក្សី ឬប្រភពផ្សេងទៀតដែលបានធ្វើឲ្យខូចខាតដល់ចំណុចមួយដែលលំបាកទទួលបានភ័ស្តុតាងដែលអាចជឿទុកចិត្តបាន អង្គហេតុពុំមែនជាការងារដែលត្រូវទម្លាក់ការទទួលខុស

ត្រូវឲ្យមេធាវីការពារក្តីនៅក្នុងការស៊ើបអង្កេតព្រហ្មទណ្ឌនោះទេប្ តែក៏នាំឲ្យមានបទដ្ឋានភ័ស្តុតាងកាន់តែស្រាលសម្រាប់បញ្ជូនរឿងទៅជំនុំជម្រះ ឬផ្តន្ទាទោសឡើយ ។ មេធាវីការពារក្តីមានសិទ្ធិទទួលបានការវាយតម្លៃដោយឥតលម្អៀងអំពីភ័ស្តុតាង និងការបកស្រាយច្បាប់នៅគ្រប់ថ្នាក់ទាំងអស់នៃឋានានុក្រមរបស់ អ.វ.ត.ក ដោយគិតចាប់ពី ស.ច.ស ទៅ ។

## លក្ខណវិនិច្ឆ័យក្នុងការអនុវត្តឆន្ទានុសិទ្ធិ-ការធ្វើសេចក្តីសម្រេចនៅក្នុងរចនាសម្ព័ន្ធនៃរបបកម្ពុជាប្រជាធិបតេយ្យ

នៅក្នុងសាលដីកាសំណុំរឿង០០១ អង្គជំនុំជម្រះតុលាការកំពូល បានសម្រេចដោយប្រយោលថា មិនមានការសម្រេចណាមួយក្នុងការអះអាងណាមួយបែបប្រវត្តិសាស្រ្ត-នយោបាយដែលថា ការចរចាគ្នាអំពីការបង្កើត អ.វ.ត.ក នាំឲ្យមានការយល់ឃើញជារួម និងជាប់កាតព្វកិច្ចថា មានតែមនុស្សមួយចំនួនមានកំណត់តែប៉ុណ្ណោះដែលត្រូវស្ថិតនៅក្នុងយុត្តាធិការរបស់តុលាការ (មនុស្សដែលត្រូវមានឈ្មោះ) ។ ការជ្រើសរើសជនដែលត្រូវស៊ើបអង្កេត និងបញ្ជូនទៅជំនុំជម្រះ គឺជាការអនុវត្តឆន្ទានុសិទ្ធិសុទ្ធសាធរបស់សហព្រះរាជអាជ្ញា និង ស.ច.ស ដោយផ្អែកទាំងស្រុងទៅលើអង្គសេចក្តីនៃរឿងក្តីនីមួយៗ ។ តាមទ្រឹស្តី មេដឹកនាំជាន់ខ្ពស់ដែលមិនបានចូលរួមខ្លាំងនៅក្នុងសកម្មភាពឧក្រិដ្ឋរបស់របបកម្ពុជាប្រជាធិបតេយ្យ អាចស្ថិតនៅក្រៅដែនយុត្តាធិការរបស់តុលាការនេះក្នុងនាមជាជនដែលមិនទទួលខុសត្រូវខ្ពស់បំផុត ។ ផ្ទុយមកវិញ ជនណាម្នាក់ដែលមានឋានៈទាបនៅក្នុងឋានានុក្រម អាចត្រូវចាត់ទុកថាជាជនម្នាក់ក្នុងចំណោមជនទាំងឡាយដែលទទួលខុសត្រូវខ្ពស់បំផុត ដោយផ្អែកលើការចូលរួមរបស់ជននោះនៅក្នុងសកម្មភាពឃោរឃៅទាំងនោះ ។ ហេតុនេះ ភាពធ្ងន់ធ្ងរនៃអំពើផ្ទាល់ខ្លួនរបស់ជននោះ និងផលប៉ះពាល់បណ្តាលមកពីអំពើទាំងនោះគឺជាចំណុចត្រឹមត្រូវមួយទៀតដែលយកជាមូលដ្ឋានបាន ។ យើងមិនគួរមើលរំលងផលប៉ះពាល់ជាក់ស្តែងពីដំបូងដែលបណ្តាលមកពីតួនាទីផ្លូវការរបស់ជនណាម្នាក់នៅក្នុងឋានានុក្រមឡើយ ។

ជាងនេះទៀតការធ្វើសេចក្តីសម្រេចក្នុងឋានានុក្រមរបស់ខ្មែរក្រហម មិនមែនធ្វើឡើងដោយមានមតិយោបល់ស្មើភាពគ្នាពីអ្នកមានតួនាទីនៅថ្នាក់ណាមួយ ហើយបន្ទាប់មក មានការពិភាក្សាគ្នារកវិធីដោះស្រាយឡើយ ។ សេចក្តីសម្រេចត្រូវបានធ្វើឡើងនៅថ្នាក់លើ បន្ទាប់មកថ្នាក់ក្រោមជាអ្នកអនុវត្ត ហើយអាចដាក់ទោសជាលក្ខណៈបុគ្គលប្រសិនបើមិនគោរពតាមសេចក្តីសម្រេចទេ ហើយអាចដាក់ទោសកាន់តែច្រើនទៀតដល់ខ្សែរយៈបញ្ជាការថ្នាក់ក្រោមៗប្រសិនបើមិនគោរពតាមសេចក្តីសម្រេចទាំងនោះទេ ។ ការកំណត់គោលនយោបាយចុងក្រោយ និងមធ្យោបាយអនុវត្តគោលនយោបាយ គឺស្ថិតនៅថ្នាក់លើដែលអាចជ្រៀតជ្រែកតាមចិត្តរបស់ពួកគេ ។ តាមពិត ការពិភាក្សាគ្នាដោយចំហអំពីសេចក្តីណែនាំនានាពីអង្គការ អាចត្រូវចាត់ទុកយ៉ាងងាយថាជាជំហានដំបូងនៃការមិនស្តាប់បង្គាប់ ហើយគ្មាននរណាម្នាក់អាចមានសុវត្ថិភាពឡើយប្រសិនបើការពិភាក្សាគ្នាបែបនេះមិនបានរាយការណ៍ទៅផ្នែកពាក់ព័ន្ធនោះទេ ។

## ការពិចារណាអំពីភ័ស្តុតាង-របាយការណ៍ឆ្នាំ ១៩៩៧ និង ១៩៩៨ របស់មជ្ឈមណ្ឌលឯកសារកម្ពុជា និងរបាយការណ៍ឆ្នាំ ១៩៨៤ របស់រដ្ឋាភិបាល

របាយការណ៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជា អាចទទួលបានជាសាធារណៈ ហេតុនេះជាយូរណាស់មកហើយរបាយការណ៍ទាំងនេះបានក្លាយជាមូលដ្ឋានមួយដ៏សំខាន់សម្រាប់ការយល់ឃើញរបស់សាធារណជន ។ ហេតុនេះ មិនចាំបាច់ពន្យល់អំពីមូលហេតុថាតើ ស.ច.ស បានចាត់ទុករបាយការណ៍ទាំងនេះយ៉ាងណានោះទេ និងដោយសារអ្វី ។

របាយការណ៍ឆ្នាំ១៩៩៧ និងឆ្នាំ១៩៩៨ របស់មជ្ឈមណ្ឌលឯកសារកម្ពុជា ពឹងផ្អែកជាចម្បងលើការចុះដល់ទីកន្លែង និងការសម្ភាសន៍ជាមួយប្រភពនានា ហើយក៏បញ្ចូលព័ត៌មានពីរបាយការណ៍ឆ្នាំ១៩៨៤ របស់រដ្ឋាភិបាល ។ របាយការណ៍ទាំងនេះផ្តល់ព័ត៌មានអំពីទីតាំង និងចំនួនជនរងគ្រោះ ។ ទាក់ទិននឹងចំនួនជនរងគ្រោះសម្រាប់ទីតាំងមួយកន្លែង មានតែប្រភពមួយឬពីរតែប៉ុណ្ណោះតាមរយៈមជ្ឈមណ្ឌលឯកសារកម្ពុជាដែលផ្តល់ទិន្នន័យអំពីចំនួនជនរងគ្រោះ ។ របាយការណ៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជាជាសេចក្តីសង្ខេប មិនមានកំណត់ហេតុពេញលេញនៃការសន្ទនាគ្នាជាមួយប្រភពផ្សេងៗទេ ហេតុនេះខ្វះព័ត៌មានខ្វះ ដូចជា តើប្រភពទាំងនោះពឹងផ្អែកលើអ្វីបានជាដឹងពីចំនួនជនរងគ្រោះ ។ ជាងនេះ

ទៀតចំនួនជនរងគ្រោះមិនមានភាពស៊ីសង្វាក់គ្នា ហើយមូលហេតុនៃការស្លាប់មិនភាពមិនច្បាស់លាស់ ។ មានការបង្ហាញឲ្យឃើញថា ចំនួនជនរងគ្រោះនៅក្នុងរបាយការណ៍ឆ្នាំ១៩៨៤ របស់រដ្ឋាភិបាល គឺផ្អែកលើព័ត៌មានដែលប្រមូលបានមានលក្ខណៈជាប្រព័ន្ធច្រើនជាងមជ្ឈមណ្ឌលឯកសារកម្ពុជា ហើយក៏ប្រមូលបានពីប្រភពច្រើនជាងមជ្ឈមណ្ឌលឯកសារកម្ពុជាដែរ ។ របាយការណ៍ឆ្នាំ១៩៨៤ របស់រដ្ឋាភិបាល ក៏ផ្តល់ព័ត៌មានអំពីមូលហេតុនៃការស្លាប់ដែរ ប៉ុន្តែមិនបានបញ្ជាក់ថាបានព័ត៌មាននេះរបៀបណាទេ ។ របាយការណ៍នេះក៏មិនមានកំណត់ហេតុនៃការសន្ទនាគ្នាជាមួយប្រភពនានាដែរ ។ គ្មានរបាយការណ៍ណាមួយក្នុងចំណោមរបាយការណ៍ទាំងនេះបានបញ្ជាក់ពីកាលបរិច្ឆេទដែលជនរងគ្រោះបានស្លាប់ ឬក៏រចនាសម្ព័ន្ធរដ្ឋបាល និងខ្សែរយៈបញ្ជាការដែលការស្លាប់ទាំងនោះបានកើតឡើងដែរ ។ ហេតុនេះក៏មិនអាចកំណត់ថាតើការស្លាប់ទាំងនោះស្ថិតនៅក្នុងយុត្តាធិការពេលវេលាពាក់ព័ន្ធរបស់ អ.វ.ត.ក ឬអត់នោះទេ ។

យោងតាមខាងលើនេះ ស.ច.ស យល់ឃើញថា ចំនួនជនរងគ្រោះនៅក្នុងរបាយការណ៍ឆ្នាំ១៩៩៧ និងឆ្នាំ១៩៩៨ របស់មជ្ឈមណ្ឌលឯកសារកម្ពុជា និងរបាយការណ៍ឆ្នាំ១៩៨៤ របស់រដ្ឋាភិបាលមិនអាចទុកចិត្តបានទេ ហើយមានតម្លៃភ័ស្តុតាងតិចតួច ។ ហេតុនេះ ស.ច.ស មិនបានពឹងផ្អែកលើរបាយការណ៍ទាំងនេះទេ ។ ប៉ុន្តែ ស.ច.ស បានពឹងផ្អែកលើចំនួនមនុស្សស្លាប់ និងមូលហេតុនៃការស្លាប់ដែលសាក្សីនានាផ្តល់ជូនការិយាល័យសហចៅក្រមស៊ើបអង្កេត ។

## សេចក្តីសន្និដ្ឋានលើយុត្តាធិការបុគ្គល

ការសន្និដ្ឋានថា អ៊ឹម ចែម ស្ថិតនៅក្រោយុត្តាធិការបុគ្គលរបស់ អ.វ.ត.ក គឺទីមួយ ដោយបានពិចារណាលើភ័ស្តុតាងពាក់ព័ន្ធនឹងទីតាំងឧក្រិដ្ឋកម្មដែលគាត់ត្រូវបានដាក់ឲ្យស្ថិតក្រោមការពិនិត្យ ។ ទីពីរ សូម្បីតែពិចារណាលើភ័ស្តុតាងពាក់ព័ន្ធនឹងការចោទប្រកាន់ផ្សេងទៀតដែលគាត់មិនត្រូវបានដាក់ឲ្យស្ថិតក្រោមការពិនិត្យក៏ដោយ ក៏ អ៊ឹម ចែម នៅតែស្ថិតនៅក្រោយុត្តាធិការរបស់ អ.វ.ត.ក ដដែល ។ ហេតុនេះហើយបានជាមិនចាំបាច់ដាក់គាត់ ឲ្យស្ថិតនៅក្រោមការពិនិត្យចំពោះការចោទប្រកាន់ដែលនៅសេសសល់ផ្សេងទៀតទេ ។ អ៊ឹម ចែម មិនមែនជាមេដឹកនាំជាន់ខ្ពស់ ហើយក៏មិនស្ថិតនៅក្នុងចំណោមជនដែលទទួលខុសត្រូវខ្ពស់បំផុតដែរ ។ គ្មានភ័ស្តុតាងដែលគាំទ្រដល់ការសន្និដ្ឋានខាងលើ បើទោះបីជាបានពិចារណាទៅដល់តួនាទីរបស់គាត់នៅក្នុងឋានានុក្រមរបស់កម្ពុជាប្រជាធិបតេយ្យឬក៏ភាពធ្ងន់ធ្ងរនៃការប្រព្រឹត្តិរបស់គាត់ដែលត្រូវចោទប្រកាន់ដែរ ។ មានលេខាស្រុកប្រហែលជា១០០ នាក់ផ្សេងទៀតនៅសម័យកម្ពុជាប្រជាធិបតេយ្យ ។ តំណែងជាលេខាស្រុក គ្រាន់តែជាឋានៈទីបីរាប់ពីឋានានុក្រមថ្នាក់ក្រោមតែប៉ុណ្ណោះ (លើថ្នាក់ភូមិ និងថ្នាក់ឃុំ) ។ មានភ័ស្តុតាងគាំទ្រ សេចក្តីសន្និដ្ឋានដែលថា អ៊ឹម ចែម ត្រូវបាន តា ម៉ុក ប្រគល់ភារកិច្ចឲ្យដឹកនាំកម្មាភិបាលភូមិភាគនិរតី ទៅភូមិភាគពាយ័ព្យ ហេតុនេះ គាត់មានតួនាទីមួយដែលមិនត្រូវតាមតួនាទីជាលេខាស្រុកជាទូទៅនោះទេ ប៉ុន្តែត្រូវតែពិចារណាលើអង្គហេតុដែលថា ពីដំបូង អ៊ឹម ចែម ទទួលបានតួនាទីត្រឹមតែជាលេខាស្រុកតែប៉ុណ្ណោះនៅពេលដែលគាត់ទៅដល់ភូមិភាគពាយ័ព្យភ្លាម ហើយក្រោយមក ទើបគាត់បានក្លាយជាសមាជិកគណៈតំបន់ ។ ការដំឡើងឋានៈបែបនេះគឺផ្ទុយពីការដំឡើងឋានៈខ្ពស់ជាផ្លូវការ ។

មានការបង្ហាញយ៉ាងច្បាស់ថា ពីដំបូងគាត់ត្រូវបានចាត់ទុកថាស្ថិតនៅក្នុងចំណោមជនដែលទទួលខុសត្រូវខ្ពស់បំផុត ដោយសារថា បើតាមការចោទប្រកាន់ មានមនុស្សស្លាប់ចំនួន៤០.០០០នាក់ នៅមន្ទីរសន្តិសុខភ្នំត្រយ៉ោងតែមួយប៉ុណ្ណោះ ។ ច្បាស់ណាស់ដែលថាការចោទប្រកាន់នេះអាចតវ៉ាបាន ប៉ុន្តែភ័ស្តុតាងដែលបានរកឃើញនៅក្នុងអំឡុងពេលស៊ើបអង្កេត បានបញ្ជាក់ថា នៅទីតាំងឧក្រិដ្ឋកម្មទាំងអស់ដែលបានដាក់ឲ្យស្ថិតក្រោមការពិនិត្យឬក៏មិនបានដាក់ឲ្យស្ថិតនៅក្រោមការពិនិត្យជនរងគ្រោះមានចំនួនតិចជាងនេះឆ្ងាយណាស់ ។

សរុបមក ទាំងកត្តាបុគ្គល ទាំងកត្តាទាំងអស់បូករួមបញ្ចូលគ្នាដែលបានពិចារណា ស.ច.ស មិនអាចធ្វើការសន្និដ្ឋានថា អ៊ឹម ចែម ស្ថិតនៅក្នុងប្រភេទជនដែលទទួលខុសត្រូវខ្ពស់បំផុតទេ និងថែមទាំងមិនអាចសន្មតថា មានសំអាងហេតុគាំទ្រការចោទប្រកាន់ថាគាត់ទទួលខុសត្រូវចំពោះឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តនៅទីតាំងដែលបានស៊ើបអង្កេតនោះទេ ។

**អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា**

# មាត់អត់អាហារ

យាយ ផាន់ ទឹង កើតក្នុងឆ្នាំ១៩៤៦ ក្នុងភូមិលំទងចាស់ ឃុំលំទង ស្រុកអន្លង់វែង ខេត្តឧត្តរមានជ័យ ។ យាយ ទឹង មានបងប្អូន ៣នាក់ ។ យាយ ទឹង ត្រូវបានឪពុកម្តាយរៀបចំឲ្យមានគ្រួសារ ក្នុងវ័យ១៨ឆ្នាំ ហើយគាត់បង្កើតបានកូនប្រុសស្រី៥នាក់ (ស្រី២ ប្រុស៣នាក់) ។ ពេលនោះ ឃុំលំទង ដែលយាយ ទឹង រស់នៅគឺជាតំបន់ ដាច់ស្រយាលពីទីប្រជុំជន ហេតុដូច្នេះនៅក្នុងសម័យសង្គមរាស្ត្រនិយម និងសម័យសាធារណរដ្ឋខ្មែរ ប្រជាពលរដ្ឋក្នុងភូមិក៏ដូចជា យាយ ទឹង ផ្ទាល់ ហាក់មិនបានដឹងកិច្ចការនយោបាយ ឬការដឹកនាំប្រទេសនោះទេ ។ យាយ ទឹង បានរៀបរាប់ថា នៅក្នុងឆ្នាំ១៩៧៤ ខ្មែរក្រហមបានចូលមកដល់ស្រុកភូមិរបស់គាត់ ។ ពេលនោះខ្មែរក្រហមបានសម្តែងរបាំ និងច្រៀងបទបដិវត្តន៍ ដោយបានប្រមូល និងកៀងគរអ្នកភូមិឲ្យចូលរួមទស្សនាការសម្តែងនោះ ។ ក្រោយមកទៀត ខ្មែរក្រហមក៏បានបើកសាលាបង្រៀនអក្សរ និងបង្រៀនចម្រៀងបដិវត្តន៍ដល់ក្មេងៗនៅក្រោមដើមឈើដែលមានម្លប់ត្រឈឹងត្រឈៃ ស្ថិតនៅក្បែរមាត់ទឹក និងនៅមិនឆ្ងាយប៉ុន្មានពីភូមិ ។ សម័យនោះខ្មែរក្រហមបានយកចិត្តទុកដាក់ជាមួយប្រជាជននៅក្នុងភូមិខ្លាំងណាស់ ។ ខ្មែរក្រហមបានអំពាវនាវឲ្យប្រជាជនចូលរួមជាមួយចលនារបស់ខ្លួន ដើម្បីផ្តួលរំលំរបបសក្តិភូមិជិះជាន់ និងរំដោះប្រជាជនក្រីក្រចេញពីចក្រពត្តិនិយមអាមេរិក ។ ខ្មែរក្រហមបានសន្យាជាមួយអ្នកភូមិថា ពេលខ្លួនដឹកនាំប្រទេស ខ្លួននឹងដឹកនាំប្រជាជនឲ្យរស់នៅស្មើភាពគ្នា មិនមានអ្នកមានអ្នកក្រ និងលុបបំបាត់ចោលវណ្ណៈសក្តិភូមិដែលជាវណ្ណៈជិះជាន់ ។ យាយ ទឹង បានរំឭកថា កាលនោះប្រជាជនក្នុងភូមិរួមទាំងខ្លួនគាត់ផ្ទាល់ មិនមានការយល់ដឹងជ្រៅជ្រះទេទាក់ទងរឿងនយោបាយ ។



យាយ ផាន់ ទឹង នៅផ្ទះរបស់គាត់នៅភូមិលំទងចាស់ ឃុំលំទង ស្រុកអន្លង់វែង ខេត្តឧត្តរមានជ័យ ។

នៅឆ្នាំ១៩៧៥ ខ្មែរក្រហមបានផ្តួលរលំរបបសាធារណរដ្ឋខ្មែរដែលដឹកនាំដោយ លន់ នល់ ។ នៅក្នុងឆ្នាំដដែល បន្ទាប់ពីខ្មែរក្រហមបានឡើងកាន់អំណាច ខ្មែរក្រហមចាប់ផ្តើមរឹតបន្តឹងការរស់នៅរបស់ប្រជាជននៅក្នុងភូមិ ។ ពេលនោះ សម្ភារប្រើប្រាស់ រួមមាន ចាន ឆ្នាំង របស់គ្រួសារយាយ ទឹង ក៏ដូចជារបស់ប្រជាជនក្នុងភូមិត្រូវបានខ្មែរក្រហមប្រមូល និងដាក់ឲ្យប្រើប្រាស់ជារបស់រួម ។ រយៈពេលពីរបីខែក្រោយមក គ្រួសារយាយ ទឹង ត្រូវបានខ្មែរក្រហមជម្លៀសឲ្យទៅនៅភូមិផ្អុង ។ នៅទីនោះ ជីវិតគ្រួសាររបស់យាយ ទឹង ចាប់ផ្តើមលំបាកបណ្តើរៗ ដោយសារខ្មែរក្រហមបានបង្ខំឲ្យគ្រួសាររបស់គាត់ និងប្រជាជនធ្វើការហួសកម្លាំង និងហូបតែបបររាវ ។ គ្រួសារយាយ ទឹង រស់នៅភូមិផ្អុងបានជិតមួយឆ្នាំ ក៏ត្រូវខ្មែរក្រហមជម្លៀសឲ្យមករស់នៅស្រុកកំណើតវិញ ។ យាយ ទឹង ត្រូវបានខ្មែរក្រហមចាត់ឲ្យដេរស្លឹក ដោយសារពេលនោះគាត់មានផ្ទៃពោះ ។ ក្រោយពីសម្រាលកូនបានរយៈពេលប្រាំថ្ងៃ ខ្មែរ

ក្រហមបានចាត់ឲ្យគាត់ធ្វើការងារដេរស្លឹកបន្តទៀត បន្ទាប់មកទើបបង្ខំគាត់ឲ្យកាប់ឆ្ការព្រៃ និងរានដីធ្វើស្រែ ។ រីឯរបបអាហារវិញ គាត់មិនដែលទទួលបានគ្រប់គ្រាន់ទេ ។ ពេលខ្លះ យាយ ទឹង លួចបូតស្រូវយកមកលីង និងលួចគាស់មើមរការ ក្តួច និងដំឡូងយកមកដុតហូបថែមទៀត ។

នៅចុងឆ្នាំ១៩៧៧ វ៉ន ដែលជាគណៈស្រុកអន្លង់វែងថ្មី បានបញ្ជាឲ្យជម្លៀស ប្រជាជននៅអន្លង់វែងទាំងអស់ឲ្យទៅរស់នៅតាមសហករណ៍នៅក្នុងឃុំកំពង់ថ្កូវ ស្រុកក្រឡាញ់ ខេត្តសៀមរាប ។ ប្រជាជនអន្លង់វែងមួយចំនួនត្រូវបានបញ្ជូនទៅស្រុកវ៉ារិន្ទ ស្រីស្នំ សំរោង និងចុងកាល់ ។ ក្នុងចំណោមប្រជាជនទាំងអស់ដែលត្រូវបានជម្លៀស ក៏មានគ្រួសាររបស់យាយ ទឹង ដែរ ។ គ្រួសាររបស់គាត់ ត្រូវបានខ្មែរក្រហមជម្លៀសឲ្យទៅនៅឃុំកំពង់ថ្កូវ ។ ទៅដល់កំពង់ថ្កូវបានមួយរយៈ ប្តីរបស់យាយ ទឹង បានស្លាប់ដោយសារជំងឺហើម ។ ការរស់នៅ ក៏ដូចជាការងារនៅទីនោះ មិនខុសពីកន្លែងដែលខ្មែរក្រហមជម្លៀសយាយ ទឹង ឲ្យទៅរស់នៅមុនទេ គឺកូនៗរបស់យាយទឹង ត្រូវបានអង្គការចាត់ឲ្យទៅធ្វើការនៅកងកុមារ ចំណែក យាយ ទឹង ត្រូវបានអង្គការចាត់ឲ្យចូលក្នុងកងចល័តនារី ។ ការងារកងចល័តពេលនោះ គឺគាត់ត្រូវធ្វើការដកស្ទូង កាប់រានដី វែកដី ច្រូតកាត់ និងលើកទំនប់ ។ ក្នុងរយៈពេលរស់នៅក្នុងឃុំកំពង់ថ្កូវ គាត់មិនដែលបានហូបបាយទេ គឺហូបតែបបររាវៗប៉ុណ្ណោះ ។ ចំណែកការងារពេលខ្លះ គាត់ធ្វើរហូតដល់ម៉ោង៩យប់ ទើបបានឈប់សម្រាក ។ មានថ្ងៃខ្លះ យាយ ទឹង ហត់ហេវអស់កម្លាំងស្ទើរដើរមិនរួច ដូច្នេះដើម្បីបំពេញសេចក្តីស្រេកឃ្លាន គាត់ក៏បានសម្រេចចិត្តលួចគាស់មើមដំឡូង ក្តួច មើមរការ និងចាប់ក្តាម ខ្យង ហើយពេលខ្លះគាត់ចាប់សត្វពស់យកមកដុតហូប ។ នៅរដូវស្រូវទុំ យាយ ទឹង បានលួចដើរបូតស្រូវយកមកលីងហូបថែមទៀត ។ យាយ ទឹង បានរំឭកថា មានពេលខ្លះគាត់ហូបក្អែប ខ្យាដំរី ដើម្បីបំពេញសេចក្តីស្រេកឃ្លាន និងធ្វើយ៉ាងណាឲ្យជីវិតរស់ ។ ជាសំណាងល្អដែលកងឈ្លបខ្មែរក្រហមមិនដែលចាប់គាត់បាន ។

នៅឆ្នាំ១៩៧៩ ពេលរបបខ្មែរក្រហមត្រូវបានផ្តួលរំលំ គ្រួសារយាយ ទឹង បាននាំគ្នាដើរត្រឡប់មកស្រុកកំណើតវិញ ដោយគាត់ត្រូវចំណាយពេលជិតមួយខែក្នុងការធ្វើដំណើរ ។ អំឡុងពេលធ្វើដំណើរ អាកាសធាតុក្តៅយ៉ាងខ្លាំងធ្វើឲ្យរុក្ខជាតិនៅតាមផ្លូវក្រៀមស្វិត ដីចាប់ផ្តើមប្រេះក្រហែង ស្ទឹងបឹងបួរនៅតាមផ្លូវក៏រីងស្ងួតអស់ ។ មានថ្ងៃខ្លះ យាយ ទឹង មិនមានទឹកផឹកជិតមួយថ្ងៃក៏មាន ។ យាយ ទឹង បានបន្តថា ជាញឹកញាប់នៅពេលរកទឹកផឹកមិនបាន គាត់ និងកូនៗបានយកមុងទៅច្រោះទឹកភក់ យកមកផឹក និងដាំបាយ ។ ពេលដើរជិតដល់ភូមិកំណើតគាត់បានទទួលដំណឹងថាប្អូនប្រុសរបស់គាត់ពីរនាក់របស់គាត់ត្រូវកងទ័ពវៀតណាមចាប់ខ្លួន រួចបាញ់សម្លាប់ចោល ដោយចោទប្អូនប្រុសរបស់គាត់ថា ជាខ្មែរក្រហម ។ ដូច្នេះ គ្រួសារយាយ ទឹង ក៏នាំគ្នាទៅរស់នៅភូមិរំចេកវិញ ។ មួយរយៈក្រោយមក ដោយសភាពការណ៍ចលាចលខ្លាំង គ្រួសារយាយ ទឹង ក៏ត្រឡប់ទៅរស់នៅស្រែណូយវិញ ។ តមកគ្រួសារគាត់ក៏នាំគ្នាភៀសខ្លួនទៅរស់នៅលើភ្នំដងរែក បន្ទាប់ពីមានការប្រយុទ្ធគ្នារវាងកងទ័ពខ្មែរក្រហមដែលដឹកនាំដោយ តាម៉ុក ជាមួយនឹងកងទ័ពរដ្ឋាភិបាល ។ គ្រួសារយាយ ទឹង បានរស់នៅកន្លែងមួយ ដែលសម័យនោះហៅថា ភ្នំ៤០ ។ បន្ទាប់ពីសង្គ្រាមបានស្ងប់ស្ងាត់ យាយ ទឹង បានចុះពីលើភ្នំមករស់នៅជំរំកូណយវិញ ។ យាយ ទឹង រស់នៅជំរំកូណយ បានមួយរយៈក៏ភៀសខ្លួនឡើងលើភ្នំវិញ ដោយសារមានការប្រយុទ្ធគ្នាម្តងទៀត រវាងកងកម្លាំងខ្មែរក្រហម និងកងទ័ពរដ្ឋាភិបាល ។ ក្រោយមក កងទ័ពខ្មែរក្រហមដែលនៅសេសសល់បានធ្វើសមាហរណកម្មចុះចូលជាមួយរាជរដ្ឋាភិបាល ទើបយាយ ទឹង និងកូនចៅក៏បានមករស់នៅភូមិលំនៅចាស់ដែលជាស្រុកកំណើតវិញ ។ កូនចៅ និងគ្រួសាររបស់យាយ ទឹង ក៏ចាប់ផ្តើមរបរធ្វើស្រែចម្ការចាប់តាំងពីពេលនោះមក ។ យាយ ទឹង បានឲ្យដឹងថា សព្វថ្ងៃនេះគាត់សោកស្តាយដែលមាត់របស់គាត់បរិភោគអាហារលែងដឹងរស់ជាតិ ទោះរបស់នោះជាគុយទាវ ឬអាហារដែលមានរស់ជាតិឆ្ងាញ់ដែលកូនៗ ទិញយកមកឲ្យគាត់បរិភោគក៏ដោយ ។ ទម្រាំប្រទេសជាតិចប់សង្គ្រាម និងមានសន្តិភាព គាត់ដល់វ័យចាស់ណាស់ទៅហើយ ។ គាត់មានប្រសាសន៍ថា «បើពីមុនហូបអីក៏ឆ្ងាញ់ដែរ សូម្បីស៊ីស្រូវលីង ស៊ីក្អែប ស៊ីខ្យាដំរី តែមកដល់សព្វថ្ងៃមាត់គាត់គ្មានសំណាងទេ» ។

**យាង សេងហឿន**

# ដំណឹងស្វែងរកបងប្អូន

ខ្ញុំបាទឈ្មោះ ផុន សារួន រស់នៅភូមិពោធិ៍ស្នាយ ឃុំព្រៃឃ្នេស ស្រុកមេសាង ខេត្តព្រៃវែង ។ សូមប្រកាសរកបងប្រុសបងស្រី ដែលបានបាត់ខ្លួនក្នុងរបបខ្មែរក្រហម ដូចមានរាយនាមដូចខាងក្រោម ៖

១) កុន ចាន់ថា (ស្រី) កើតឆ្នាំរកា នៅពេលបាត់ខ្លួនមានអាយុ២១ឆ្នាំ ។ បងស្រី កុន ចាន់ថា បានបាត់ខ្លួននៅឆ្នាំ១៩៧៧ នៅពេលដែលខ្មែរក្រហមជម្លៀស និងឲ្យគាត់ទៅធ្វើការនៅដប់ពាមជាំង ស្រុកអូររាំងឪ ខេត្តកំពង់ចាម (ត្បូងឃ្មុំ) ។ បងស្រីធ្វើជាកម្មករនៅរោងចក្រស្លកៅស៊ូ នៅដប់ពាមជាំង ហើយក្រោយមកក៏បាត់ដំណឹងពីគាត់រហូត ។ ចាន់ថា មាខធំល្មម សម្បុរខ្មៅស្រអែម និងមានកម្ពស់ ១.៥៥ម៉ែត្រ ។

២) កុន សាបី (ប្រុស) កើតឆ្នាំឆ្លូវ នៅពេលបាត់ខ្លួនមានអាយុ១៧ឆ្នាំ ។ បងប្រុស កុន សាបី បានបាត់ខ្លួននៅឆ្នាំ១៩៧៧ អំឡុងពេលដែលខ្មែរក្រហមចាត់គាត់ឲ្យទៅធ្វើទ័ពនៅខេត្តស្វាយរៀង ។ ចាប់តាំងពីពេលចេញទៅធ្វើទ័ពក៏បាត់ដំណឹងពីបងប្រុសរហូត ។ សាបី មាខធំល្មម សម្បុរខ្មៅស្រអែម កម្ពស់ ១.៦៥ម៉ែត្រ ។ អ្នកទាំងពីរមានស្រុកកំណើតនៅភូមិពោធិ៍ស្នាយ ឃុំព្រៃឃ្នេស ស្រុកមេសាង ខេត្តព្រៃវែង ។ ខ្ញុំមានឪពុកឈ្មោះ ពោច កុន (ស្លាប់) និងម្តាយឈ្មោះ ខាត់ ស៊ី និងមានបងប្អូនបង្កើតចំនួន១៤នាក់ ៖

១) កុន ចាន់ថា (ស្រី) បាត់ខ្លួន

២) កុន សម្បត្តិ (ប្រុស)

៣) កុន សាបី (ប្រុស) បាត់ខ្លួន

៤) កុន សាបន (ប្រុស) ស្លាប់

៥) កុន សាបាន (ប្រុស)

៦) កុន សុគុន (ប្រុស)

៧) កុន សុគឿន (ប្រុស)

៨) កុន សុគួន (ប្រុស)

៩) កុន ចាន់ឌាន (ស្រី)

១០) កុន ចាន់ឌី (ស្រី)

១១) កុន សំអឿន (ស្រី)

១២) កុន សំអួន (ស្រី)

១៣) កុន សារួន (ប្រុស)

១៤) កុន រិទ្ធិ (ប្រុស)

អាស្រ័យដូចបានរៀបរាប់ខាងលើ ប្រសិនបើបងប្អូនណាបានស្គាល់ និងដឹងដំណឹងអំពីបងប្រុសបងស្រីរបស់ខ្ញុំទាំងពីរ ដូចដែលបានរាយនាមខាងលើ សូមមេត្តាទំនាក់ទំនងមកកាន់មជ្ឈមណ្ឌលឯកសារកម្ពុជា តាមរយៈអាសយដ្ឋានផ្ទះលេខ៦៦ មហាវិថីព្រះសីហនុ សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន និងទូរសព្ទ ០២៣ ២១៨ ០០៩ ឬក៏ទំនាក់ទំនងមកខ្ញុំបាទផ្ទាល់តាមរយៈទូរសព្ទលេខ ០៩២ ២០៤ ៣៦៧ , ០៦៩ ៥៨៣ ៥០០ ឬសារអេឡិចត្រូនិច phunsaroun@gmail.com ។ **សូមអរគុណ!**

# សៀវភៅរំឭកវិញ្ញាណក្ខន្ធអ្នកដែលបានស្លាប់
# នៅក្នុងរបបខ្មែរក្រហម




មជ្ឈមណ្ឌលឯកសារកម្ពុជា គ្រោងនឹងបោះពុម្ពផ្សាយនូវសៀវភៅមានកត់ត្រាឈ្មោះរបស់អ្នកដែលស្លាប់បាត់បង់ជីវិតនៅក្នុងរបបខ្មែរក្រហម ។ កន្លងមក មជ្ឈមណ្ឌលឯកសារកម្ពុជាបានចងក្រងនូវឈ្មោះអ្នកដែលស្លាប់ជាង១លាននាក់រួចមកហើយ ។ ប្រសិនបើលោកយាយ លោកតា អ៊ំ ពូ មីង ប្រាថ្នាចង់ឲ្យឈ្មោះសមាជិកក្រុមគ្រួសារដែលបានស្លាប់បាត់បង់ជីវិតមាននៅក្នុងសៀវភៅនេះ សូមទាក់ទងមកកាន់មជ្ឈមណ្ឌលឯកសារកម្ពុជាតាមរយៈ វ៉ាន់ថាន់ ពៅដារ៉ា ទូរសព្ទលេខ ០១២ ៨៤៦ ៥២៦ ឬ អ៊ីម៉ែល ៖ *truthpdara@dccam.org* ឲ្យបានឆាប់រហ័សតាមពេលវេលាដែលអាចធ្វើទៅបាន ។




**សូមផ្តល់ព័ត៌មានដូចខាងក្រោមៈ**

១) ឈ្មោះអ្នកប្រកាសប្រាប់, ២) តើមានបងប្អូនបង្កើតរួមទាំងឪពុកម្តាយស្លាប់ប៉ុន្មាននាក់នៅក្នុងសម័យខ្មែរក្រហម? ៣) ឈ្មោះអ្នកស្លាប់, ៤) ភេទអ្នកស្លាប់, ៥) អាយុអ្នកស្លាប់ (បើអាចចាំបាន), ៦) ត្រូវជាអ្វីនឹងអ្នកប្រកាស (ឧទាហរណ៍ៈ ឪពុក ម្តាយ បងប្រុស ប្អូនប្រុស បងស្រី ឬប្អូនស្រី), ៧) សាច់រឿងទាក់ទងនឹងការស្លាប់ (ឧទាហរណ៍ ៖ ស្លាប់នៅទីណា? មូលហេតុអ្វី?), ៨) វត្ថុតាងទាក់ទងនឹងអ្នកស្លាប់ (ឧទាហរណ៍ៈ រូបថត ឯកសារ ឬវត្ថុផ្សេងៗ), ៩) ព័ត៌មានសម្រាប់មជ្ឈមណ្ឌលទាក់ទង (ឧទាហរណ៍ៈ លេខទូរស័ព្ទ អាស័យដ្ឋាន) ។

**ប្រសិនបើចង់ស្វែងរកអ្នកដែលបាត់ខ្លួនសូមផ្តល់ព័ត៌មានខាងក្រោមៈ**

១) ឈ្មោះអ្នកបាត់ខ្លួន, ២) ភេទ, ៣) អាយុ, ៤) ត្រូវជាអ្វី, ៥) សាច់រឿងទាក់ទងនឹងការបែកគ្នា, ៦) វត្ថុតាងទាក់ទងនឹងអ្នកបាត់ខ្លួន (ឧទាហរណ៍ៈ រូបថត ឯកសារ ឬវត្ថុផ្សេងៗ) ។




ដើម្បីយុត្តិធម៌និងការចងចាំ
ដែលជាមូលដ្ឋានដ៏សំខាន់ក្នុងការផ្សះផ្សាជាតិ

ឧបត្ថម្ភការបោះពុម្ពផ្សាយដោយ ទីភ្នាក់ងារអភិវឌ្ឍន៍អន្តរជាតិ សហរដ្ឋអាមេរិក (USAID)
អនុញ្ញាតឲ្យបោះពុម្ពផ្សាយដោយក្រសួងព័ត៌មាននៃព្រះរាជាណាចក្រកម្ពុជា ប្រកាសទេសរដ្ឋមន្ត្រីនិងរដ្ឋមន្ត្រីក្រសួងព័ត៌មានលេខ ០២៩១ពម.៩៩ចុះថ្ងៃទី២ ខែសីហា ឆ្នាំ១៩៩៩

**មជ្ឈមណ្ឌលឯកសារកម្ពុជា ៖ ការិយាល័យព័ត៌មានសាធារណៈ**
ផ្ទះលេខ ៦៦, មហាវិថីព្រះសីហនុ ភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ទូរសព្ទ ៖ (៨៥៥) ២៣ ២១១ ៨៧៥ ទូរសារ ៖ (៨៥៥) ២៣ ២១០ ៣៥៨

DC-Cam/PIR : #66 ◆ Preah Sihanouk Blvd ◆ Phnom Penh ◆ Cambodia ◆ Tel: (855) 23 211 875 ◆ Fax: (855) 23 210 358 ◆ dccam@online.com.kh ◆ www.dccam.org.
A magazine of the Documentation Center of Cambodia: Searching for the truth. ◆ Number 214, 2017 ◆ Funded by USAID.
Licensed by the Ministry of Information of the Kingdom of Cambodia, Prakas No.0291 P.M/99, 2 August 1999.